# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## សត្តកនិបាត

## ភាគ ៤៧

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

សត្តកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ រួមមាន ៥៣ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៥៨ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## សត្តកនិបាត

## ភាគ ៤៧

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

សត្តកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ រួមមាន ៩៣ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៥៨ សូត្រ

# អង្គុត្តរនិកាយ សត្តកនិបាត

## រួមមាន

### ១ បណ្ណាសកៈ មាន ៥ វគ្គ និងសូត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ ៣ វគ្គ និងសូត្រមិនសង្គ្រោះចូលក្នុងវគ្គ ១០ សូត្រ សរុបមាន ៩៣ សូត្រ

### ព្រះអដ្ឋកថាកែសេចក្តី ៥៨ សូត្រ

**បឋមបណ្ណាសកៈ**

| | | | |
|---|---|---|---|
| ១ ធម្មវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |
| ២ អនុសយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៨ សូត្រ |
| ៣ វជ្ជីវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៧ សូត្រ |
| ៤ ទេវតាវគ្គ | មាន ១២ សូត្រ | អដ្ឋកថាកែសេចក្តី | ០៤ សូត្រ |
| ៥ មហាយ័ញ្ញវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |

**វគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ**

| | | | |
|---|---|---|---|
| ១ អព្យាកតវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ២ មហាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ៣ វិនយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៤ សូត្រ |

**សូត្រមិនសង្គ្រោះក្នុងវគ្គ**

មាន ១០ សូត្រ អដ្ឋកថាកែសេចក្តីរួម

# ស្រះនិងស្រៀយ

## *Signes et accents:*



# ស្រះពេញតួ

# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡាតាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈគឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដី នេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី

រីករាយ និងសួរជាបន្តៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញុំាងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកដៃផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធ-សាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់

នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមកត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់កត្តដែលមិនបានធ្វើវិនយកម្មមុន ឬមិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមកត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បាន ស្តាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរស របស់ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំង ឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ ក្រាបាន ពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យ សង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោ- កុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយ ក្នុងវវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុង ព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យ មហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមក ពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទ ពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពី ត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែក គ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាល និកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើត ឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញ មកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយ នេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែក ចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បី ជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈ ជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីបបាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះអាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ

ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារគ្របសង្កត់របួត សកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្សាយ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលីយ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរបួតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈគង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទយ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថាឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបាន

ឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីប មានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសជ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ខ្វះ (សិរិកុដៈ) ខ្វះ (សិរិកូដ្ឋៈ) ខ្វះ ពុទ្ធសកករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កា ទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះ ឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយ ក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចដ៏យ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេ-

ត្តេយ្យពោធិសត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡ: មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈនិមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា

អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនាក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធាន

ហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន ឧបាសក ឆាក់ម៉ៅ

ឧបាសក ឌុំ ឌួន ឧបាសក ហុកសីឆ័ហ្វាត

ឧបាសក ជីម ជំនិត ឧបាសក កើត ធិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ដុន ឧបាសក ជា ស៊ីថាន

ឧបាសិកា ថាប់ លឿម ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គធិន្នោ នូវ ប៊ូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ជុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ជុត តៅ ធម្មាចារ្យ

ព្រះភិក្ខុតេជធរោ ធាវ ធាន ធម្មាចារ្យ

សាមណេរ កោវិទោ ឡោះស្វៀតសមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី

បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ-

ឧទ្ទិសថ្វាយ និងគោរពជូន :

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណ:

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## សត្តកនិបាត បឋមបណ្ណាសកៈ

### ធនវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា បឋមបិយសូត្រ | ទី ១ | ១ |
| អដ្ឋកថា ទុតិយបិយសូត្រ | ទី ២ មិនមានអដ្ឋកថា | ២ |
| អដ្ឋកថា បឋមពលសូត្រ | ទី ៣ | ៣ |
| អដ្ឋកថា ទុតិយពលសូត្រ | ទី ៤ | ៤ |
| អដ្ឋកថា បឋមធនសូត្រ | ទី ៥ | ៥ |
| អដ្ឋកថា ទុតិយធនសូត្រ | ទី ៦ មិនមានអដ្ឋកថា | ៦ |
| អដ្ឋកថា ឧគ្គសូត្រ | ទី ៧ | ៧ |
| អដ្ឋកថា សំយោជនសូត្រ | ទី ៨ | ៩ |
| អដ្ឋកថា បហានសូត្រ | ទី ៩ មិនមានអដ្ឋកថា | ១០ |
| អដ្ឋកថា មច្ឆរិសូត្រ | ទី ១០ មិនមានអដ្ឋកថា | ១១ |


### អនុសយវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា បឋមអនុសយសូត្រ | ទី ១ មិនមានអដ្ឋកថា | ១២ |
| អដ្ឋកថា ទុតិយអនុសយសូត្រ | ទី ២ មិនមានអដ្ឋកថា | ១៣ |
| អដ្ឋកថា កុលសូត្រ | ទី ៣ | ១៤ |
| អដ្ឋកថា បុគ្គលសូត្រ | ទី ៤ | ១៥ |
| អដ្ឋកថា ឧទកូបមសូត្រ | ទី ៥ | ២១ |
| អដ្ឋកថា អនិច្ចានុបស្សីសូត្រ | ទី ៦ | ២៣ |
| អដ្ឋកថា ទុក្ខានុបស្សីសូត្រ | ទី ៧ | ២៧ |
| អដ្ឋកថា អនត្តានុបស្សីសូត្រ | ទី ៨ | ២៨ |
| អដ្ឋកថា និព្វានសូត្រ | ទី ៩ | ២៩ |
| អដ្ឋកថា និទ្ទសវត្ថុសូត្រ | ទី ១០ | ៣០ |

**វជ្ជីវគ្គ ទី ៣**

| | | | | |
|---|---|---|---|---|
| អដ្ឋកថា | សារន្ទទសូត្រ | ទី ១ | | ៣៤ |
| អដ្ឋកថា | វស្សការសូត្រ | ទី ២ | | ៤៧ |
| អដ្ឋកថា | ភិក្ខុសូត្រ | ទី ៣ | | ៥៣ |
| អដ្ឋកថា | កម្មសូត្រ | ទី ៤ | | ៦៤ |
| អដ្ឋកថា | សទ្ធិយសូត្រ | ទី ៥ | មិនមានអដ្ឋកថា | ៦៨ |
| អដ្ឋកថា | ពោធិយសូត្រ | ទី ៦ | មិនមានអដ្ឋកថា | ៦៩ |
| អដ្ឋកថា | សញ្ញាសូត្រ | ទី ៧ | | ៧០ |
| អដ្ឋកថា | សេក្ខសូត្រ | ទី ៨ | | ៧១ |
| អដ្ឋកថា | ហានិសូត្រ | ទី ៩ | | ៧២ |
| អដ្ឋកថា | វិបត្តិសម្ភវសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ៧៣ |

**ទេវតាវគ្គ ទី ៤**

| | | | | |
|---|---|---|---|---|
| អដ្ឋកថា | អប្បមាទសូត្រ | ទី ១ | | ៧៤ |
| អដ្ឋកថា | ហិរិមាសូត្រ | ទី ២ | មិនមានអដ្ឋកថា | ៧៥ |
| អដ្ឋកថា | បឋមសុវចសូត្រ | ទី ៣ | មិនមានអដ្ឋកថា | ៧៦ |
| អដ្ឋកថា | ទុតិយសុវចសូត្រ | ទី ៤ | មិនមានអដ្ឋកថា | ៧៧ |
| អដ្ឋកថា | បឋមសខាសូត្រ | ទី ៥ | | ៧៨ |
| អដ្ឋកថា | ទុតិយសខាសូត្រ | ទី ៦ | | ៨០ |
| អដ្ឋកថា | បឋមបដិសម្ភិទាសូត្រ | ទី ៧ | | ៨១ |
| អដ្ឋកថា | ទុតិយបដិសម្ភិទាសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ៨៣ |
| អដ្ឋកថា | បឋមវសសូត្រ | ទី ៩ | មិនមានអដ្ឋកថា | ៨៤ |
| អដ្ឋកថា | ទុតិយវសសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ៨៥ |
| អដ្ឋកថា | បឋមនិទ្ទសសូត្រ | ទី ១១ | មិនមានអដ្ឋកថា | ៨៦ |
| អដ្ឋកថា | ទុតិយនិទ្ទសសូត្រ | ទី ១២ | មិនមានអដ្ឋកថា | ៨៧ |

**មហាយញ្ញវគ្គ ទី ៥**

| | | | | |
|---|---|---|---|---|
| អដ្ឋកថា | ចិត្តសូត្រ | ទី ១ | | ៨៨ |
| អដ្ឋកថា | បរិក្ខារសូត្រ | ទី ២ | | ៩៥ |
| អដ្ឋកថា | បឋមអគ្គិសូត្រ | ទី ៣ | | ៩៦ |

អដ្ឋកថា ទុតិយអគ្គិសូត្រ ទី ៤ ៩៩
អដ្ឋកថា បឋមសញ្ញាសូត្រ ទី ៥ ១០២
អដ្ឋកថា ទុតិយសញ្ញាសូត្រ ទី ៦ ១០៣
អដ្ឋកថា មេថុនសូត្រ ទី ៧ ១០៥
អដ្ឋកថា សំយោគសូត្រ ទី ៨ ១០៨
អដ្ឋកថា ធានសូត្រ ទី ៩ ១១០
អដ្ឋកថា មេត្តាសូត្រ ទី ១០ ១១៣


## វគ្គមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

### អព្យាកតវគ្គ ទី ១


អដ្ឋកថា អព្យាកតសូត្រ ទី ១ ១២២
អដ្ឋកថា បុរិសគតិសូត្រ ទី ២ ១២៤
អដ្ឋកថា តិស្សសូត្រ ទី ៣ ១២៨
អដ្ឋកថា សីហសូត្រ ទី ៤ ១៣០
អដ្ឋកថា រក្ខិតសូត្រ ទី ៥ ១៣១
អដ្ឋកថា កិមិលសូត្រ ទី ៦ មិនមានអដ្ឋកថា ១៣២
អដ្ឋកថា សត្តធម្មសូត្រ ទី ៧ មិនមានអដ្ឋកថា ១៣៣
អដ្ឋកថា មោគ្គល្លានសូត្រ ទី ៨ ១៣៤
អដ្ឋកថា បុញ្ញាភិចាកសូត្រ ទី ៩ ១៤៤
អដ្ឋកថា ភរិយាសូត្រ ទី ១០ ១៤៨
អដ្ឋកថា កោធនាសូត្រ ទី ១១ ១៥២


### មហាវគ្គ ទី ២


អដ្ឋកថា ហិរិសូត្រ ទី ១ ១៥៧
អដ្ឋកថា សុរិយសូត្រ ទី ២ ១៥៨
អដ្ឋកថា នគរោបមសូត្រ ទី ៣ ១៦៥
អដ្ឋកថា ធម្មញ្ញូសូត្រ ទី ៤ ១៧៤
អដ្ឋកថា ចារិច្ឆត្តកសូត្រ ទី ៥ ១៧៦

អដ្ឋកថា សក្កច្ចសូត្រ ទី ៦ ១៩១
អដ្ឋកថា ភាវនាសូត្រ ទី ៧ ១៩២
អដ្ឋកថា អគ្គិខន្ធូបមសូត្រ ទី ៨ ១៩២
អដ្ឋកថា សុនេត្តអនុសាសនីសូត្រ ទី ៩ មិនមានអដ្ឋកថា ១៩៤
អដ្ឋកថា អរកាអនុសាសនីសូត្រ ទី ១០ ១៩៥


## វិនយវគ្គ ទី ៣


អដ្ឋកថា បឋមវិនយធរសូត្រ ទី ១ ១៩៦
អដ្ឋកថា ទុតិយវិនយធរសូត្រ ទី ២ ១៩៧
អដ្ឋកថា តតិយវិនយធរសូត្រ ទី ៣ ១៩៨
អដ្ឋកថា ចតុត្ថវិនយធរសូត្រ ទី ៤ មិនមានអដ្ឋកថា ១៩៩
អដ្ឋកថា បឋមវិនយ....សូត្រ ទី ៥ មិនមានអដ្ឋកថា ២០០
អដ្ឋកថា ទុតិយវិនយ...សូត្រ ទី ៦ មិនមានអដ្ឋកថា ២០១
អដ្ឋកថា តតិយវិនយ...សូត្រ ទី ៧ មិនមានអដ្ឋកថា ២០២
អដ្ឋកថា ចតុត្ថវិនយ....សូត្រ ទី ៨ មិនមានអដ្ឋកថា ២០៣
អដ្ឋកថា សត្ថុសាសនសូត្រ ទី ៩ មិនមានអដ្ឋកថា ២០៤
អដ្ឋកថា អធិករណសមថសូត្រ ទី ១០ ២០៦


## ព្រះសូត្រមិនសង្គ្រោះចូលក្នុងវគ្គ


អដ្ឋកថា ព្រះសូត្រមិនសង្គ្រោះចូលក្នុងវគ្គ ២០៨

សូមនមស្ការចំពោះព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ

# អង្គុត្តរនិកាយសត្តកនិបាត

## បឋមបណ្ណាសកៈ

## ធនវគ្គវណ្ណនាទី ១

## អដ្ឋកថា បឋមបិយសូត្រទី ១

*អ្នកប្រកបដោយធម៌ជាទីស្រឡាញ់*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបិយសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា* *អនវញ្ញត្តិកាមោ (មិនចង់ឲ្យគេមើលងាយខ្លួន)* បាន *ដល់ ជាអ្នកប្រាថ្នាដើម្បីជាអ្នកមានកេរ្តិ៍ឈ្មោះ ។*

ចប់អដ្ឋកថា អប្បិយសូត្រទី ១

# អដ្ឋកថា ទុតិយអប្បិយសូត្រទី ២

*(អ្នកប្រែកបដោយធម៌ជាទីស្រឡាញ់)*

[២] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ទុតិយអប្បិយសូត្រទី ២

# អដ្ឋកថា បឋមពលសូត្រទី ៣

## *ពលៈ ៧ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមពលសូត្រទី ៣ ដូចតទៅនេះ ៖*

*[៣] បទថា **យោនិសោ វិចិនេ ធម្មំ** (ពិចារណាធម៌ដោយឧបាយ) បានដល់ រមែងពិចារណាធម៌ គឺ សច្ចៈ ៤ ដោយឧបាយ ។ បទថា **បញ្ញាយត្ថំ វិបស្សតិ** (តែងឃើញច្បាស់នូវអត្ថដោយបញ្ញាបាន) បានដល់ រមែងឃើញសច្ចធម៌ដោយបញ្ញា ដែលសម្បយុត្តដោយមគ្គព្រមទាំងវិបស្សនា ។ បទថា **បជ្ជោតស្សេវ** (ដូចជាការរលត់នៃប្រទីប) បានដល់ ដូចជាការរលត់នៃប្រទីបដូច្នោះ ។ បទថា **វិមោក្ខោ ហោតិ ចេតសោ** (ការរួចផុតចាកអារម្មណ៍នៃចិត្ត) បានដល់ ចរិមកចិត្ត ចិត្តដួងចុងក្រោយរបស់ព្រះខីណាស្រពនោះ ដែលប្រកបដោយពលៈទាំងនេះ រមែងរួចផុតចាកវត្ថុនិងអារម្មណ៍ ដូចជាការរលត់ទៅនៃដួងប្រទីបដូច្នោះ គឺ រមែងមិនប្រាកដស្ថានទីទៅ ។*

ចប់អដ្ឋកថា បឋមពលសូត្រទី ៣

# អដ្ឋកថា ទុតិយពលសូត្រទី ៤

## ពោលដោយពលៈ ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយពលសូត្រទី ៤ ដូចតទៅនេះ ៖*

[៤] *បទថា* ***សទ្ធោ ហោតិ*** *(ជាអ្នកមានសទ្ធា) បានពណ៌នាទុក ហើយក្នុងបញ្ចកនិបាតនោះឯង ។*

ចប់អដ្ឋកថា ទុតិយពលសូត្រទី ៤

# អដ្ឋកថា បឋមធនសូត្រទី ៥

## ទ្រព្យ ៧ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមធនសូត្រទី ៥ ដូចតទៅនេះ ៖*

[៥] *បទថា* ធនានិ *(ទ្រព្យ) បានដល់ ឈ្មោះថា ទ្រព្យ ដោយអត្ថថា ព្រោះធ្វើមិនឲ្យក្រលំបាក ។*

ចប់អដ្ឋកថា បឋមធនសូត្រទី ៥

# អដ្ឋកថា ទុតិយធនសូត្រទី ៦

*ពោលដោយទ្រព្យ ៧ ប្រការ*

[៦] *សូត្រទី ៦ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា ទុតិយធនសូត្រទី ៦

# អដ្ឋកថា ឧគ្គសូត្រទី ៧

## (ត្រាស់ទ្រព្យ ៧ ប្រការ ដល់ឧគ្គអាមាត្យ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧគ្គសូត្រទី ៧ ដូចតទៅនេះ ៖

[៧] បទថា **ឧគ្គោ រាជមហាមត្តោ (មហាអាមាត្យរបស់ព្រះរាជាឈ្មោះថាឧគ្គៈ)** បានដល់ មហាមាត្យរបស់ព្រះបាទបសេនទិកោសល ។ បទថា **ឧបសង្កមិ (បានចូលទៅគាល់)** បានដល់ ជាអ្នកបរិភោគអាហារព្រឹកស្រេចហើយ ទើបចូលទៅគាល់ ។

បទថា **អឌ្ឍោ (ស្តុកស្តម្ភ)** បានដល់ ជាអ្នកស្តុកស្តម្ភ ព្រោះទ្រព្យដែលបានរក្សាទុក ។ បទថា **មិគារោ រោហណេយ្យោ (មិគារសេដ្ឋីជាចៅរបស់រោហណសេដ្ឋី)** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកមិគារសេដ្ឋីជាចៅរបស់រោហណសេដ្ឋី ។ បទថា **មហទ្ធនោ (ជាអ្នកមានទ្រព្យច្រើន)** បានដល់ ជាអ្នកមានទ្រព្យច្រើន ដោយទ្រព្យសម្រាប់ប្រើប្រាស់ ។ បទថា **មហាភោគោ (មានភោគៈច្រើន)** បានដល់ ជាអ្នកមានភោគៈច្រើន ព្រោះមានឧបភោគៈ បរិភោគៈច្រើន ។ បទថា **ហិរញ្ញស្ស (មាស)** បានដល់

មាសនោះឯង ។ ពិតហើយ ចំពោះមាសរបស់សេដ្ឋីនោះ រាប់បានចំនួនដោយកោដិ ។ បទថា *រូបិយស្ស* (ប្រាក់) បានដល់ ពោលចំពោះគ្រឿងប្រើប្រាស់ ដូចជាទីដេក កម្រាលទន់ៗ ផ្តិល គ្រឿងក្រាល និងគ្រឿងស្លៀកដណ្តប់ជាដើម ប្រមាណមិនបានឡើយ ។

ចប់អដ្ឋកថា ឧគ្គសូត្រទី ៧

# អដ្ឋកថា សញ្ញោជនសូត្រទី ៨

## ពោលដោយសញ្ញោជនៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញោជនៈសូត្រទី ៨ ដូចតទៅនេះ ៖*

[៨] *បទថា* ***អនុនយសញ្ញោជនំ*** *(សញ្ញោជនៈ គឺ សេចក្តីត្រេកអរ) បានដល់ កាមរាគសញ្ញោជនៈ ។ ពិតហើយ សញ្ញោជនៈទាំងអស់នេះឯង គប្បីជ្រាបថា សញ្ញោជនៈ ដោយអត្ថថា ជាគ្រឿងចង ។ ក្នុងសូត្រទីនេះ ព្រះមានព្រះភាគត្រាស់ចំពោះវដ្តៈតែម្យ៉ាង ។ បទដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា សញ្ញោជនៈសូត្រទី ៨

# អដ្ឋកថា បហានសូត្រទី ៩

## *ការលះសញ្ញោជនៈ*

[៩] *សូត្រទី ៩ លោកមិនមានអធិប្បាយទុកទេ ។*

ចប់អដ្ឋកថា បហានសូត្រទី ៩

# អដ្ឋកថា មច្ឆរិយសូត្រទី ១០

*សេចក្តីកំណាញ់*

[១០] *សូត្រទី ១០ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា មច្ឆរិយសូត្រទី ១០

## ចប់ធនវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៦ សូត្រ

# អនុសយវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមអនុសយសូត្រទី ១

*ពោលដោយអនុស័យ ៧*

[១១] *ក្នុងសូត្រទី ១ នេះ មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា បឋមអនុសយសូត្រទី ១

# អដ្ឋកថាទុតិយអានុសយសូត្រទី២

*ពោលដោយអនុស័យ ៧*

[១២] *សូត្រទី ២ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា ទុតិយអនុសយសូត្រទី ២

# អដ្ឋកថា កុលសូត្រទី ៣

## ត្រកូលដែលគួរចូលទៅ និងមិនគួរចូលទៅ

គប្បីជ្រាបវិនិច្ឆ័យក្នុង កុលសូត្រទី ៣ ដូចតទៅនេះ៖

[១៣] បទថា **នាលំ** (មិនគួរ) បានដល់ មិនសមគួរ គឺ មិនសមគួរ ។ បទថា **ន មនាបេន** (ដោយមិនពេញចិត្ត) បានដល់ ក្រោកចាកអាសនៈដែលខ្លួនអង្គុយដោយអាការមិនធ្លាប់ពេញចិត្ត គឺ សំដែងអាការមិនពេញចិត្តនោះឯង ។ បទថា **សន្តមស្ស បរិគូហន្តិ** (លាក់ទុកនូវរបស់ដែលមានហើយ) បានដល់ រមែងលាក់ទុក គឺ រមែងបិទបាំងទេយ្យធម៌សូម្បីដែលមានដល់ភិក្ខុនោះ ។ បទថា **អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ** (ឲ្យដោយមិនគោរព មិនឲ្យដោយគោរព) បានដល់ មិនថានឹងវត្ថុជាសៅហ្មងឬប្រណីតក៏ដោយ មិនឲ្យដោយដៃរបស់ខ្លួន គឺ ឲ្យដោយអាការមិនកោតក្រែង រមែងមិនឲ្យដោយអាការកោតក្រែង ។

ចប់អដ្ឋកថា កុសលសូត្រទី ៣

# អដ្ឋកថា បុគ្គលសូត្រទី ៤

## *បុគ្គល ៧ ពួក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុគ្គលសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *បទថា* ***ឧភតោភាគវិមុត្តោ (ឧភតោភាគវិមុត្តិ)*** *បានដល់រូបផុតហើយដោយចំណែកទាំង ២ ។ អធិប្បាយថា រូបផុតហើយចាករូប-កាយដោយអរូបសមាបត្តិ និងរូបផុតហើយចាកនាមកាយដោយមគ្គ ។ ឧភតោភាគវិមុត្តិនោះ មាន ៥ ពួក គឺ បុគ្គលអ្នកចេញចាកអរូបសមាបត្តិ ៤ សមាបត្តិណាមួយ ពិចារណាសង្ខារទាំងឡាយ ហើយសម្រេចព្រះអរហត្ត ៤ ពួក និងព្រះអនាគាមីអ្នកចេញចាកនិរោធហើយ សម្រេចអរហត្ត ១ ពួក ។ តែបាលីក្នុងព្រះសូត្រនេះ មកហើយដោយអំណាចអ្នកបានវិមោក្ខ ៨ ដោយនាមកាយហើយ អាសវៈរបស់បុគ្គលនោះរមែងអស់ទៅ ព្រោះឃើញសូម្បីដោយបញ្ញា ។*

*បុគ្គលឈ្មោះថា* ***បញ្ញាវិមុត្តោ (បញ្ញាវិមុត្តិ)*** *ព្រោះអត្ថថា រូបផុត*

ដោយបញ្ញា ។ បញ្ញាវិមុត្តិបុគ្គលនោះ មាន ៥ ពួក បានដល់ បុគ្គលទាំងនេះ គឺ ព្រះអរហន្តសុក្ខវិបស្សកៈ ១ ពួក លោកអ្នកចេញចាកឈាន ៤ ហើយសម្រេចព្រះអរហន្ត ៤ ពួក ។ តែបាលីក្នុងសូត្រនេះ មកហើយដោយបដិសេធវិមោក្ខ ៨ ដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា ពិតហើយ បុគ្គលមិនបានពាល់ត្រូវវិមោក្ខ ៨ ដោយនាមកាយ អាសវៈទាំងឡាយរបស់លោករមែងអស់ទៅ ព្រោះឃើញដោយបញ្ញា បុគ្គលនេះហៅថា បញ្ញាវិមុត្តិ (រួចផុតហើយដោយបញ្ញា) ។

បុគ្គលឈ្មោះថា កាយសក្ខី (កាយសក្ខិ) ព្រោះអត្ថថា ធ្វើឲ្យជាក់ច្បាស់ដល់ទីបំផុតនៃវិមោក្ខ ដែលខ្លួនពាល់ត្រូវហើយដោយនាមកាយ ។ កាយសក្ខីបុគ្គលនោះ រមែងពាល់ត្រូវឈានមុន រមែងធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺ ព្រះនិព្វានក្នុងកាលខាងក្រោយ ។ កាយសក្ខីបុគ្គលនោះរាប់តាំងពីព្រះអរិយបុគ្គលអ្នកតាំងនូវក្នុងសោតាបត្តិផល រហូតដល់ព្រះអរិយ-បុគ្គលដែលតាំងនូវក្នុងអរហត្តមគ្គ រួមជា ៦ ពួក ។ ព្រោះហេតុនោះ លោកទើបពោលទុកថា "បុគ្គលពួកខ្លះក្នុងព្រះសាសនានេះ ពាល់ត្រូវវិមោក្ខ

៨ ដោយនាមកាយ អាសវៈពួកខ្លះរបស់បុគ្គលនោះរមែងអស់ទៅ ព្រោះឃើញដោយបញ្ញា បុគ្គលនេះហៅថា កាយសក្ខី (ឃើញវិមោក្ខដោយនាម-កាយ) ។

បទថា ទិដ្ឋិប្បត្តោ (ទិដ្ឋិប្បត្តៈ) ព្រោះអត្ថថា ដល់អរិយសច្ចធម៌ដែលខ្លួនឃើញហើយ ។ ក្នុងទិដ្ឋិប្បត្តបុគ្គលនោះ មានលក្ខណៈសង្ខេបដូចតទៅនេះ បុគ្គលឈ្មោះថា ទិដ្ឋិប្បត្តៈ ព្រោះដឹង ឃើញ ដឹងច្បាស់ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវដោយបញ្ញាថា "សង្ខារទាំងឡាយជាទុក្ខ ការរលត់សង្ខារជាសុខ" តែពោលដោយពិស្តារ សូម្បីបុគ្គលនោះ ក៏មាន ៦ពួក ដូចកាយសក្ខីបុគ្គលដែរ ។ ព្រោះហេតុនោះឯង លោកទើបពោលថា "បុគ្គលពួកខ្លះក្នុងសាសនានេះ រមែងដឹងជាក់ច្បាស់តាមសេចក្ដីពិតថា នេះទុក្ខ ។ល។ រមែងដឹងជាក់ច្បាស់តាមសេចក្ដីពិតថា នេះបដិបទាជាគ្រឿងញុំាងសត្វឲ្យដល់នូវសេចក្ដីរលត់ទុក្ខ និងធម៌ទាំងឡាយដែលព្រះតថាគតប្រកាសហើយ ដែលខ្លួនឃើញហើយដោយបញ្ញា ដែលខ្លួនប្រព្រឹត្តហើយដោយបញ្ញា ។ល។ បុគ្គលនេះហៅថា ទិដ្ឋិប្បត្តៈ (អ្នកដល់អរិយសច្ចៈដែល

ខ្ញុំនឃើញហើយ)" ។

បុគ្គលឈ្មោះថា **សទ្ធាវិមុត្តោ** (សទ្ធាវិមុត្ត) ព្រោះរួចផុតដោយសទ្ធា សទ្ធាវិមុត្តបុគ្គលសូម្បីនោះ ក៏មាន ៦ ពួក ដោយន័យដូចពោលហើយនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា បុគ្គលពួកខ្លះក្នុងសាសនានេះ រមែងដឹងជាក់ច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។ល។ រមែងដឹងជាក់ច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាគ្រឿងឲ្យដល់នូវការរលត់ទុក្ខ និងធម៌ដែលព្រះតថាគតប្រកាសហើយ ដែលខ្ញុំនឃើញហើយដោយបញ្ញា ដែលខ្ញុំនប្រព្រឹត្តហើយដោយបញ្ញា ។ល។ បុគ្គលនេះហៅថា សទ្ធាវិមុត្ត (រួចផុតដោយសទ្ធា) តែថា មិនដូចការរួចផុតទុក្ខរបស់ទិដ្ឋិប្បត្តបុគ្គល ។ ព្រោះថា ការអស់កិលេសរបស់សទ្ធាវិមុត្តបុគ្គលនេះ ដូចការអស់កិលេសរបស់បុគ្គលអ្នកជឿ បាក់ចិត្តជឿ នឹងបង្អោនចិត្តជឿ ក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម ដូច្នោះ ញាណដែលជាគ្រឿងកាត់កិលេសក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម របស់ទិដ្ឋិប្បត្តបុគ្គល ជាញាណមិនយឺតយូរ ចាស់ក្លា មុតស្រួច ទើបកាត់កិលេសទៅបានរហ័ស

ព្រោះដូចបុគ្គលប្រើកាំបិតដែលមិនមុតកាត់ដើមចេក ស្នាមកាត់ដើមចេករមែងមិនត្រឹមល្អ កាំបិតក៏មិនកាត់ទៅបានដោយឆាប់រហ័ស នៅឮសំឡេងខ្លាំង ត្រូវប្រើសេចក្ដីព្យាយាមខ្លាំង យ៉ាងណា មគ្គការនាដែលជាចំណែកខាងដើមរបស់សទ្ធាវិមុត្តបុគ្គល ក៏គប្បីជ្រាបដូច្នោះ តែកាលបុគ្គលយកកាំបិតដ៏មុតល្អហើយកាត់ដើមចេក ស្នាមកាត់ដើមចេករមែងត្រឹមល្អ កាំបិតរមែងកាត់បានរហ័ស មិនបានឮសំឡេង មិនត្រូវប្រើសេចក្ដីព្យាយាមច្រើន យ៉ាងណា មគ្គការនាដែលជាចំណែកខាងដើម របស់បញ្ញាវិមុត្តិបុគ្គល ក៏គប្បីជ្រាបដូច្នោះដូចគ្នា ។

បុគ្គលឈ្មោះថា **ធម្មានុសារី** ព្រោះអត្ថថា តាមរលឹកដល់ធម៌ ។ បញ្ញា ឈ្មោះថា ធម៌ ។ អធិប្បាយថា បុគ្គលរមែងចម្រើនមគ្គដែលមានបញ្ញាដែលជាគ្រឿងនាំ ។ សូម្បីក្នុងបុគ្គលជា **សទ្ធានុសារី** ក៏ន័យនេះដូចគ្នា ។ បុគ្គលទាំង ២ នោះ ក៏គឺ បុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គនោះឯង ។ សមពិតដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា កាលបុគ្គលណាបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ដោយសោតាបត្តិផល បញ្ញិន្ទ្រីយ៍

រមែងមានចំនួនច្រើន បុគ្គលនោះឈ្មោះថា រមែងចម្រើនអរិយមគ្គ ដែលមានបញ្ញាគ្រឿងនាំ បុគ្គលនេះ ហៅថា ធម្មានុសារី ។ ក្នុងធម្មានុសារីនេះ មានសេចក្ដីសង្ខេបត្រឹមតែប៉ុណ្ណេះ ។ តែពោលដោយពិស្ដារ កថាពោលដោយឧភតោភាគវិមុត្តិបុគ្គលជាដើមនេះ ក៏ពោលទុកហើយក្នុងអធិការពោលដោយការចម្រើនបញ្ញា ក្នុងបករណ៍វិសុទ្ធិមគ្គ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយក្នុងបករណ៍វិសុទ្ធិមគ្គនោះចុះ ។

ចប់អដ្ឋកថា បុគ្គលសូត្រទី ៨

# អដ្ឋកថាឧទកូបមសូត្រទី៥

## ព្រះមានព្រះភាគប្រៀបដូចបុគ្គលអ្នកមុជទឹក

គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧទកូបមសូត្រទី ៥ ដូចតទៅនេះ ៖

[១៥] បទថា **ឧទកូបមា** (ប្រៀបដូចអ្នកមុជទឹក) បានដល់ ព្រះពុទ្ធទ្រង់ប្រៀបដូចបុគ្គលអ្នកមុជទឹក ដោយការកាន់យកអាការ មានការមុជចុះជាដើម ។ បទថា **សកឹ និមុគ្គោ** (មុជបាត់ទៅតែម្តង) បានដល់ មុជចុះទៅតែម្យ៉ាង ។ បទថា **ឯកន្តកាឡកេហិ** (ខ្មៅសុទ្ធ) ព្រះអង្គត្រាស់សំដៅដល់និយតមិច្ឆាទិដ្ឋិ ។ បទថា **ឧម្មុជ្ជតិ** (ងើបឡើង) បានដល់ ងើបឡើង ។ បទថា **សាធុ** (ជាការល្អ) បានដល់ ល្អ គឺ ចម្រើន ។ បទថា **ហាយ-តិយេវ** (មានតែសាបសូន្យទៅវិញ) បានដល់ រមែងសាបសូន្យទៅតែម្យ៉ាងដូចទឹក ដែលបុគ្គលចាក់ចុះក្នុងប្រដាប់ត្រងទឹកដូច្នោះ ។ បទថា **ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ** (ងើបឡើង ហើយក្រឡេករមិលមើល) បានដល់ បុគ្គលដែលងើបឡើងមក ហើយពិចារណាក្រឡេករមិលមើលទិសដែលគួរទៅ ឈ្មោះថា ធ្ងន់ទៅ ។

បទថា **បតរតិ (ឆ្លងទៅ)** បានដល់ សំដៅត្រង់ទិសដែលគួរទៅ ឈ្មោះថា ឆ្លងទៅ ។ បទថា **បតិគាធប្បត្តោ (ដល់នូវទីពឹង)** បានដល់ បុគ្គលងើបឡើងមក ហើយក្រឡេកមើលឆ្លងទៅបាន ឈ្មោះថា រមែងប្រសព្វនូវទីពឹងក្នុងកន្លែងមួយ រមែងតាំងនៅ មិនវិលត្រឡប់ទៀត ។ បទថា **តិណ្ណោ បារគតោ ថលេ តិដ្ឋតិ (ងើបឡើង ឆ្លងទៅដល់ត្រើយនាយ ហើយឈរនៅលើគោក)** បានដល់ បុគ្គលឆ្លងអន្លង់ទឹក គឺ កិលេសទាំងពួង ដល់ត្រើយនាយហើយ ឈ្មោះថា រមែងជា អ្នកឈរលើច្រាំង គឺ ព្រះនិព្វាន ។ ព្រះមានព្រះភាគត្រាស់ទាំងវដ្តៈ និងវិវដ្តៈទុកក្នុងសូត្រនេះ ។

ចប់អដ្ឋកថា ឧទកូបមសូត្រទី ៥

# អដ្ឋកថា អនិច្ចានុបស្សីសូត្រទី ៦

## *ការពិចារណាឃើញសេចក្ដីមិនទៀងក្នុងសង្ខារ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនិច្ចានុបស្សីសូត្រទី ៦ ដូចតទៅនេះ ៖*

[១៦] *បទថា* ***អនិច្ចានុបស្សី*** *(ពិចារណាឃើញថាមិនទៀង) ព្រោះអត្ថថា តាមឃើញដោយបញ្ញាយ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង បុគ្គលឈ្មោះថា* ***អនិច្ចសញ្ញី*** *(មានសេចក្ដីសំគាល់ថាមិនទៀង) ព្រោះអត្ថថា មានសេចក្ដីសំគាល់យ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង បុគ្គលឈ្មោះថា* ***អនិច្ចប្បដិសំវេទី*** *(ដឹងច្បាស់ថាមិនទៀង) ព្រោះអត្ថថា ដឹងដោយញាណ (បញ្ញា) យ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង ។ បទថា* ***សតតំ*** ***(ជាប់តគ្នាទៅ)*** *បានដល់ គ្រប់កាល ។ បទថា* ***សមិតំ*** ***(តរៀងគ្នា)*** *បានដល់ ចិត្តដួងខាងក្រោយតជាប់គ្នាហើយ គឺ បន្តគ្នា ជាប់តជាមួយចិត្តដួងមុន យ៉ាងណា ក៏តជាប់គ្នាទៅយ៉ាងនោះ ។ បទថា* ***អព្វោកិណ្ណំ*** ***(មិនដាច់)*** *បានដល់ តជាប់គ្នាមិនដាច់ខ្សែ គឺ មិនលាយឡំដោយចិត្តដទៃ ។ បទថា* ***ចេតសា អធិមុច្ចមានោ*** ***(តាំងចិត្តមាំ)*** *បានដល់ ព្រមព្រៀងនៃចិត្ត ។ បទថា*

បញ្ញាយ បរិយោគាហមានោ (ស្ទង់មើលដោយបញ្ញារឿយៗ) បានដល់ តាមចូលទៅដឹងដោយវិបស្សនាញាណ ។

បទថា **អបុព្វំ អចរិមំ** (ដំណាលគ្នាតែម្តង) បានដល់ មិនមុន មិនក្រោយ គឺ ក្នុងខណៈជាមួយគ្នានោះឯង ។ ព្រះមានព្រះភាគត្រាស់ សមសីសីបុគ្គលទុកក្នុងព្រះសូត្រនេះ ។ សមសីសីបុគ្គលនោះមាន ៤ ពួក គឺ រោគសមសីសី វេទនាសមសីសី ឥរិយាបថសមសីសី និងជីវិត-សមសីសី ។ បណ្តាបុគ្គល ៤ ពួកនោះ បុគ្គលណាត្រូវរោគណាមួយ ពាល់ត្រូវហើយ រោគស្ងប់រម្ងាប់ និងអាសវៈអស់ទៅ ដោយគ្រាតែមួយ នោះឯង បុគ្គលនេះឈ្មោះថា **រោគសមសីសី** ។ ចំណែកបុគ្គលណា សោយវេទនាណាមួយ វេទនាស្ងប់រម្ងាប់ និងអាសវៈអស់ទៅ ក្នុងគ្រាតែ មួយនោះឯង បុគ្គលនេះឈ្មោះថា **វេទនាសមសីសី** ។ ចំណែកបុគ្គល ណា ព្រមព្រៀងដោយឥរិយាបថណាមួយ មានការឈរជាដើម ឃើញ ច្បាស់ ឥរិយាបថក៏ដល់ទីបំផុត អាសវៈក៏អស់ទៅ ក្នុងខណៈតែមួយនោះ ឯង បុគ្គលនេះឈ្មោះថា **ឥរិយាបថសមសីសី** ។ ចំណែកបុគ្គលណាមាន

ជីវិតអស់ទៅ ហើយអាសវៈក៏អស់ទៅ ក្នុងខណៈតែមួយនោះឯង ដោយសេចក្តីព្យាយាម (របស់ខ្លួន ឬរបស់អ្នកដទៃ) ឬដោយសភាវៈ (អស់អាយុ) បុគ្គលនេះឈ្មោះថា **ជីវិតសមសីសី** ។ ជីវិតសមសីសីបុគ្គលនេះ ព្រះអង្គទ្រង់បំណងយកក្នុងសូត្រនេះ ។ ក្នុងជីវិតសមសីសីបុគ្គលនោះ មានការអធិប្បាយថា ការអស់ទៅនៃអាសវៈរមែងមានដោយមគ្គចិត្ត ការដល់ទីបំផុតនៃជីវិតរមែងមានដោយចុតិចិត្ត ឈ្មោះថា ការកើតព្រមនៃធម៌ដែលអស់អាសវៈ និងការដល់ទីបំផុតនៃជីវិត ទាំង ២ យ៉ាង រមែងមានក្នុងខណៈតែមួយមិនបានក៏ពិត តែថា ព្រោះហេតុដែលល្មមអាសវៈរបស់ជីវិតសមសីសីបុគ្គលនោះអស់ទៅ ការដល់ទីបំផុតនៃជីវិតក៏មកដល់ក្នុងលំដាប់វារៈនៃបច្ចវេក្ខណៈនោះឯង មិនប្រាកដចន្លោះ ដូច្នោះ លោកទើបពោលយ៉ាងនេះ ។

បទថា **អន្តរាបរិនិព្វាយី** (អន្តរាបរិនិព្វាយី) នេះ ជាឈ្មោះរបស់ព្រះអនាគាមិបុគ្គលអ្នកកើតក្នុងភូមិណាមួយ ក្នុងបណ្តាសុទ្ធាវាសភូមិទាំង ៥ បានសម្រេចព្រះអរហន្តក្នុងខណៈដែលកើត ឬធ្លងទៅបន្តិច ទើបបាន

សម្រេច ឬតាំងនៅពាក់កណ្ដាលអាយុ ក៏បានសម្រេច ។ បទថា **ឧប-ហច្ចបរិនិព្វាយី (ឧបហច្ចបរិនិព្វាយី)** នេះ ជាឈ្មោះរបស់ព្រះអនាគាមិ-បុគ្គលដែលកន្លងហួសពាក់កណ្ដាលអាយុហើយ ទើបសម្រេចព្រះអរហត្ត ក្នុងសុទ្ធាវាសភូមិនោះឯង ។ បទថា **អសង្ខារបរិនិព្វាយី (អសង្ខារ-បរិនិព្វាយី)** នេះ ជាឈ្មោះរបស់បណ្ដាព្រះអនាគាមីទាំងនោះ ព្រះអនា-គាមិបុគ្គលដែលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយមិនត្រូវការប្រឹងប្រែង ដោយមិនត្រូវការធ្វើសេចក្ដីព្យាយាម ។ បទថា **សង្ខារបរិនិព្វាយី (សង្ខា-របរិនិព្វាយី)** នេះ ជាឈ្មោះរបស់ព្រះអនាគាមិបុគ្គល ដែលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ព្រោះត្រូវមានអ្នកដាស់តឿន ត្រូវមានសេចក្ដីព្យាយាម ។ បទថា **ឧទ្ធំសោតោ អកនិដ្ឋគាមី (ឧទ្ធំសោតអកនិដ្ឋគាមី)** នេះ ជាឈ្មោះរបស់ព្រះអនាគាមិបុគ្គលដែលកើតក្នុងសុទ្ធាវាសភូមិជាន់ទាប ៤ ជាន់ណាមួយ ចុតិចាកភូមិនោះហើយ កើតដោយលំដាប់រហូតដល់អកនិដ្ឋភូមិ ហើយសម្រេចព្រះអរហន្ត ។

ចប់អដ្ឋកថា អនិច្ចានុបស្សីសូត្រទី ៦

# អដ្ឋកថា ទុក្ខានុបស្សីសូត្រទី ៧

## *ការពិចារណាឃើញភាពជាទុក្ខក្នុងសង្ខារ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុក្ខានុបស្សីសូត្រទី ៧ ដូចតទៅនេះ ៖*

[១៧] *បទថា ទុក្ខានុបស្សី (ពិចារណាឃើញថាជាទុក្ខ) បានដល់ បុគ្គលតាមឃើញអាការ គឺ ការបៀតបៀន ដោយសភាពជាទុក្ខ ។*

ចប់អដ្ឋកថា ទុក្ខានុបស្សីសូត្រទី ៧

# អដ្ឋកថា អនត្តានុបស្សីសូត្រទី ៨

## ការពិចារណាឃើញថាជាអនត្តាក្នុងធម៌

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនត្តានុបស្សីសូត្រទី ៨ ដូចតទៅនេះ ៖*

[១៧] *បទថា* ***អនត្តានុបស្សី*** *(ពិចារណាឃើញថាជាអនត្តា) បាន ដល់ បុគ្គលតាមឃើញអាការ គឺ ការមិនប្រព្រឹត្តទៅក្នុងអំណាចថា ធម៌ ទាំងឡាយជាអនត្តា ដូច្នេះ ។*

ចប់អដ្ឋកថា អនត្តានុបស្សីសូត្រទី ៨

# អដ្ឋកថា និព្វានសូត្រទី ៩

## *ដោយអំពីព្រះនិព្វាន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វានសូត្រទី ៩ ដូចតទៅនេះ ៖*

[១៧] *បទថា* ***សុខានុបស្សី*** *(ពិចារណាឃើញថាជាសុខ) បានដល់ បុគ្គលតាមឃើញដោយញាណ (បញ្ញា) យ៉ាងនេះថា ព្រះនិព្វានជាសុខ ។*

ចប់អដ្ឋកថា អនត្តានុបស្សីសូត្រទី ៩

# អដ្ឋកថា និទ្ទសវត្ថុសូត្រទី ១០

## មានអាយុមិនដល់ ១០ ឆ្នាំ

*គប្បីជ្រាបវិនិច្ឆ័យក្នុង និទ្ទសវត្ថុសូត្រទី ១០ ដូចតទៅនេះ៖*

*[១៨] បទថា **និទ្ទសវត្ថុ** បានដល់ ធម៌ជាហេតុឲ្យមានអាយុមិនដល់ ១០ ឆ្នាំជាដើម គឺ មានហេតុឲ្យពោលយ៉ាងនេះថា ភិក្ខុជាអ្នកមានអាយុមិនដល់ ១០ មិនដល់ ២០ ឆ្នាំ មិនដល់ ៣០ ឆ្នាំ មិនដល់ ៤០ ឆ្នាំ មិនដល់ ៥០ ឆ្នាំ ដូច្នេះ ។ បានឮថា បញ្ហានេះកើតឡើងក្នុងលទ្ធិតិរ្ថិយ ។ ពិតហើយ ពួកតិរ្ថិយហៅនិគ្រន្ថដែលស្លាប់ក្នុងវេលាអាយុគ្រប់ ១០ ឆ្នាំ ថា និទ្ទសៈ (អ្នកមានអាយុមិនដល់ ១០ ឆ្នាំ) ។ ន័យថា និគ្រន្ថនោះនឹងមិនមានអាយុ ១០ ឆ្នាំទៀត ។ មិនមែនត្រឹមតែ ១០ ឆ្នាំ ប៉ុណ្ណោះទេ សូម្បី ៩ ឆ្នាំ សូម្បី ១ ឆ្នាំ ក៏មិនបានដែរ ។ ដោយន័យដូចពោលហើយនេះឯង តិរ្ថិយទាំងឡាយ ទើបហៅនិគ្រន្ថដែលស្លាប់ក្នុងវេលាអាយុគ្រប់ ២០ ឆ្នាំជាដើមថា អាយុមិនដល់ ២០ ឆ្នាំ អាយុមិនដល់ ៣០ ឆ្នាំ អាយុមិនដល់ ៤០ ឆ្នាំ អាយុមិនដល់ ៥០ ឆ្នាំ ។ ព្រះអានន្ទចារិកទៅ*

ក្នុងស្រុក បានស្តាប់ពាក្យដូចពោលនោះ លុះទៅព្រះវិហារហើយ ទើបបាន ក្រាបទូលព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា អានន្ទ នេះមិន មែនជាឈ្មោះរបស់តិរ្ថិយទាំងឡាយទេ តែជាឈ្មោះរបស់ព្រះខីណាស្រព ក្នុងសាសនារបស់តថាគត ។ ពិតណាស់ ព្រះខីណាស្រពដែលបរិនិព្វាន ក្នុងវេលាអាយុ ១០ ឆ្នាំ និងមិនមានអាយុ ១០ ឆ្នាំទៀត មិនមែនត្រឹម តែ ១០ ឆ្នាំប៉ុណ្ណោះទេ សូម្បី ៩ ឆ្នាំ ។ល។ សូម្បី ១ ឆ្នាំក៏មិនមាន មិនមែនត្រឹមតែ ១ ឆ្នាំប៉ុណ្ណោះទេ សូម្បី ១១ ខែ ។ល។ សូម្បី ១ ខែ សូម្បី ត្រឹមតែមួយខណៈ ក៏មិនមានឡើយ ។ ព្រោះហេតុអ្វី ។ ព្រោះមិនមាន បដិសន្ធិទៀត ។ សូម្បីក្នុងបទថា មានអាយុមិនដល់ ២០ ឆ្នាំ ជាដើម ។ ក៏មានន័យនេះដូចគ្នា ។

ដោយប្រការដូច្នេះ ព្រះមានព្រះភាគត្រាស់ថា ពាក្យនោះ ជាឈ្មោះ របស់ព្រះខីណាស្រពក្នុងសាសនារបស់តថាគត ។ ហើយទើបទ្រង់ផ្តើម ព្រះធម្មទេសនានេះ ដើម្បីទ្រង់សំដែងហេតុដែលព្រះខីណាស្រពមានអាយុ មិនដល់ ១០ ឆ្នាំ ប៉ុណ្ណោះ ។ បណ្តាបទទាំងនោះ បទថា ឥធ (ក្នុងធម្ម

វិន័យនេះ) បានដល់ ក្នុងព្រះសាសនានេះ ។ បទថា **សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ** (ជាអ្នកមានសេចក្តីពេញចិត្តដ៏ខ្លាំងក្លាក្នុងការសមាទានសិក្ខា) បានដល់ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការបំពេញសិក្ខា ៣ ឲ្យបរិបូរណ៍ ។ បទថា **អាយតឹ ច សិក្ខាសមាទានេ អវិគតបេមោ** (ជាអ្នកបានសេចក្តីត្រេកអរក្នុងការសមាទានសិក្ខាតទៅ) បានដល់ ក្នុងថ្ងៃស្អែកជាដើម ជាអ្នកប្រកបដោយសេចក្តីត្រេកអរដែលបានហើយក្នុងការបំពេញសិក្ខាឲ្យបរិបូរណ៍ ។ បទថា **ធម្មនិសន្តិយា** (ក្នុងការពិចារណាធម៌) បានដល់ ក្នុងការពិចារណាធម៌ ។ ពាក្យនេះជាឈ្មោះរបស់វិបស្សនា ។ បទថា **ឥច្ឆាវិនយេ** (ក្នុងការកម្ចាត់សេចក្តីប្រាថ្នា) បានដល់ ក្នុងការកំចាត់តណ្ហា ។ បទថា **បដិសល្លានេ** (ក្នុងការគេចចេញ) បានដល់ ក្នុងការនៅតែម្នាក់ឯង ។ បទថា **វិរិយារម្ភេ** (ការប្រារព្ធសេចក្តីព្យាយាម) បានដល់ ក្នុងការបំពេញសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **សតិនេបក្កេ** (ក្នុងសតិនិងបញ្ញាជាគ្រឿងរក្សាខ្លួន) បានដល់ ទាំងក្នុងសតិ និងក្នុងការមានបញ្ញាជាគ្រឿងរក្សាខ្លួន ។ បទថា **ទិដ្ឋិប្បដិវេធេ** (ក្នុងការចាក់ធ្លុះដោយទិដ្ឋិ)

*បានដល់ ក្នុងការឃើញមគ្គ ។ បទដ៏សេសក្នុងទីទាំងពួងងាយហើយ ។*

ចប់អដ្ឋកថា និទ្ទសវត្ថុសូត្រទី ១០

## ចប់អនុសយវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ០៨ សូត្រ

# វជ្ជីវគ្គវណ្ណនាទី ៣

## អដ្ឋកថា សារន្ទទសូត្រទី ១

### ត្រាស់អបរិហានិយធម៌ត្រង់សារន្ទទចេតិយ

គប្បីជ្រាបវិនិច្ឆ័យក្នុង សារន្ទទចេតិយសូត្រទី ១ ដូចតទៅនេះ ៖

[១៩] បទថា ***សារន្ទទេ ចេតិយេ*** (ក្នុងសារន្ទទចេតិយ) បានដល់ក្នុងវិហារមានឈ្មោះយ៉ាងនោះ ។ បានឮថា កាលព្រះតថាគតស្តេចមិនទាន់ឧប្បត្តិឡើង ទីនៅរបស់យក្សឈ្មោះសារន្ទទៈ បានក្លាយជាចេតិយ ។ គ្រានោះ ជនទាំងឡាយបាននាំគ្នាសាងវិហារថ្វាយព្រះមានព្រះភាគ ត្រង់ចេតិយនោះ ។ វិហារនោះ បានឈ្មោះថា សារន្ទទចេតិយ ។ បទថា ***យាវកីវញ្ច*** (ត្រឹមណា) បានដល់ រហូតអស់កាលត្រឹមណា ។ បទថា ***អភិណ្ហសន្និបាតា*** (មានការប្រជុំគ្នារឿយៗ) បានដល់ ប្រជុំគ្នាមួយថ្ងៃ ៣ ដងក្តី ប្រជុំគ្នាជារយៈៗ ក្តី ឈ្មោះថា ប្រជុំគ្នារឿយៗ ។ បទថា ***សន្និបាត-ពហុលា*** (មានការប្រជុំគ្នាច្រើន) បានដល់ ឈ្មោះថា ប្រជុំគ្នារឿយៗ ព្រោះ

មិនមានការឈប់ ដោយគិតថា ទាំងថ្ងៃម្សិល ទាំងក្នុងថ្ងៃមុនៗ យើងក៏ប្រជុំហើយ ថ្ងៃនេះនឹងប្រជុំគ្នាធ្វើអ្វីទៀត ។ បទថា **វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ (អ្នកដែនវជ្ជីគប្បីប្រាថ្នាសេចក្តីចម្រើនបានជាប្រាកដ មិនគប្បីប្រាថ្នាសេចក្តីវិនាសឡើយ ត្រឹមនោះ)** សេចក្តីថា ស្តេចលិច្ឆវីកាលមិនប្រជុំគ្នារឿយៗ រមែងមិនបានស្តាប់ដំណឹងដែលមកអំពីទិសទាំងឡាយឡើយ តពីនោះ រមែងមិនជ្រាបថា ស្រុកដែនឯណោះ ឬខេត្តដែននិគមឯណោះច្របូកច្របល់ ពួកចោរប្រមូលគ្នានៅក្នុងទីឯណោះ ។ ចំណែកពួកចោរ កាលដឹងថា ស្តេចទាំងឡាយនាំគ្នាប្រមាទហើយ ក៏ចោមវាយស្រុកជាដើម ធ្វើជនបទឲ្យវិនាស ។ សេចក្តីវិនាសរមែងមានដល់ស្តេចទាំងឡាយ ដោយអាការយ៉ាងនេះ ។ តែកាលប្រជុំគ្នារឿយៗ រមែងបានស្តាប់រឿងនោះៗ តពីនោះ ក៏បញ្ជាកងទ័ពទៅច្បាំងជាមួយនឹងសត្រូវ ។ សូម្បីពួកចោរក៏គិតថា ស្តេចទាំងឡាយមិនប្រមាទហើយ ពួកយើងមិនអាចត្រាច់ទៅដោយផ្តុំគ្នាជាពួកៗ បានឡើយ ។ ហើយក៏បែកគ្នាចៀសចេញទៅ ។ ស្តេចទាំងឡាយ ទើបមានសេចក្តីចម្រើនដោយអាការយ៉ាងនេះ ព្រោះហេតុ

នោះ ព្រះមានព្រះភាគទើបត្រាស់ថា អ្នកដែនវជ្ជីគប្បីប្រាថ្នាសេចក្តីចម្រើន បានពិត មិនគប្បីមានសេចក្តីសាបសូន្យឡើយ ត្រឹមនោះ ។

ក្នុងបទថា សមគ្គា (ព្រមព្រៀងគ្នា) ជាដើម មានវិនិច្ឆ័យដូចតទៅនេះ កាលឮសំឡេងស្គរហៅប្រជុំ ពួកស្តេចលិច្ឆវីធ្វើសេចក្តីប្រកែកថា ក្នុងថ្ងៃនេះ យើងមានកិច្ច យើងមានមង្គល ឈ្មោះថា មិនព្រមព្រៀងគ្នាប្រជុំ ។ តែពួកស្តេចលិច្ឆវី ពេលបានស្តាប់សំឡេងស្គរ កំពុងបរិភោគអាហារក្តី កំពុងប្រដាប់ក្តី កំពង់ស្លៀកដណ្តប់ក្តី បរិភោគអាហារបានមួយគ្រា ប្រដាប់ខ្លួនបានពាក់កណ្តាល កំពង់ស្លៀកដណ្តប់ ក៏មកប្រជុំ ឈ្មោះថា រមែងព្រមព្រៀងគ្នាប្រជុំ ។ មួយទៀត ពួកស្តេចលិច្ឆវីប្រជុំគ្នា គិតប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើហើយ តែមិនប្រជុំរួមគ្នា (ប្រជុំគ្នាជាពួកៗ) ឈ្មោះថា មិនលើកការប្រជុំរួមគ្នា ។ ព្រោះថា កាលពួកស្តេចលិច្ឆវីប្រជុំគ្នាដោយអាការយ៉ាងនេះ ពួកស្តេចលិច្ឆវីដែលប្រជុំមុន រមែងមានបរិវិតក្កៈយ៉ាងថា ពួកយើងបានស្តាប់តែរឿងមិនសំខាន់ទាំងនោះ ឥឡូវនេះ នឹងមានរឿងសម្រេចសេចក្តីយ៉ាងណា ។ តែពួកស្តេចលិច្ឆវី កាលប្រជុំព្រមគ្នា ឈ្មោះថា

រមែងជាអ្នកព្រមព្រៀងគ្នាក្នុងការប្រជុំ ។ ម្យ៉ាងទៀត កាលពួកស្ដេចលិច្ឆវី ស្ដាប់ថា ខេត្តដែនស្រុកឯណោះ ឬខេត្តដែនទិគមឯណោះ ប្រឫកប្របល់ ឬពួកចោរប្រមូលគ្នាក្នុងទីឯណោះ កាលមានអ្នកសួមថា នរណានឹងទៅ បង្ក្រាបពួកសត្រូវ ក៏នាំគ្នាពោលថា យើងមុន យើងមុន ឈ្មោះថា ជាអ្នក ព្រមព្រៀងគ្នាប្រជុំ ។ មួយទៀត កាលការងាររបស់ស្ដេចលិច្ឆវីអង្គណាមួយ វិនាស ពួកស្ដេចលិច្ឆវីក្រៅពីនោះ ក៏បញ្ជូនបុត្រ និងបងប្អូនប្រុសទៅជួយ ដល់ការងាររបស់ស្ដេចវជ្ជីនោះ មិនត្រាស់ថា សូមព្រះរាជាចូរស្ដេចទៅកាន់ ដំណាក់របស់ស្ដេចលិច្ឆវីឯណោះ សូមព្រះរាជាចូរស្ដេចទៅកាន់ដំណាក់របស់ ស្ដេចលិច្ឆវីឯណោះ ទាំងអស់ព្រមព្រៀងគ្នាក្រោកទទួលព្រះរាជាដែលជាអា-គន្តុកៈក្ដី កាលមានមង្គល ឬរោគ ឬសុខទុក្ខណាមួយ កើតឡើងដល់ ស្ដេចលិច្ឆវីអង្គណាមួយ ទាំងអស់គ្នាធ្វើរឿងសំឡាញ់នោះឯង ឲ្យដូចជារបស់ ខ្លួន ឈ្មោះថា រមែងព្រមព្រៀងគ្នាធ្វើកិច្ចនៃអ្នកដែនវជ្ជីដែលគួរធ្វើ ។

បទថា អប្បញ្ញត្តំ (វត្ថុដែលមិនបញ្ញត្តិ) ជាដើម មានវិនិច្ឆ័យដូចត ទៅនេះ ពួកស្ដេចលិច្ឆវីកាលឲ្យរក្សាសួយ ឬភាសី ឬតម្លៃណាដែលមិនបាន

ធ្វើទុកក្នុងកាលមុន ឈ្មោះថា រមែងបញ្ញត្តវត្ថុដែលមិនទាន់បានបញ្ញត្ត ។ មួយទៀត ពួកស្តេចលិច្ឆវី កាលមិនឲ្យរក្សាសួយជាដើម ដែលមានមកតាមប្រពៃណីយ៍បូរាណនោះឯង ឈ្មោះថា រមែងដកវត្ថុដែលបញ្ញត្តទុកហើយ ។ ពួកស្តេចលិច្ឆវីមិនបានសាកសួរពួកមនុស្ស ដែលត្រូវរាជបុរសចាប់មកសម្តែងថាជាចោរ បញ្ជាកាត់ទោស ឬកាត់អវយវៈ ឈ្មោះថា រមែងមិនប្រព្រឹត្តនូវធម៌របស់ពួកអ្នកដែនវជ្ជីកាលពីបូរាណ កាលពួកស្តេចលិច្ឆវីទាំងនោះបញ្ញត្តវត្ថុដែលនៅមិនទាន់បានបញ្ញត្ត ពួកមនុស្សអ្នកត្រូវនាំសួយដែលកំណត់ឡើងជាថ្មីជាដើមបៀតបៀន ក៏ប្រឹក្សាគ្នាថា ពួកយើងត្រូវពួកស្តេចលិច្ឆវីបៀតបៀនហើយ នរណាហ៊ានឹងទ្រាំនៅក្នុងដែនរបស់ពួកស្តេចទាំងនេះបាន ហើយនាំគ្នាភៀសខ្លួនទៅនៅជាយដែន ធ្វើចោរខ្លះ ធ្វើជាពួករបស់ចោរខ្លះ នាំគ្នាប្លន់អ្នកជនបទ ។ កាលស្តេចលិច្ឆវីទាំងនោះ ដកវត្ថុដែលបញ្ញត្តទុកហើយមិនរក្សាសួយជាដើម ដែលមានហើយតាមប្រពៃណីយ៍ ផ្ទៃព្រះឃ្លាំងរមែងវិនាស ។ លំដាប់នោះ ជនទាំងឡាយដែលមានពលដំរី ពលសេះ និងនាងស្នំជាដើម កាលមិនបានទទួលប្រាក់ខែដែលធ្លាប់មានជាប្រចាំ រមែង

វិនាសបាកកម្លាំង ជនទាំងនោះ រមែងអត់ធន់ចំពោះការច្បាំងមិនបាន រមែងអត់ធនក្នុងការប្រណិប័តន៍មិនបាន ។ កាលពួកស្តេចលិច្ឆវីមិនប្រព្រឹត្តក្នុងធម៌របស់ពួកអ្នកដែនវជ្ជីពីបុរាណ ពួកមនុស្សក្នុងដែន ក៏នាំគ្នាក្រោធថា ស្តេចលិច្ឆវីទាំងឡាយ កាត់ក្តី បុត្របិតារបស់យើងដែលមិនជាចោរ ឲ្យក្លាយជាចោរ ហើយកាត់ ឬទម្លាយអវយវៈ ហើយនាំគ្នាកៀសខ្លួនចេញទៅនៅជាយដែន ធ្វើចោរខ្លះ ធ្វើជាពួកចោរខ្លះ នាំគ្នាប្លន់ពួកអ្នកជនបទ ។ ស្តេចទាំងឡាយរមែងវិនាសដោយអាការយ៉ាងនេះ ។ តែកាលពួកស្តេចលិច្ឆវីមិនបញ្ញត្តវត្តដែលមិនទាន់បញ្ញត្ត ពួកមនុស្សរីករាយត្រេកអរថា ស្តេចទាំងឡាយធ្វើតាមវត្តបញ្ញត្តដែលធ្លាប់មានមកហើយតាមប្រពៃណីនោះឯង ហើយរមែងចាត់ចែងការងារ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ឲ្យសម្រេចផល ។ កាលពួកស្តេចលិច្ឆវីមិនដកវត្តដែលបញ្ញត្តទុកហើយ រក្សាសួយជាដើម ដែលធ្លាប់មានមកតាមប្រពៃណី ផ្លូវព្រះឃ្លាំងរមែងចម្រើនឡើង ។ តពីនោះពលដំរី ពលសេះ និងស្រីស្នំជាដើម កាលបានទទួលប្រាក់ខែតាមដែលមានជាប្រចាំ រមែងសប្បុរដោយកម្លាំង រមែងអត់ធន់ដល់ការងារ និងអត់ធន់ក្នុងការ

បម្រើ ។ កាលពួកស្តេចលិច្ឆវី ប្រព្រឹត្តតាំងនៅក្នុងធម៌របស់ពួកអ្នកដែនវជ្ជី ពីបុរាណ ពួកមនុស្សក៏មិនសម្លឹងទោស នាំគ្នាគិតថា ស្តេចទាំងឡាយទ្រង់ធ្វើតាមប្រពៃណីបុរាណ ទ្រង់ពិចារណាក្តី ដែលសេនាបតី និងឧបរាជអ្នកធ្លាតក្នុងអត្តក្តី បានពិចារណាល្អហើយដោយព្រះអង្គឯង ទ្រង់ឲ្យរាជបុរសអានគម្ពីរ (ច្បាប់) តាមប្រពៃណីហើយ ទ្រង់ដាក់អាជ្ញាដ៏សមគួរប៉ុណ្ណោះ ពួកស្តេចទាំងនេះមិនមានកំហុស ពួកយើងប៉ុណ្ណោះមានកំហុស ទើបនាំគ្នាមិនប្រមាទ ធ្វើការងារទាំងឡាយ ។ ស្តេចទាំងឡាយរមែងចម្រើនដោយអាការយ៉ាងនេះ ។

បទថា **សក្ករិស្សន្តិ (ធ្វើសក្ការៈ)** បានដល់ ស្តេចលិច្ឆវីទាំងឡាយ កាលធ្វើសក្ការៈណាមួយដល់ស្តេចលិច្ឆវីជាធំនោះ នឹងធ្វើតែសក្ការៈដែលល្អប៉ុណ្ណោះ ។ បទថា **គរុករិស្សន្តិ (នឹងគោរព)** បានដល់ នឹងធ្វើសេចក្តីគោរពថា ជាគ្រូឲ្យប្រាកដ ។ បទថា **មានេស្សន្តិ (រាប់អាន)** បានដល់ នឹងជាទីស្រលាញ់ដោយសេចក្តីរាប់អាន ។ បទថា **បូជេស្សន្តិ (នឹងបូជា)** បានដល់ នឹងបូជាដោយការបូជាដោយបច្ច័យ ។ បទថា **សោតព្វំ មញ្ញិ-**

សន្និ (ទីងសំគាល់ពាក្យ) បានដល់ ពួកស្តេចលិច្ឆវីទៅកាន់ទីទំនុកបម្រុង មួយថ្ងៃៗ ២-៣ ដង ទាំងសម្គាល់ពាក្យរបស់ស្តេចលិច្ឆវីជាធំទាំងនោះថា គួរស្តាប់ គួរកាន់យក ។ បណ្តាស្តេចលិច្ឆវីទាំងនោះ ស្តេចលិច្ឆវីពួកណាមិនធ្វើសក្ការៈជាដើមដល់ស្តេចលិច្ឆវីជាធំ ឬមិនទៅកាន់ទីទំនុកបម្រុងនៃស្តេចលិច្ឆវីជាធំទាំងនោះ កាលប្រយោជន៍ដល់ការទទួលឱវាទយ៉ាងនេះ ស្តេចលិច្ឆវីទាំងនោះ ត្រូវស្តេចលិច្ឆវីជាធំទាំងនោះលះបង់ចោលហើយ មិនឲ្យឱវាទ ជាអ្នកសប្បាយតែក្នុងការលេង រមែងវិនាសចាកកាជការ ។ តែស្តេចលិច្ឆវីពួកណារមែងបដិបត្តិដោយប្រការនោះ ស្តេចលិច្ឆវីដែលធំរមែងប្រាប់ប្រពៃណីបុរាណដល់ស្តេចលិច្ឆវីទាំងនោះថា កិច្ចនេះគួរធ្វើ កិច្ចនេះមិនគួរធ្វើ សូម្បីពេលមានសង្គ្រាមក៏ប្រាប់ឧបាយថា គួរចូលទៅយ៉ាងនេះ គួរចេញមកយ៉ាងនេះ ស្តេចលិច្ឆវីទាំងនោះ កាលត្រូវស្តេចលិច្ឆវីជាធំឲ្យឱវាទហើយ បដិបត្តិតាមឱវាទ រមែងអាចតាំងនៅក្នុងប្រពៃណីនៃរាជការបាន ព្រោះហេតុនេះ ព្រះមានព្រះភាគទើបត្រាស់ថា អ្នកដែនវជ្ជីគប្បីប្រាថ្នាសេចក្តីចម្រើនបានដោយពិត ។

បទថា កុលិត្ថិយោ (ពួកស្រីក្នុងត្រកូល) បានដល់ ស្ត្រីជាមេផ្ទះ

ក្នុងត្រកូល ។ បទថា **កុលកុមារិយោ** (ពួកកុមារីក្នុងត្រកូល) បានដល់ ធិតាទាំងឡាយរបស់ស្រីមេផ្ទះទាំងនោះដែលមិនមែនជាស្រីមេម៉ាយ ។ បទថា **ឱក្កស្ស** (បង្ខំ) ឬបទថា **បសយ្ហ** (បង្ខំចិត្ត) នេះជាឈ្មោះនៃការកំហែងនោះឯង ។ បាលីថា ឱកាស ដូច្នេះក៏មាន ។ ក្នុងបទទាំងនោះ បទថា **បង្ខំ** បានដល់ ទាញមក គឺ កន្ត្រាក់មក ។ បទថា **បង្ខំចិត្ត** បានដល់ សង្កត់សង្កិន គឺ បង្ខំចិត្ត ។ ពិតហើយ កាលស្តេចទាំងនោះ ធ្វើយ៉ាងនេះ មនុស្សទាំងឡាយក្នុងដែនក៏ក្រោធថា ទាំងបុត្រ និងបងប្អូនក្នុងផ្ទះរបស់ពួកយើង ទាំងធិតាដែលយើងទំផ្គុតទឹក និងជូតសំបោរជាដើមចេញអំពីមុខ ចិញ្ចឹមឲ្យចម្រើនធំធាត់ហើយ ស្តេចលិច្ឆវីទាំងនេះចាប់ទៅ ដោយប្រើកម្លាំង ឲ្យនៅបម្រើក្នុងផ្ទះរបស់ខ្លួន ក៏នាំគ្នាភៀសខ្លួនទៅនៅជាយដែន ធ្វើជាចោរខ្លះ ធ្វើជាពួករបស់ចោរខ្លះ ប្លន់ពួកអ្នកជនបទ ។ តែកាលពួកស្តេចលិច្ឆវីមិនធ្វើយ៉ាងនោះ ពួកមនុស្សក្នុងដែន ជាអ្នកគ្មានសេចក្តីកង្វល់ ធ្វើការងាររបស់ខ្លួន រមែងធ្វើផ្លែព្រះឃ្លាំងឲ្យសម្បូរ ។ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យក្នុងប្រការនេះ ដោយអាការយ៉ាងនេះ ។

បទថា **វជ្ជីនំ វជ្ជីចេតិយោ (ចេតិយក្នុងដែនវជ្ជី)** បានដល់ ស្ថានទីនៅរបស់យក្សដែលបាននាមថា ចេតិយ ដែលគេតាក់តែងវិចិត្រក្នុងដែនវជ្ជីរបស់ស្តេចលិច្ឆវីទាំងឡាយ ។ បទថា **អព្ភន្តរានិ (ខាងក្នុង)** បានដល់ តាំងនៅខាងក្នុងព្រះនគរ ។ បទថា **ពាហិរានិ (ខាងក្រៅ)** បានដល់ តាំងនៅខាងក្រៅព្រះនគរ ។ បទថា **ទិន្នបុព្វំ កតបុព្វំ (ដែលគេធ្លាប់ឲ្យ ធ្លាប់ធ្វើ)** បានដល់ ដែលឲ្យ និងធ្វើមកអំពីមុន ។ បទថា **នោ បរិហាបេស្សន្តិ (មិនបដិសេធ)** បានដល់ ស្តេចលិច្ឆវីទាំងឡាយទើបមិនបន្ថយ ទ្រង់ធ្វើតាមដែលធ្លាប់ធ្វើហើយនោះឯង ។ ពិតហើយ កាលស្តេចលិច្ឆវីទាំងឡាយបន្ថយពលិកម្មដែលជាធម៌ ទេវតាទាំងឡាយក៏មិនធ្វើការរក្សា ឲ្យជាការរក្សាដែលចាត់ចែងយ៉ាងល្អ សូម្បីកាលមិនអាចនឹងឲ្យកើតទុក្ខ ដែលមិនទាន់កើត រមែងធ្វើរោគក្អក រោគសីសៈជាដើម ដែលកើតហើយឲ្យកម្រើក កាលកើតសង្គ្រាមក៏មិនចូលជាបក្សពួកផង ។ តែកាលពួកស្តេចលិច្ឆវីមិនបន្ថយពលិកម្ម ទេវតាទាំងឡាយក៏ធ្វើការរក្សា ឲ្យជាការរក្សាដែលចាត់ចែងយ៉ាងល្អ សូម្បីកាលមិនអាចនឹងឲ្យសេចក្តីសុខដែលនៅមិនទាន់កើត ឲ្យកើតបាន រមែងបំបាត់

រោគក្អក រោគសីសៈជាដើម ដែលកើតឡើងហើយ រមែងជាបក្សពួកគ្រា មានសង្គ្រាម ព្រោះហេតុនោះ គប្បីជ្រាបសេចក្ដីចម្រើន និងសេចក្ដីសាប-សូន្យក្នុងសេចក្ដីនេះ ដោយប្រការដូច្នេះ ។

បទថា **ធម្មិការក្ខាវរណគុត្តិ** (ការរក្សា ការការពារ និងការឃុំគ្រង ប្រកបដោយធម៌) មានវិនិច្ឆ័យដូចតទៅនេះ ការរក្សានេះឯង ឈ្មោះថា ការពារ ព្រោះការពារនូវវត្ថុដែលមិនគួរប្រាថ្នា និងមិនទាន់មកដល់ ឈ្មោះថា ឃុំគ្រង ព្រោះឃុំគ្រងនូវវត្ថុគួរប្រាថ្នាមិនវិនាស ។ ក្នុងការរក្សានោះ ការប្រើកងកម្លាំងហែហមរក្សា មិនឈ្មោះថា ការរក្សា ការពារ និងឃុំគ្រង ដោយធម៌សម្រាប់បព្វជិតទេ ។ ចំណែកការធ្វើដោយប្រការដែលគ្រហស្ថ ទាំងឡាយ មិនកាប់ឆ្ការដើមឈើក្នុងព្រៃជិតវិហារ អ្នកចំការមិនព្រោះពូជ ក្នុងខេត្តនៃវិហារ មិនចាប់ត្រីក្នុងស្រះក្នុងខេត្តនៃវិហារ ឈ្មោះថា ការរក្សា ការពារ និងឃុំគ្រងដោយធម៌ ។ បទថា **កិន្តិ** (ដូចម្ដេច) បានដល់ ដោយហេតុអ្វីហ្ន៎ ។

ក្នុងបទថា **ដូចម្ដេច** ជាដើមនោះ មានវិនិច្ឆ័យដូចតទៅនេះ ស្ដេច

លិច្ឆវីអ្នកមិនប្រាថ្នាការមករបស់ព្រះអរហន្តទាំងឡាយ ដែលនៅមិនទាន់មក រមែងឈ្មោះថា ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា កាលបព្វជិតមកដល់ហើយ មិនធ្វើការក្រោកទទួល ទៅរកហើយ មិនថ្វាយបង្គំ មិនធ្វើបដិសណ្ឋារៈ មិនសាកសួរបញ្ហា មិនស្តាប់ធម៌ មិនថ្វាយទាន មិនស្តាប់ការអនុមោទនា មិនចាត់ចែងទីស្នាក់អាស្រ័យប្រគេន ។ ដូច្នោះ កិត្តិស័ព្ទមិនល្អរបស់ស្តេចលិច្ឆវីទាំងនោះ រមែងខ្ចរខ្ចាយទៅថា ស្តេចឈ្មោះឯណោះ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា កាលបព្វជិតមកដល់ហើយ ក៏មិនធ្វើការក្រោកទទួល ។ល។ មិនចាត់ចែងទីស្នាក់អាស្រ័យប្រគេន ។ ពួកបព្វជិតបានស្តាប់ដូច្នោះហើយ សូម្បីធ្លងទៅផ្លូវទ្វារក្រុងរបស់ព្រះរាជានោះ ក៏មិនចូលក្រុង ។ កាលបើដូច្នោះ ព្រះអរហន្តដែលនៅមិនទាន់មក ក៏មិនមក ។ ក៏កាលការនៅជាសុខមិនមានដល់អ្នកមកហើយ អ្នកដែលមិនដឹងហើយមក គិតថា ក្នុងពេលជំបូងពួកយើងតាំងចិត្តថា នឹងនៅ ទើបនាំគ្នាមក នរណាហ្ន៎នឹងនៅបាន ដោយការមិនទទួលដូច្នេះ របស់ស្តេចទាំងនេះ ហើយក៏នាំគ្នាចៀសចេញទៅ ។ កាលដូច្នេះ កាលព្រះអរហន្តដែលនៅមិន

ទាន់មកក៏មិនមក ដែលមកហើយក៏នូវជាទុក្ខ ប្រទេសនោះក៏ឈ្មោះថា មិនជាទីគួរនៅសម្រាប់បព្វជិត ។ តពីនោះ ការរក្សារបស់ទេវតាក៏មិនមាន កាលការរក្សារបស់ទេវតាមិនមាន ពួកអមនុស្សរមែងបានឱកាស ស្ថានទីនោះនឹងពេញទៅដោយពួកអមនុស្ស រមែងញាំងពព្យាធិ ដែលនៅមិនទាន់កើតឲ្យកើតឡើង បុណ្យមានហេតុព្រោះការឃើញ និងការសួរបញ្ហាចំពោះអ្នកមានសីលទាំងឡាយជាដើម ក៏នឹងមិនមកដល់ ។ ដោយបរិយាយផ្ទុយគ្នា ធម៌ចំណែកស (កុសល) ដែលផ្ទុយគ្នាជាមួយធម៌ចំណែកខ្មៅ តាមដែលពោលហើយ រមែងកើតឡើង ព្រោះហេតុនោះ គប្បីជ្រាបសេចក្ដីចម្រើន និងសេចក្ដីសាបសូន្យក្នុងរឿងនេះ ដោយអាការយ៉ាងនេះឯង ។

ចប់អដ្ឋកថា សារន្ទទសូត្រទី ១

# អដ្ឋកថា វស្សការសូត្រទី ២

## វស្សការព្រាហ្មណ៍ស្តាប់អបរិហានិយធម៌ ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង វស្សការសូត្រទី ២ ដូចតទៅនេះ ៖*

*[២០] បទថា **អភិយាតុកាមោ** (ទ្រង់ព្រះបំណងនឹងយាត្រាទ័ពទៅច្បាំញ) បានដល់ ទ្រង់មានព្រះរាជបំណងនឹងលើកទ័ពទៅច្បាំញ ។ បទថា **វជ្ជី** (ដែនវជ្ជី) បានដល់ ស្តេចវជ្ជីទាំងឡាយ ។ បទថា **ឯវំមហិទ្ធិកេ** (មានឫទ្ធិច្រើនយ៉ាងនេះ) បានដល់ អ្នកប្រកបដោយរាជឫទ្ធិធំយ៉ាងនេះ ។ ដោយបទថា **មានឫទ្ធិច្រើនយ៉ាងនេះ** នេះ ព្រះបាទអជាតសត្រូវត្រាស់ដល់ស្តេចវជ្ជីទាំងនោះ មានសេចក្តីព្រមព្រៀងគ្នា ។ បទថា **ឯវំមហានុភាវេ** (មានអានុភាពច្រើនយ៉ាងនេះ) បានដល់ ជាអ្នកប្រកបដោយរាជានុភាពធំយ៉ាងនេះ ។ បទថា **មានអានុភាពច្រើនយ៉ាងនេះ** នេះ ព្រះបាទអជាតសត្រូវត្រាស់ដល់ស្តេចវជ្ជីទាំងនោះ ជាអ្នកធ្វើការសិក្សាហើយក្នុងសិល្បៈទាំងឡាយមានសិល្បៈដំរីជាដើម ដូចដែលមានអ្នកពោលទុកថា ស្តេចលិច្ឆវីកំលោះទាំងនេះសិក្សាហើយហ្ន៎ ស្តេចលិច្ឆវីកំលោះទាំងនេះសិក្សាល្អហើយហ្ន៎ មាន*

ការបាញ់ព្រួញបានត្រូវគ្នា មិនខុសផ្លូវនៃរន្ធកូនព្រួញដ៏តូចៗ បាន ។ បទថា **ឧច្ឆេជ្ជិស្សាមិ** (នឹងកាត់... នឹងផ្តាច់ផ្តិល) បានដល់ នឹងកាត់ផ្តាច់ ។ បទថា **វិនាសេស្សាមិ** (ឲ្យវិនាស) បានដល់ ធ្វើមិនឲ្យប្រាកដឡើយ ។ បទថា **អនយព្យសនំ** (នូវសេចក្តីវិនាស) បានដល់ ការមិនចម្រើន និងសេចក្តីវិនាសនៃញាតិ ។ បទថា **អាបាទេស្សាមិ** (ឲ្យដល់) បានដល់ នឹងឲ្យដល់ (សេចក្តីសាបសូន្យ និងសេចក្តីវិនាស) ។

បានឮថា ព្រះបាទអជាតសត្រូវនោះ ត្រាស់រឿងការច្បាំងនេះក្នុងទីប្រថាប់ឈរ ក្នុងទីដែលប្រថាប់អង្គុយជាដើម និងត្រាស់បញ្ជាកងទ័ពថា ពួកអ្នកត្រៀមយាត្រាទ័ព ព្រោះហេតុអ្វី ។ ព្រោះថា ត្រង់មាត់ប្រាំងទន្លេគង្គា មានពួកស្រុកបដ្តនគ្រាមជាតំបន់មួយ ជាដែនដីរបស់ព្រះបាទអជាត-សត្រូវ ៨ យោជន៍ របស់ពួកស្តេចលិច្ឆវី ៨ យោជន៍ ។ ក្នុងបដ្តនគ្រាមនោះ របស់ក្រអូប និងវត្ថុដែលមានតម្លៃច្រើនហូរមកអំពីជើងភ្នំ ។ កាលព្រះបាទអជាតសត្រូវទ្រង់ស្តាប់រឿងនោះ ទ្រង់ត្រិះរិះថា យើងនឹងទៅថ្ងៃនេះ យើងនឹងទៅស្អែកនេះ រវល់តែត្រៀមគ្នា ពួកស្តេចលិច្ឆវីបានព្រមព្រៀងគ្នា

មកយកទៅមុនអស់ ។ ព្រះបាទអជាតសត្រូវស្តេចមកដល់ខាងក្រោយ ទ្រង់ជ្រាបរឿងនោះ ស្តេចក៏ទ្រង់ពិរោធ ហើយស្តេចត្រឡប់ទៅវិញ ។ សូម្បីក្នុងឆ្នាំតទៅ ស្តេចលិច្ឆវីទាំងនោះក៏ទ្រង់ធ្វើដូចយ៉ាងនោះឯង។ គ្រានោះឯងព្រះបាទអជាតសត្រូវខ្វាល់យ៉ាងខ្លាំង ទ្រង់ក៏ធ្វើយ៉ាងនោះ ក្នុងគ្រានោះ ។ លំដាប់នោះ ព្រះបាទអជាតសត្រូវទ្រង់ត្រិះរិះថា ដែលឈ្មោះថា ការច្បាំងជាមួយគណៈស្តេចលិច្ឆវីជារឿងធំ ការបង្ក្រាបឲ្យស្ងប់ស្ងៀមសូម្បីតែមួយដងក៏មិនបាន ការបង្ក្រាបនេះត្រូវធ្វើការប្រឹក្សាជាមួយបណ្ឌិតណាម្នាក់ ទើបមិនក្លាំងក្លាត់ តែបណ្ឌិតដូចជាព្រះសាស្តាមិនមាន និងព្រះសាស្តាក៏ប្រថាប់នៅក្នុងព្រះវិហារជិតៗ មិនឆ្ងាយ ណ្ហើយចុះ យើងនឹងបញ្ជូនមនុស្សទៅទូលសួរ ប្រសិនបើយើងទៅ (ច្បាំង) ហើយ នឹងមានប្រយោជន៍កើតឡើង ព្រះសាស្តាក៏នឹងគង់ស្ងៀម តែកាលនឹងមានសេចក្តីវិនាស ព្រះសាស្តានឹងត្រាស់ថា នឹងមានប្រយោជន៍អ្វីដោយការទៅក្នុងទីនោះ ស្តេចទើបទ្រង់បញ្ជូនវស្សការព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទៅហើយក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោល

ថា អថខោ ភជា ។បេ។ អាបាទេស្សាមិ វជ្ជី (គ្រោះនោះឯង ព្រះរាជា ស្តេចផែនដី ។ល។ ឲ្យដល់នូវសេចក្តីវិនាស) ។

បទថា ភគវន្តំ វីជមានោ (កំពង់បក់ថ្វាយព្រះមានព្រះភាគ) បានដល់ ព្រះថេរៈតាំងនៅក្នុងវត្តបដិបត្តិ បក់ថ្វាយព្រះមានព្រះភាគ ។ តែត្រជាក់ និងក្តៅ មិនមានដល់ព្រះមានព្រះភាគទេ ។ ព្រះមានព្រះភាគលុះទ្រង់ស្តាប់ ពាក្យរបស់ព្រាហ្មណ៍ហើយ មិនបានត្រាស់ជាមួយព្រាហ្មណ៍នោះទេ ទ្រង់ មានព្រះបំណងនឹងត្រាស់ជាមួយព្រះថេរៈ ទើបត្រាស់ថា (កិន្តិ តេ អានន្ទ សុតំ (អានន្ទ អ្នកបានស្តាប់មកហើយ ដូច្នេះឬថា) សេចក្តីនោះ មានពាក្យ អធិប្បាយដូចដែលពោលទុកហើយនោះឯង ។

ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ឯកមិទាហំ (សម័យមួយ តថាគត) ដើម្បីទ្រង់ប្រកាសដល់វជ្ជីធម៌ ៧ ប្រការនេះ ទ្រង់សម្តែងដល់ ស្តេចវជ្ជីទាំងឡាយអំពីមុន ។ បទថា អករណីយា (មិនគប្បីធ្វើការតយុទ្ធ) បានដល់ មិនគួរធ្វើ អធិប្បាយថា មិនគួរកាន់យក ។ បទថា យទិទំ ជានិបាត ។ បទថា យុទ្ធស្ស (ការតយុទ្ធ) ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃ

តតិយាវិកត្តិ ។ អធិប្បាយថា នរណាៗ មិនអាចដឹងបានដោយការច្បាំងដែលកើតឡើងចំពោះមុខ ។ បទថា **អញ្ញត្រ ឧបលាបទាយ (វៀរលែងតែការលួងលោម)** បានដល់ វៀរចាកការចចារ ។ ដែលឈ្មោះថា ចចារនោះ បានដល់ ការបញ្ជូនបណ្ណាការ មានដំរី សេះ រថ ប្រាក់ មាសជាដើមទៅធ្វើការសង្គ្រោះគ្នា ដោយពោលថា កុំវិវាទគ្នាឡើយ ឥឡូវនេះពួកយើងនឹងសាមគ្គីគ្នា ។ អធិប្បាយថា ការធ្វើសង្គ្រោះយ៉ាងនេះ ក៏អាចនឹងលើកទឹកចិត្តគ្នាបាន ដោយសេចក្តីស្និទ្ធស្នាលពិតៗ ។ បទថា **អញ្ញត្រ មិថុភេទា (ក្រៅពីការញុះញង់ឲ្យបែកគ្នា)** បានដល់ វៀរការធ្វើឲ្យ ២ ចំណែកបែកគ្នា ។ ។ ដោយបទនេះ វស្សការព្រាហ្មណ៍សម្តែងថា ធ្វើឲ្យបែកគ្នាហើយ ក៏នឹងអាចចាប់ស្តេចវជ្ជីទាំងនោះបាន ។

ព្រាហ្មណ៍បានន័យនៃព្រះពុទ្ធត្រាស់ហើយ ទើបពោលដូច្នេះ ។ សួរថា ក៏ព្រះមានព្រះភាគទ្រង់ជ្រាបការបានន័យរបស់ព្រាហ្មណ៍អំពីព្រះតម្រាស់នេះឬ ។ ឆ្លើយថា មែន ទ្រង់ជ្រាប ។ សួរថា ក៏កាលទ្រង់ជ្រាប ហេតុអ្វីទើបត្រាស់ ។ ឆ្លើយថា ដើម្បីទ្រង់អនុគ្រោះ ។ ន័យថា ព្រះអង្គទ្រង់មាន

ព្រះតម្រិះយ៉ាងនេះថា សូម្បីកាលតថាគតមិនពោល កន្លងទៅ ២-៣ ថ្ងៃ ព្រះបាទអជាតសត្រូវស្តេចទៅចាប់ស្តេចវជ្ជីទាំងអស់ តែកាលតថាគតពោលហើយ ព្រះបាទអជាតសត្រូវ ត្រូវប្រើវេលា ៣ ឆ្នាំ ទើបបំបែកស្តេចវជ្ជីដែលសាមគ្គីគ្នាបាន ការមានជីវិតសូម្បីត្រឹមតែប៉ុណ្ណេះ ក៏ជាការប្រសើរពិតហើយ ស្តេចវជ្ជីដែលរស់នៅប៉ុណ្ណេះ ក៏នឹងធ្វើបុណ្យដើម្បីជាទីពឹងដល់ខ្លួនបាន ។ បទថា **អភិនន្ទិត្វា (រីករាយ)** បានដល់ រីករាយហើយដោយចិត្ត ។ បទថា **អនុមោទិត្វា (អនុមោទនា)** បានដល់ រីករាយដោយវាចាថា ព្រះតម្រាស់នេះ ព្រះគោតមដ៏ចម្រើនត្រាស់ល្អហើយ ។ បទថា **បក្កាមិ (ចេញទៅ)** បានដល់ ត្រឡប់ទៅទូលព្រះរាជាហើយ ។ ចំណែកព្រះរាជាក៏បញ្ជូនវស្សការព្រាហ្មណ៍នោះឯងទៅបំបែកស្តេចវជ្ជីទាំងអស់ ឲ្យដល់នូវការបែកគ្នា ។

ចប់អដ្ឋកថា វស្សការសូត្រទី ២

# អដ្ឋកថា ភិក្ខុសូត្រទី ៣

## *ត្រាស់អបរិហានិយធម៌ដល់ភិក្ខុ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុសូត្រទី ៣ ដូចតទៅនេះ ៖*

[២១] *បទថា* អភិណ្ហសន្និបាតា *(ប្រជុំគ្នារឿយៗ) នេះ ដូចពាក្យដែលពោលហើយក្នុងវជ្ជីអបរិហានិយធម៌ ៧ ប្រការនោះឯង ។ ក៏ភិក្ខុទាំងឡាយសូម្បីក្នុងសាសនានេះ កាលមិនប្រជុំគ្នាជារឿយៗ រមែងមិនបានឮដំណឹងដែលមកអំពីទិសទាំងឡាយ តអំពីនោះ រមែងមិនដឹងដំណឹងជាដើមថា សីមាវិហារឯណោះប្រឫកប្រឫល់ តែនៅមានឧបោសថ និងបវារណា ភិក្ខុក្នុងទីឈ្មោះឯណោះធ្វើវេជ្ជកម្ម និងទូតកម្មជាដើម ភិក្ខុទាំងឡាយដែលច្រើនទៅដោយវិញ្ញត្តិ រមែងចិញ្ចឹមជីវិតដោយការឲ្យផ្លែឈើ និងផ្កាឈើជាដើម សូម្បីភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃប្រមាទហើយ រមែងធ្វើពាក្យប្រៀនប្រដៅដែលបរិបូណ៌ឲ្យសាបសូន្យ ។ ចំណែកភិក្ខុទាំងឡាយដែលប្រជុំគ្នារឿយៗ រមែងបានស្តាប់រឿងនោះ ។ លំដាប់នោះ ក៏បញ្ជូនភិក្ខុសង្ឃឲ្យទៅធ្វើសីមាឲ្យត្រឹមត្រូវ ញុំាងឧបោសថ និងបវារណាឲ្យប្រព្រឹត្ត*

ទៅ បញ្ជូនភិក្ខុអ្នកតាំងនៅក្នុងអរិយវង្ស ទៅកាន់ទីនៅរបស់ពួកភិក្ខុមិច្ឆា-ជីព ហើយឲ្យទូន្មានអរិយវង្ស ឲ្យភិក្ខុពួកវិន័យធរដាក់និគ្គហកម្មដល់ភិក្ខុអាក្រក់ទាំងឡាយ សូម្បីភិក្ខុទាំងឡាយដឹងថា សង្ឃមិនធ្វេសប្រហែស ពួកយើងមិនអាចដើម្បីត្រាច់ទៅជាពួកជាក្រុមបាន ទើបបំបែកគ្នាចៀសចេញទៅ ។ គប្បីជ្រាបសេចក្ដីចម្រើន និងសេចក្ដីវិនាសក្នុងប្រការនេះ ដោយអាការយ៉ាងនេះ ។

ក្នុងបទថា *សមគ្គា (ព្រមព្រៀងគ្នា)* ជាដើម មានវិនិច្ឆ័យដូចតទៅនេះ កាលបុគ្គលវាយស្គរ ឬគោះរគាំងថា សង្ឃនឹងប្រជុំគ្នាដើម្បីសម្អាតព្រះចេតិយ ឬដើម្បីសម្អាតផ្ទះពោធិព្រឹក្ស ឬរោងឧបោសថ ឬដើម្បីបំណាំងនឹងតាំងនៅកតិកាវត្ត ភិក្ខុទាំងឡាយធ្វើការប្រកែកថា យើងមានវិចីកម្មហើយ យើងជាអ្នកប្រព្រឹត្តបិណ្ឌបាត យើងមាននវកម្មហើយ ឈ្មោះថាមិនព្រមព្រៀងគ្នាប្រជុំ ។ តែភិក្ខុទាំងឡាយផ្អាកកម្មទាំងអស់នោះ គិតថាយើងនឹងទៅមុនគេៗ ប្រជុំព្រមគ្នា ឈ្មោះថា *ព្រមព្រៀងគ្នាប្រជុំ* ។ មួយទៀត ភិក្ខុទាំងឡាយប្រជុំគ្នា គិតប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើហើយ មិន

លើកការប្រជុំព្រមគ្នា (ប្រជុំជាចំណែកៗ) ឈ្មោះថា មិនព្រមព្រៀងគ្នាលើកការប្រជុំ ។ ព្រោះថា កាលភិក្ខុទាំងឡាយលើកប្រជុំគ្នាដោយអាការយ៉ាងនេះ ពួកភិក្ខុដែលលើកទៅមុន រមែងមានបរិវិតក្កៈយ៉ាងនេះថា ពួកយើងស្តាប់តែរឿងប្រការខាងក្រៅ (រឿងខាងក្រៅព្រះនគរ) ឥឡូវនេះ នឹងមានរឿងកំណត់គ្នាយ៉ាងណា ។ តែភិក្ខុទាំងឡាយកាលលើកប្រជុំព្រមៗ គ្នានោះឯង ឈ្មោះថា **ព្រមព្រៀងគ្នាលើកប្រជុំ** ។ម្យ៉ាងទៀត ភិក្ខុទាំងឡាយស្តាប់ដំណឹងថា សីមាវិហារក្នុងទីឯណោះប្រេបួកប្រេបល់ ឧបោសថ បវារណានៅមានក្នុងទីឯណោះ ពួកភិក្ខុអាក្រក់អ្នកធ្វើវេជ្ជកម្មជាដើមច្រើនៗ ឡើងកាលព្រះថេរៈពោលថា នរណានឹងទៅដាក់និគ្គហកម្មដល់ភិក្ខុទាំងនោះ ក៏នឹងដណ្តើមគ្នានិយាយថា ខ្ញុំមុន ខ្ញុំមុន ហើយក៏ទៅ ឈ្មោះថា **ព្រមព្រៀងគ្នាលើកប្រជុំ** ។

មួយទៀត ភិក្ខុទាំងឡាយឃើញភិក្ខុអាគន្តុកៈហើយ មិនពោលថា លោកចូរទៅក្នុងបរិវេណនេះ លោកចូរទៅបរិវេណនោះ ពួកយើងជានរណាដឹងទេ គ្រប់អង្គធ្វើវត្តក្តី ឃើញអាគន្តុកៈមានបាត្រចីវរចាស់ ក៏ស្វែងរក

បាត្រ ចីវរ ដោយភិក្ខាចារវត្តដល់ភិក្ខុអាគន្តុៈនោះក្តី ស្វែងរកគិលានភេសជ្ជៈ (ថ្នាំ) ដល់ភិក្ខុអាគន្តុកៈអ្នកអាពាធក្តី មិននិយាយជាមួយភិក្ខុអាគន្តុកៈ ភិក្ខុអាពាធមិនមានទីពឹងថា លោកចូរទៅបរិវេណឯណោះ បានត្រៀមក្នុងបរិ-វេណរបស់ខ្លួនៗ ហើយក្តី មានគម្ពីរដែលនៅច្រូសប្រហែស ក៏សង្គ្រោះភិក្ខុអ្នកមានបញ្ញា ឲ្យលោកកែខែគម្ពីរនោះក្តី ឈ្មោះថា **ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃដែលគួរធ្វើ** ។

ក្នុងបទថា **អប្បញ្ញត្តំ (វត្ថុមិនទាន់បញ្ញត្តសិក្ខាបទ)** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ភិក្ខុទាំងឡាយតាំងកតិកាវត្ត ឬសិក្ខាបទដែលមិនមែនជាធម៌ ថែមថ្មី ឈ្មោះថា បញ្ញត្តវត្ថុដែលទ្រង់មិនបានបញ្ញត្ត ដូចភិក្ខុទាំងឡាយក្នុងក្រុងសាវត្ថី បញ្ញត្តវត្ថុដែលទ្រង់មិនទាន់បានបញ្ញត្តចំពោះរឿងសន្ថ័តចាស់ ។ ភិក្ខុទាំងឡាយកាលសម្តែងពាក្យទូន្មានក្រៅធម៌ ក្រៅវិន័យ ឈ្មោះថា ដកវត្ថុដែលទ្រង់បញ្ញត្តទុកហើយ ដូចភិក្ខុវជ្ជីបុត្រក្រុងវេសាលី ដកសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយ កាលព្រះមានព្រះភាគស្តេចបរិនិព្វានបាន ១០០ ឆ្នាំ ។ មួយទៀត ភិក្ខុទាំងឡាយកាលតាំងចិត្តកន្លងអាបត្តិតូចៗ

ឈ្មោះថា មិនប្រព្រឹត្តមុតមាំក្នុងសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្ត ទុកហើយ ដូចព្រះអស្សជិ និងព្រះបុនព្វសុកៈ ។ ចំណែកភិក្ខុទាំងឡាយ កាលមិនធ្វើយ៉ាងនោះ ឈ្មោះថា រមែងមិនបញ្ញត្តវត្ថុដែលទ្រង់មិនទាន់បាន បញ្ញត្ត រមែងមិនដកវត្ថុដែលទ្រង់បញ្ញត្តទុកហើយ រមែងប្រព្រឹត្តមុតមាំនៅ ក្នុងសិក្ខាបទតាមដែលទ្រង់បញ្ញត្តទុកហើយ ដូចព្រះឧបសេន ។ បទថា **វុឌ្ឍិយេវ (សេចក្តីចម្រើនតែងមានប្រាកដ)** បានដល់ សេចក្តីចម្រើនដោយ គុណ មានសីលគុណជាដើមប៉ុណ្ណោះ មិនមានសេចក្តីសាបសូន្យឡើយ ។

បទថា **ថេរា (ជាថេរៈ)** បានដល់ អ្នកដល់នូវភាវៈមាំមួន គឺ ប្រកប ដោយគុណជាគ្រឿងធ្វើភាពជាថេរៈ ។ ភិក្ខុពួកណារមែងដឹងរាត្រីច្រើន ព្រោះ ហេតុនោះ ភិក្ខុទាំងនោះទើបឈ្មោះថា **រត្តញ្ញូ (អ្នកដឹងរាត្រីច្រើន)** ។ ការ បួសរបស់ភិក្ខុទាំងនេះអស់កាលយូរ ព្រោះហេតុនោះឈ្មោះថា **ចិរប្បព្វជិតា (បួសយូរ)** ។ ភិក្ខុពួកណាតាំងនៅក្នុងឋានៈជាបិតានៃសង្ឃ ព្រោះហេតុ នោះ ភិក្ខុពួកនោះទើបឈ្មោះថា **សង្ឃបិតរោ (ជាបិតានៃសង្ឃ)** ។ ភិក្ខុ ពួកណារមែងនាំសង្ឃ ព្រោះតាំងនៅក្នុងឋានៈជាបិតានៃសង្ឃនោះ គឺ ជា

ប្រធាន ឲ្យភិក្ខុទាំងឡាយប្រព្រឹត្តក្នុងសិក្ខា ៣ ព្រោះហេតុនោះ ភិក្ខុទាំងនោះទើបឈ្មោះថា សង្ឃបរិនាយកោ (ជាបរិនាយករបស់សង្ឃ) ។ ភិក្ខុពួកណាមិនធ្វើសក្ការៈជាដើមដល់ព្រះថេរៈទាំងនោះ មិនទៅប្រណិប័តន៍ ២ វារៈ ៣ វារៈ ដើម្បីប្រយោជន៍ដល់ការទទួលឱវាទ ព្រះថេរៈសូម្បីពួកនោះរមែងមិនឲ្យឱវាទដល់ភិក្ខុទាំងនោះ មិនពោលពាក្យដែលជាប្រវេណី ជាធម្មនិយាមដល់ភិក្ខុទាំងនោះ មិនឲ្យសិក្សាបរិយត្តិធម៌ដែលជាសារៈ ភិក្ខុពួកនោះ ដែលព្រះថេរៈទាំងនោះលះបង់ចេញហើយ រមែងវិនាសចាកគុណទាំងឡាយជាដើម យ៉ាងនេះគឺ ធម្មក្ខន្ធ មានសីលក្ខន្ធជាដើម និងអរិយទ្រព្យ ៧ ប្រការ ។ ចំណែកភិក្ខុពួកណាធ្វើសក្ការៈជាដើមដល់ព្រះថេរៈទាំងនោះ ទៅប្រណិប័តន៍ព្រះថេរៈទាំងនោះ ព្រះថេរៈទាំងនោះរមែងឲ្យឱវាទដល់ភិក្ខុទាំងនោះជាដើមថា លោកគប្បីឈានទៅខាងមុខដោយអាការយ៉ាងនេះ រមែងពោលពាក្យដែលជាធម្មនិយាម ជាប្រវេណី រមែងឲ្យសិក្សាធម្មបរិយាយដែលជាសារៈ រមែងបង្រៀនធុតង្គ ១៣ កថាវត្ថុ ១០ ភិក្ខុទាំងនោះតាំងនូវក្នុងឱវាទរបស់ព្រះថេរៈទាំងនោះ ចម្រើនដោយគុណ មាន

សីលគុណជាដើម រមែងសម្រេចតាមលំដាប់នូវប្រយោជន៍ ដែលជាសាមញ្ញ-ផល ។ ក្នុងសេចក្តីនេះ គប្បីជ្រាបសេចក្តីវិនាស និងសេចក្តីចម្រើនដោយអាការយ៉ាងនេះ ។

ការកើតថ្មីជាប្រក្រតីរបស់តណ្ហានោះ ព្រោះហេតុនោះ តណ្ហានោះទើបឈ្មោះថា ហេតុឲ្យកើតថ្មី អធិប្បាយថា ឲ្យការកើតថ្មី ។ តណ្ហាឈ្មោះថា **បោនោព្ភវិកាយ (ដែលជាហេតុកើតថ្មី)** ។ ក្នុងបទថា **នោ វសំ គច្ឆិស្សន្តិ (មិនលុះក្នុងអំណាច)** នេះ មានវិនិច្ឆ័យដូចតទៅនេះ ភិក្ខុពួកណាជាអ្នកប្រព្រឹត្តទៅតាមស្នាមនៃឧបដ្ឋានទាំងឡាយ ព្រោះហេតុនៃបច្ច័យ ៤ រមែងត្រាច់ទៅផ្ទះឯណោះ ផ្ទះឯណោះ ភិក្ខុទាំងនោះឈ្មោះថា លុះអំណាចនៃតណ្ហាដែលជាហេតុឲ្យកើតថ្មីនោះ ចំណែកពួកភិក្ខុដទៃទៀត មិនលុះក្នុងអំណាចតណ្ហាដែលជាហេតុឲ្យកើតថ្មីនោះ ។ ក្នុងសេចក្តីនោះ សេចក្តីសាបសូន្យ និងសេចក្តីចម្រើនទាំងឡាយប្រាកដហើយនោះឯង ។

បទថា **អារញ្ញកេសុ (ក្នុងព្រៃ)** បានដល់ ដែលតាំងនៅខាងក្រោយស្រុក ៥០០ ធ្នូឡើងទៅ ។ បទថា **សាបេក្ខា (ពេញចិត្ត)** បានដល់

នៅមានអាល័យ ។ ពិតហើយ ភិក្ខុសូម្បីបានសម្រេចឈានក្នុងសេនាសនៈជិតស្រុក ពេលចេញចាកឈាននោះ រមែងបានឮសំឡេងប្រុសស្រី និងក្មេងជាដើម ព្រោះហេតុនោះ គុណវិសេសដែលលោកសម្រេចហើយ រមែងសាបសូន្យ ។ ភិក្ខុសូម្បីត្រឡប់ទៅក្នុងសេនាសនៈព្រៃ ពេលក្រោកឡើងបានឮសំឡេងរាជសីហ៍ ខ្លាធំ សត្វក្ងោកជាដើម ដែលជាហេតុឲ្យបានបីតិក្នុងព្រៃ ពិចារណាបីតិនោះឯង ក៏តាំងនូវក្នុងផលដ៏លើស ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ទើបសរសើរភិក្ខុអ្នកនៅក្នុងព្រៃនោះឯង ជាងភិក្ខុដែលសម្រេចឈានអដ្ឋយក្នុងសេនាសនៈជិតស្រុក ព្រោះដូច្នោះ ទ្រង់អាស្រ័យប្រយោជន៍នោះឯង ទើបត្រាស់ថា ភិក្ខុទាំងឡាយនឹងពេញចិត្តនៅក្នុងសេ-នាសនៈព្រៃ ។

បទថា បច្ចត្តញ្ញេវ សតឹ ឧបដ្ឋបេស្សន្តិ (នឹងប្រុងស្មារតីក្នុងខ្លួនថា) បានដល់ តាំងសតិទុកខាងក្នុងខ្លួន ។ បទថា បេសលា (មានសីលជាទីស្រឡាញ់) បានដល់ អ្នករក្សាសីល ។ ភិក្ខុចៅអាវាសទាំងឡាយអ្នកមិនប្រាថ្នាការមករបស់ភិក្ខុជាសព្រហ្មចារីទាំងឡាយ សូម្បីក្នុងសាសនា

នេះ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា មិនធ្វើវត្ត មានការចេញទៅទទួល ទទួលបាត្រ និងចីវរ ក្រាលអាសនៈ និងកាន់យកផ្លិតជាងគ្នោត (បក់ឲ្យ) ជាដើម ដល់ភិក្ខុអ្នកមកដល់វិហារ ។ ពេលនោះ កេរ្តិ៍ឈ្មោះដ៏អាក្រក់របស់ពួកភិក្ខុទាំងនោះ រមែងផ្សាយទៅថា ភិក្ខុទាំងឡាយអ្នកនៅក្នុងវិហារឈ្មោះឯណោះ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា មិនធ្វើសូម្បីវត្តបដិបត្តិដល់ភិក្ខុអ្នកចូលទៅកាន់វិហារ ។ បព្វជិតទាំងឡាយកាលបានឮរឿងនោះហើយ សូម្បីកាលឈានទៅផ្លូវវិហារនោះ ក៏មិនចូលកាន់វិហារ បព្វជិតទាំងឡាយដែលមិនធ្លាប់មកក៏មិនមក ដោយប្រការដូច្នេះ ។ កាលការនៅជាសុខមិនមានដល់បព្វជិតអ្នកមកដល់ហើយ គឺ បព្វជិតដែលមកដល់ ព្រោះមិនជ្រាប ក៏នាំគ្នាត្រឡប់ចេញទៅ ដោយគិតថា មុននេះពួកយើងមកហើយដោយសង្ឃឹមថា ពួកយើងនឹងស្នាក់នៅ ទើបមក ដោយការបដិបត្តិទំនងនេះរបស់ចៅអាវាសទាំងនេះ នរណានឹងស្នាក់នៅបាន ។ វិហារនោះ រមែងមិនជាទីនៅរបស់ភិក្ខុពួកដទៃ ដោយប្រការដូច្នេះ ។ លំដាប់នោះ ភិក្ខុចៅអាវាសទាំងឡាយ កាលមិនបានប្រសព្វភិក្ខុទាំងឡាយអ្នកមាន

សីល រមែងមិនបានបុគ្គលបន្ទោបង់សេចក្ដីសង្ស័យ ។ មិនបានបុគ្គលឲ្យសិក្សាអាចារៈ ឬមិនបានការស្ដាប់ធម៌ដ៏ពីរោះ ។ ភិក្ខុទាំងនោះ រមែងមិនបានរៀនធម៌ដែលមិនធ្លាប់រៀន រមែងមិនបានធ្វើការស្វាធ្យាយធម៌ដែលធ្លាប់រៀនមកហើយ ។ ដូច្នោះ ភិក្ខុទាំងនោះទើបមានតែសេចក្ដីសាបសូន្យតែម្យ៉ាង មិនមានសេចក្ដីចម្រើនឡើយ ។

ចំណែកភិក្ខុពួកណា រមែងប្រាថ្នាការមករបស់សព្រហ្មចារីទាំងឡាយ ភិក្ខុពួកនោះជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា ធ្វើសាមីចិកម្ម មានការចេញទៅទទួលជាដើម ដល់សព្រហ្មចារីទាំងឡាយដែលបានមកដល់ហើយក្រាលអាសនៈថ្វាយ នាំភិក្ខុដែលសព្រហ្មចារីទាំងនោះចូលទៅភិក្ខាចារ រមែងបន្ទោបង់សេចក្ដីសង្ស័យបាន រមែងបានស្ដាប់ធម៌ដ៏ពីរោះ ។ ទីរបស់ភិក្ខុនោះក៏មានកេរ្តិ៍ឈ្មោះល្អ មានការផ្សាយទៅថា ភិក្ខុទាំងឡាយក្នុងវិហារឈ្មោះឯណោះ ជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា បរិបូណ៌ដោយវត្តជាអ្នកសង្គ្រោះ ដោយអាការយ៉ាងនេះ ។ ភិក្ខុទាំងឡាយបានស្ដាប់ដំណឹងដូច្នោះ ទើបនាំគ្នាមកសួរម្បីអំពីទីឆ្ងាយ ។ ភិក្ខុចៅអាវាសទាំងឡាយ ធ្វើ

វត្តដល់ភិក្ខុទាំងនោះ ចូរទៅជិត ថ្វាយបង្គំភិក្ខុអាគន្តុកៈអ្នកចាស់ជាង ហើយអង្គុយ លុះកាន់យកអាសនៈក្នុងសម្នាក់របស់ភិក្ខុអ្នកមានវស្សាតិចជាងហើយក៏សួរថា លោកម្ចាស់ទាំងឡាយនឹងនៅក្នុងទីនេះ ឬនឹងទៅ ។ កាលលោកពោលថា នឹងទៅ ទើបពោលពាក្យមានជាអាទិ៍ថា សេនាសនៈជាទីសប្បាយភិក្ខាហាររកបានងាយ ហើយមិនប្រាថ្នាឲ្យទៅ ។ បើភិក្ខុនោះជាព្រះវិន័យ-ធរសោត ក៏ស្វាធ្យាយព្រះវិន័យក្នុងសម្នាក់របស់លោក បើលោកទ្រទ្រង់ព្រះសូត្រជាដើម ក៏ស្វាធ្យាយធម៌ក្នុងសម្នាក់របស់លោក ។ ភិក្ខុទាំងនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈដែលជាអាគន្តុកៈ រមែងសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយបាន ។ ភិក្ខុអាគន្តុកៈទាំងឡាយរមែងជាអ្នកពោលថា ពួកយើងមកដោយគិតថា ពួកយើងនឹងនៅត្រឹមតែមួយថ្ងៃពីរថ្ងៃ ។ តែពួកយើងក៏នៅបានដល់ ១០ វស្សា ២០ វស្សា ដើម្បីជាប្រយោជន៍ដល់ការនៅជាសុខសម្រាប់ភិក្ខុទាំងនេះ ។ គប្បីជ្រាបសេចក្តីវិនាស និងសេចក្តីចម្រើនក្នុងសេចក្តីនេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៣

# អដ្ឋកថា កម្មសូត្រទី ៤

## *អបរិហានិយធម៌ មានសេចក្តីមិនត្រេកអរក្នុងការងារជាដើម*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កម្មសូត្រទី ៤ ដូចតទៅនេះ ៖*

[២២] *បទថា **ន កម្មារាមា** (មិនត្រេកអរនឹងការងារ) បានដល់ ភិក្ខុពួកណាធ្វើការងារ មានចីវរ វត្តពន្ធចង្កេះ សំពត់ត្រងទឹក ធម្មក្រក ក្បៀង ជូតជើងជាដើមនោះពេញមួយថ្ងៃ នេះជាការហាមសេចក្តីពេញចិត្តរបស់ភិក្ខុទាំងនោះ ។ ចំណែកភិក្ខុពួកណា ក្នុងវេលាធ្វើការងារទាំងនោះ ក៏ធ្វើការងារទាំងនោះយ៉ាងនេះ ក្នុងវេលារៀនឧទ្ទេសក៏រៀនឧទ្ទេស ក្នុងវេលាស្វាធ្យាយក៏ស្វាធ្យាយ ក្នុងវេលាធ្វើវត្តត្រង់លានព្រះចេតិយក៏ធ្វើវត្តត្រង់លានព្រះចេតិយ ក្នុងវេលាធ្វើមនសិការក៏ធ្វើមនសិការ ភិក្ខុនោះឈ្មោះថា **អ្នកមិនត្រេកអរក្នុងការងារ** ។*

*ភិក្ខុណា ធ្វើការនិយាយគ្នាលេងដល់ពណ៌សម្បុររបស់ស្រី និងប្រុសជាដើម បណ្តាយយប់ និងថ្ងៃឲ្យកន្លងទៅ ជជែកគ្នាមិនដឹងចប់ក្នុងពាក្យនោះ ភិក្ខុនេះឈ្មោះថា **ត្រេកអរក្នុងការជជែក** ។ ម្យ៉ាងទៀត ភិក្ខុណារមែងពោល*

ធម៌ រមែងធ្វើយបញ្ហាទាំងយប់ទាំងថ្ងៃ ភិក្ខុនេះចាត់ជាអ្នកនិយាយគ្នាតិច ចាត់ជាអ្នកនិយាយដឹងនៅទីបញ្ចប់ដូចគ្នា ។ ព្រោះហេតុអ្វី ។ ព្រោះព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ លោកប្រជុំគ្នាហើយ ក៏មានកិច្ចដែលគួរធ្វើ ២ យ៉ាង គឺ ធម្មីកថា (ពោលធម៌) ឬការនៅស្ងៀមដោយភាពព្រះអរិយៈ ។

ភិក្ខុណា ឈរក៏ដោយ ដើរក៏ដោយ អង្គុយក៏ដោយ ត្រូវថីនមិទ្ធៈគ្របសង្កត់ ក៏លក់ទៅ ភិក្ខុនេះ ឈ្មោះថា **ត្រេកអរក្នុងការដេក** ។ ចំណែកភិក្ខុណា មានចិត្តចុះកាន់ភវង្គ ព្រោះការឈឺរបស់ករជកាយ ភិក្ខុនេះឈ្មោះថា **មិនត្រេកអរក្នុងការដេក** ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា អគ្គិវេស្សនៈ តថាគតនៅចាំបាន ក្នុងខែខាងចុងនៃរដូវក្តៅ តថាគតត្រឡប់ពីបិណ្ឌបាតខាងក្រោយភត្ត ឲ្យក្រាលសង្ឃាដី ៤ ជាន់ ដេកផ្អៀងខាងស្តាំ មានសតិសម្បជញ្ញៈក្នុងការលក់ ។

ភិក្ខុណា ស្និទ្ធស្នាលហើយយ៉ាងនេះ គឺ ជាបុគ្គលទី ២ សម្រាប់ភិក្ខុមួយរូប ជាបុគ្គលទី ៣ សម្រាប់ភិក្ខុពីររូប ជាបុគ្គលទី ៤ សម្រាប់ភិក្ខុ

បីរូប មិនមានសេចក្តីត្រេកអរក្នុងការនៅម្នាក់ឯង ភិក្ខុនេះឈ្មោះថា **ត្រេកអរក្នុងការស្និទ្ធស្នាលដោយពួកគណៈ** ។ ចំណែកភិក្ខុណាមានសេចក្តីត្រេកអរក្នុងការនៅម្នាក់ឯងប៉ុណ្ណោះ ក្នុងឥរិយាបថ ៤ ភិក្ខុនេះឈ្មោះថា **មិនត្រេកអរក្នុងការស្និទ្ធស្នាលដោយពួកគណៈ** ។

ភិក្ខុអ្នកប្រកបដោយសេចក្តីប្រាថ្នាការលើកសរសើរគុណ ដែលមិនមានក្នុងខ្លួន ជាបុគ្គលទ្រុស្តសីល ឈ្មោះថា **អ្នកមានសេចក្តីប្រាថ្នាលាមក** ។ ភិក្ខុពួកណាមានមិត្រអាក្រក់ មានសំឡាញ់អាក្រក់ ព្រោះបរិភោគរួមគ្នាក្នុងឥរិយាបថទាំង ៤ និងភិក្ខុពួកណា ជាមិត្រក្នុងភិក្ខុអាក្រក់ទាំងឡាយ ព្រោះបង្អោនទៅ ទោរទៅ ផ្អៀងទៅក្នុងបាបមិត្រនោះ ភិក្ខុពួកនោះឈ្មោះថា **មានមិត្រអាក្រក់ សំឡាញ់អាក្រក់** ។

បទថា **ឱរមត្តកេន (ត្រឹមតែតិចតួច)** បានដល់ មានប្រមាណតិចតួច គឺ មានប្រមាណតិច ។ បទថា **អន្តរា (ក្នុងចន្លោះ)** បានដល់ ក្នុងចន្លោះដែលមិនទាន់បានសម្រេចព្រះអរហត្តនេះ ។ បទថា **វោសានំ (សេចក្តីបន្ធូរបន្ថយ)** បានដល់ ការឈប់ គឺ មានសេចក្តីនឿយណាយថា ប៉ុណ្ណេះ

ក៏ល្មម ។ មានអធិប្បាយថា ភិក្ខុនឹងមិនដល់ភាពធូរថយដោយគុណត្រឹម

តែសីលបារិសុទ្ធិ ឈាន និងភាពជាព្រះសោតាបន្នជាដើមណាមួយ ត្រឹមណា

ភិក្ខុទាំងឡាយគប្បីប្រាថ្នាតែសេចក្តីចម្រើនបានយ៉ាងប្រាកដ មិនគប្បីប្រាថ្នា

សេចក្តីសាបសូន្យឡើយ ត្រឹមនោះ ។

ចប់អដ្ឋកថា កម្មសូត្រទី ៤

# អដ្ឋកថា សទ្ធិយសូត្រទី ៥

## អបរិហានិយធម៌ មានសទ្ធាជាដើម

[២៣] *សូត្រទី ៥ ងាយយល់ដូចមានសេចក្តីហើយនោះឯង ។*

ចប់អដ្ឋកថា សទ្ធិយសូត្រទី ៥

# អដ្ឋកថា ពោធិយសូត្រទី ៦

## *អបរិហានិយធម៌ គឺ ពោជ្ឈង្គៈ*

[២៤] *សូត្រ ៦ នេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ពោធិសូត្រទី ៦

# អដ្ឋកថា សញ្ញាសូត្រទី ៧

## អបរិហានិយធម៌ មានអនិច្ចសញ្ញាជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញាសូត្រទី ៧ ដូចតទៅនេះ ៖

[២៥] សញ្ញា មានអនិច្ចសញ្ញាជាដើម គឺ សញ្ញាដែលកើតព្រមជាមួយអនុបស្សនា មានអនិច្ចានុបស្សនាជាដើម ។

ចប់អដ្ឋកថា សញ្ញាសូត្រទី ៧

# អដ្ឋកថា សេក្ខសូត្រទី ៨

## ធម៌ជាហេតុវិនាស និងមិនវិនាសដល់ព្រះសេក្ខៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង សេក្ខសូត្រទី ៨ ដូចតទៅនេះ ៖

[២៦] ភិក្ខុពួកណារមែងនាំនូវភារៈទៅ ព្រោះជួយធ្វើកិច្ចការរបស់សង្ឃដែលកើតឡើងហើយឲ្យសម្រេច ព្រោះហេតុនោះ ភិក្ខុទាំងនោះឈ្មោះថា *ភារវាហិនោ* (ជាអ្នកទទួលភារៈ) ។ បទថា *តេ តេន បញ្ញាយិស្សន្តិ* (ភិក្ខុទាំងនោះនឹងទទួលខុសត្រូវដោយកិច្ចនោះ) បានដល់ ព្រះថេរៈទាំងនោះនឹងប្រាកដដោយកិច្ច ដែលសមគួរដល់ភាពជាព្រះថេរៈរបស់ខ្លួននោះឯង ។ បទថា *វាយោគំ អាបជ្ជតិ* (រមែងខ្វល់ខ្វាយដោយខ្លួនឯង) បានដល់ រមែងដល់ការប្រកប គឺ ផ្តើមធ្វើកិច្ចទាំងនោះដោយខ្លួនឯង ។

ចប់អដ្ឋកថា សេក្ខសូត្រទី ៨

# អដ្ឋកថា ហានិសូត្រទី ៩

## ធម៌ជាហេតុវិនាស និងមិនវិនាសដល់ឧបាសក

គប្បីជ្រាបវិនិច្ឆ័យក្នុង ហានិសូត្រទី ៩ ដូចតទៅនេះ ៖

[២៧] បទថា ភិក្ខុទស្សនំ ហាបេតិ (មិនបានឃើញភិក្ខុ) បានដល់ ខ្វះការឃើញភិក្ខុសង្ឃ ។ បទថា អធិសីលេ (ក្នុងអធិសីល) បានដល់ ក្នុងសីលដ៏ឧត្តម ពោលគឺ សីល ៥ និងសីល ១០ ។ បទថា ឥតោ ពហិទ្ធា (ខាងក្រៅសាសនានេះ) បានដល់ ក្រៅព្រះសាសនានេះ ។ បទថា ទក្ខិ-ណេយ្យំ គវេសតិ (ស្វែងរកស្រែបុណ្យ) បានដល់ ស្វែងរកបុគ្គលអ្នកទទួលទេយ្យធម៌ ។ បទថា តត្ថ ច បុព្វការំ ករោតិ (ធ្វើឧបការៈមុនក្នុងស្រែបុណ្យនោះ) បានដល់ ឲ្យទានតិរ្ថិយខាងក្រៅ (ព្រះសាសនា) ទាំងនោះហើយ ទើបថ្វាយទានដល់ភិក្ខុទាំងឡាយក្នុងខាងក្រោយ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ហើយនោះឯង ។

ចប់អដ្ឋកថា ហានិសូត្រទី ៩

# អដ្ឋកថា វិបត្តិសម្ភវសូត្រទី ១០

## *វិបត្តិ និងសម្បត្តិរបស់ឧបាសក*

[២៨] *សូត្រទី ១០ នេះ មានន័យងាយហើយ ។*

ចប់អដ្ឋកថា វិបត្តិសម្ភវសូត្រទី ១០

## ចប់វគ្គីវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ០៧ សូត្រ

# ទេវតាវគ្គវណ្ណនាទី ៤

## អដ្ឋកថា អប្បមាទសូត្រទី ១

*សេចក្តីគោរពក្នុងការមិនប្រមាទ*

[២៩] *សូត្រទី ១ នេះលោកមិនបាននិច្ឆ័យទុកទេ ។*

ចប់អដ្ឋកថា អប្បមាទសូត្រទី ១

# អដ្ឋកថា ហិរិមាសូត្រទី ២

*ភាពជាអ្នកគោរពក្នុងហិរិ*

[៣០] *សូត្រទី ២ នេះ មានន័យងាយហើយ ។*

ចប់អដ្ឋកថា ហិរិមាសូត្រទី ២

# អដ្ឋកថា បឋមសុវចសូត្រទី ៣

*ភាពជាអ្នកប្រដៅងាយ*

[៣១] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា បឋមសុវចសូត្រទី ៣

# អដ្ឋកថា ទុតិយសុវចសូត្រទី ៤

*ភាពជាអ្នកប្រដៅងាយ*

[៣២] *សូត្រនេះ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា ទុតិយសុវចសូត្រទី ៤

# អដ្ឋកថា បឋមសខាសូត្រទី ៥

## អង្គនៃមិត្រល្អ

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសខាសូត្រទី ៥ ដូចតទៅនេះ ៖*

*[៣៣] បទថា **ទុទ្ទទំ** (របស់ដែលឲ្យបានលំបាក) បានដល់ វត្ថុដែលមានតម្លៃច្រើនដែលលះបង់បានលំបាក ។ បទថា **ទុក្ករំ ករោតិ** (ធ្វើកិច្ចដែលធ្វើបានលំបាក) បានដល់ ធ្វើកិច្ចកម្មដែលធ្វើមិនបានងាយៗ ដើម្បីនឹងធ្វើ ។ បទថា **ទុក្ខមំ ខមតិ** (អត់ទ្រាំចំពោះក្នុងពាក្យ ដែលអត់ទ្រាំបានលំបាក) បានដល់ រមែងអត់ទ្រាំបានយ៉ាងលំបាក ដើម្បីប្រយោជន៍ដល់មិត្រ ។ បទថា **គុយ្ហមស្ស អាវិករោតិ** (ប្រាប់សេចក្តីកំបាំងរបស់ខ្លួនដល់មិត្រ) បានដល់ រមែងបើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់សំឡាញ់នោះ ។ បទថា **គុយ្ហមស្ស បរិគូហតិ** (បិទសេចក្តីកំបាំងរបស់មិត្រ) បានដល់ មិនប្រាប់សេចក្តីកំបាំងរបស់សំឡាញ់នោះ ដល់អ្នកដទៃទៀត ។ បទថា **ខីណេន នាតិមញ្ញតិ** (កាលមិត្រអស់ភោគសម្បត្តិ ក៏មិនមើលងាយ) បានដល់ កាលភោគសម្បត្តិរបស់សំឡាញ់នោះអស់ទៅហើយ ក៏មិន*

*មើលឆ្ងាយសំឡាញ់នោះ ព្រោះសេចក្ដីវិនាសនោះ គឺ មិននិយាយដើម និងមើលឆ្ងាយក្នុងសំឡាញ់នោះ ។*

ចប់អដ្ឋកថា បឋមសេក្ខសូត្រទី ៥

# អដ្ឋកថា ទុតិយសខាសូត្រទី ៦

## អង្គនៃមិត្រល្អ

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសខាសូត្រទី ៦ ដូចតទៅនេះ ៖*

[៣៤] *បទថា* ***វត្តា*** *(ជាអ្នកឈ្លាសក្នុងការនិយាយ) បានដល់ ជាអ្នកឈ្លាសក្នុងពាក្យសំដី ។ បទថា* ***វចនក្ខមោ*** *(ជាអ្នកអត់ទ្រាំចំពោះពាក្យសម្តី) បានដល់ ភិក្ខុរមែងអត់ធន់ចំពោះពាក្យសម្តី គឺ ធ្វើតាមឱវាទរបស់បុគ្គលនោះ ។ បទថា* ***គម្ភីរំ*** *(ជ្រៅ) បានដល់ ពាក្យដែលបិទបាំង កំបាំង ដែលអាស្រ័យឈាន អាស្រ័យវិបស្សនា មគ្គ ផល និងនិព្វាន ។*

ចប់អដ្ឋកថា ទុតិយសេក្ខសូត្រទី ៦

# អដ្ឋកថា បឋមបដិសម្ភិទាសូត្រទី ៧

## ធម៌ជាហេតុឲ្យបានបដិសម្ភិទា

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបដិសម្ភិទាសូត្រទី ៧ ដូចតទៅនេះ ៖

[៣៥] បទថា **ឥទម្មេ ចេតសោ លីនត្តំ** (ចិត្តរបស់យើងរួញ ប្រអួស) បានដល់ កាលចិត្តប្រអួសកើតឡើងហើយ ភិក្ខុរមែងដឹងតាម សភាវៈពិតថា ចិត្តរបស់អញនេះប្រអួស ។ ចិត្តត្រូវថីនមិទ្ធៈតាមរំខាន ឈ្មោះថា **អជ្ឈត្តំ សង្ខិត្តំ** (ចិត្តរួញរាខាងក្នុង) ។ ចិត្តដែលត្រាច់ទៅក្នុង កាមគុណ ៥ ឈ្មោះថា **ពហិទ្ធា វិក្ខិត្តំ** (ចិត្តរាយមាយទៅខាងក្រៅ) ។ បទថា **វេទនា** ជាដើម ព្រះមានព្រះភាគទ្រង់កាន់យកដោយអំណាចមូល នៃធម៌ដែលជាគ្រឿងយឺតយូរ ។ ព្រោះថា វេទនា ជាមូលនៃតណ្ហា ព្រោះ តណ្ហាកើតឡើងដោយអំណាចសេចក្តីសុខ , សញ្ញា ជាមូលនៃទិដ្ឋិ ព្រោះ ទិដ្ឋិកើតឡើងក្នុងអវិភូតារម្មណ៍ (អារម្មណ៍ដែលមិនប្រាកដច្បាស់) , វិតក្កៈ ជាមូលនៃមានះ ព្រោះអស្មិមានះកើតឡើងដោយអំណាចវិតក្កៈ ។ បទថា សប្បាយាសប្បាយេសុ (ជាទីសប្បាយ មិនជាទីសប្បាយ) បានដល់ ជា

*ឧបការៈ និងមិនជាឧបការៈ ។ បទថា* ***និមិត្តំ (និមិត្ត)*** *បានដល់ ហេតុ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយនោះឯង ។*

ចប់អដ្ឋកថា បឋមបដិសម្ភិទាសូត្រទី ៧

# អដ្ឋកថា ទុតិយបដិសម្ភិទាសូត្រទី ៨

## *ធម៌ជាហេតុឲ្យបានបដិសម្ភិទា*

[៣៦] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ទុតិយបដិសម្ភិទាសូត្រទី ៨

# អដ្ឋកថា បឋមវសសូត្រទី ៩

## ធម៌ដែលធ្វើចិត្តឲ្យនៅក្នុងអំណាច

[៣៧] *សូត្រទី ៩ នេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា បឋមវសសូត្រទី ៩

# អដ្ឋកថា ទុតិយវសសូត្រទី ១០

*ធម៌ដែលធ្វើចិត្តឲ្យនៅក្នុងអំណាច*

[៣៨] *សូត្រទី ១០ ក៏មានសេចក្ដីងាយទាំងអស់ហើយ ។*

ចប់អដ្ឋកថា ទុតិយវសសូត្រទី ១០

# អដ្ឋកថា បឋមនិទ្ទសសូត្រទី ១១

## *ភិក្ខុអ្នកជានិទ្ទសៈ*

[៣៩] *សូត្រទី ១១ នេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា បឋមនិទ្ទសសូត្រទី ១១

# អដ្ឋកថា ទុតិយនិទ្ទសសូត្រទី ១២

## *ធម៌ដែលធ្វើចិត្តឲ្យនៅក្នុងអំណាច*

[៤០] *សូត្រទី ១២ នេះ មានសេចក្តីងាយទាំងអស់ហើយ ។*

ចប់អដ្ឋកថា ទុតិយនិទ្ទសសូត្រទី ១២

## ចប់ទេវតាវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ០៣ សូត្រ

# មហាយញ្ញវគ្គវណ្ណនាទី ៥

## អដ្ឋកថា ចិត្តសូត្រទី ១

### ភូមិជាទីតាំងនៃចិត្ត

គប្បីជ្រាបវិនិច្ឆ័យក្នុង ចិត្តសូត្រទី ១ ដូចតទៅនេះ ៖

[៤១] បទថា **វិញ្ញាណដ្ឋិតិយោ (វិញ្ញាណដ្ឋិតិ)** ទីតាំងនៃបដិសន្ធិវិញ្ញាណ ។ បទថា **សេយ្យថាបិ (ដូចជា)** ជានិបាត ប្រើក្នុងអត្ថថាជាគ្រឿងឧបមា ។ អធិប្បាយថា ដូចមនុស្សទាំងឡាយ ។ ពិតហើយ បណ្ដាមនុស្សទាំងឡាយរកប្រមាណមិនបាន ក្នុងចក្រវាលប្រមាណមិនបាន សូម្បី ២ នាក់ នឹងឈ្មោះថាដូចគ្នា ដោយអំណាចពណ៌សម្បុរ ទ្រង់ទ្រាយជាដើមមិនមាន ។ សូម្បីមនុស្សពួកណា ក្នុងទីណាៗ ជាបងប្អូនកូនភ្លោះ រមែងដូចគ្នាដោយពណ៌ និងទ្រង់ទ្រាយ សូម្បីមនុស្សទាំងនោះក៏នៅមានសេចក្ដីផ្សេងៗ គ្នា ក្នុងពេលក្រលេកមើល បែរមើល និយាយ សើច ដើរ និងឈរជាដើមនោះឯង ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា **នានត្តកាយា (មានកាយផ្សេងគ្នា)** ។ ក៏បដិសន្ធិសញ្ញារបស់សត្វទាំងនោះ ជាតិហេតុកៈ

ក៏មាន ជាទុហេតុកៈក៏មាន ជាអហេតុកៈក៏មាន ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា **នានត្តសញ្ញិនោ** (មានសញ្ញាផ្សេងគ្នា) ។ បទថា **ឯកច្ចេ ច ទេវា** (ទេវតាពួកខ្លះ) បានដល់ ទេវតាជាន់កាមាវចរៈ ៦ ជាន់ ។ ពិតហើយ ក្នុងទេវតាជាន់កាមាវចរៈ ៦ ជាន់នោះ ទេវតាពួកខ្លះមានកាយខៀវ ពួកខ្លះមានកាយលឿងជាដើម ។ ចំណែកសញ្ញារបស់ទេវតាទាំងនោះ ជាទុហេតុកៈក៏មាន ជាតិហេតុកៈក៏មាន ជាអហេតុកៈមិនមាន ។ បទថា **ឯកច្ចេ ច វិនិបាតិកា** (និងវិនិបាតិកសត្វពួកខ្លះ) បានដល់ សត្វដែលផុតពីអបាយ ៤ មានជាអាទិ៍យ៉ាងនេះ គឺ ឧត្តរមាតាយក្ខិណី បិយង្កករមាតាយក្ខិណី ផុស្សមិត្តាយក្ខិណី ធម្មគុត្តាយក្ខិណី និងវេមាណិកប្រេតពួកដទៃ ។ ក៏សត្វពួកនោះ មានកាយផ្សេងគ្នាដោយសម្បុរស សម្បុរខ្មៅ សម្បុរលឿង និងសម្បុរស្រគាំជាដើម និងដោយរាងស្គម ធាត់ ទាប និងខ្ពស់ ។ សូម្បីសញ្ញាក៏ផ្សេងគ្នា ដូចសញ្ញារបស់មនុស្ស ជាទុហេតុកៈ តិហេតុកៈ និងអហេតុកៈ ។ តែសត្វទាំងនោះ មានអំណាចមិនច្រើនដូចទេវតា មានអំណាចតិច មានអាហារ និងគ្រឿងស្លៀកដណ្តប់រកបានលំបាក

នៅជាទុក្ខ ដូចមនុស្សអ្នកក្រលំបាក ពួកខ្លះបានទទួលទុក្ខវេទនាខាងរនោច មានសុខវេទនាខាងខ្នើត ព្រោះហេតុនោះ ទើបត្រាស់ថា វិនិបាតិកសត្វ ព្រោះប្រាសចាកពីគំនរសុខ ។ ក៏ក្នុងសត្វទាំងនោះ សត្វពួកណាជាតិ-ហេតុកៈ សត្វទាំងនោះរមែងត្រាស់ដឹងធម៌បាន ដូចបិយង្ករមាតាយក្ខិណី ជាដើម ។

បទថា **ព្រហ្មកាយិកា (ព្រហ្មកាយិកា)** បានដល់ ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតៈ មហាព្រហ្ម ។ បទថា **បឋមាភិនិព្វត្តា (អ្នកកើតក្នុងភូមិបឋមឈាន)** បានដល់ សត្វសូម្បីទាំងអស់នោះ កើតឡើងដោយបឋម-ឈាន ។ ពិតហើយ ព្រហ្មបារិសជ្ជាកើតឡើងដោយបឋមឈានទន់ខ្សោយ មានអាយុប្រមាណត្រឹមចំណែកទី ៣ នៃកប្ប ។ ព្រហ្មបុរោហិតៈ កើតឡើងដោយបឋមឈានជាកណ្តាល មានអាយុប្រមាណពាក់កណ្តាលកប្ប តែមានកាយធំជាងព្រហ្មបារិសជ្ជាទាំងនោះ មហាព្រហ្មកើតឡើងដោយបឋម-ឈានយ៉ាងប្រណីត មានអាយុប្រមាណមួយកប្ប មានកាយធំជាងព្រហ្ម-បុរោហិតទាំងនោះ ។ ដូច្នោះ ព្រហ្មទាំងនោះ គប្បីជ្រាបថា **នានត្តកាយា**

ឯកត្តសញ្ញិនោ (មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា) ព្រោះមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដោយអំណាចបឋមឈាន ។ សត្វក្នុងអបាយ-ភូមិ ៤ ក៏ដូចគ្នានឹងព្រហ្មទាំងនោះ ។ ពិតណាស់ ក្នុងនរកទាំងឡាយ សត្វពួកខ្លះ មានអត្តភាពមួយគាវុត ពួកខ្លះកន្លះយោជន៍ ពួកខ្លះមួយយោជន៍ ។ តែអត្តភាពរបស់ព្រះទេវទត្តមាន ១០០ យោជន៍ ។ សូម្បីសត្វតិរច្ឆានទាំងឡាយពួកខ្លះ មានអត្តភាពតូច ពួកខ្លះមានអត្តភាពធំ ។ សូម្បីក្នុងបេត្តិ-វិស័យទាំងឡាយ ពួកខ្លះមានអត្តភាព ៦០ ហត្ថ ពួកខ្លះ ៨០ ហត្ថ ពួកខ្លះមានពណ៌សម្បុរល្អ ពួកខ្លះមានពណ៌សម្បុរអាក្រក់ ។ ពួកកាលកញ្ចិក-អសុរក៏ដូចគ្នា ។ មួយវិញទៀត ក្នុងពួកអសុរទាំងនោះ ពួកឈ្មោះថា ទីឃ-បិដ្ឋិកអសុរ មានអត្តភាព ៦០ យោជន៍ ។ ក៏សញ្ញារបស់អសុរសូម្បីទាំងអស់ ជាអហេតុកអកុសលវិបាកប៉ុណ្ណោះ ។ ដូច្នោះ សត្វសូម្បីកើតក្នុងអបាយភូមិ រមែងរាប់ថា មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា ។

បទថា អាភស្សរា (ជាន់អាភស្សរៈ) មានវិនិច្ឆ័យដូច្នេះ ព្រហ្មឈ្មោះថា អាភស្សរា ព្រោះព្រហ្មទាំងនេះមានរស្មីផ្សាយចេញ គឺ ផ្សាយ

ចេញអំពីសរីរៈដាច់ធ្លាក់ចុះដូចផ្កាភ្លើង នៃគប់ភ្លើងដូច្នោះ ។ ក្នុងអាភស្សរ-ព្រហ្មទាំងនោះ ព្រហ្មអ្នកចម្រើនទុតិយឈាន និងតតិយឈាន ទាំង ២ ទន់ខ្សោយក្នុងបញ្ចកន័យ ហើយកើតឡើង ឈ្មោះថា **បរិត្តាភាព្រហ្ម** ។ បរិត្តាភាព្រហ្មទាំងនោះ មានអាយុប្រមាណ ២ កប្ប ។ អ្នកចម្រើនទុតិយ-ឈាន និងតតិយឈានយ៉ាងកណ្តាលកើតឡើង ឈ្មោះថា **អប្បមាណា-ភាព្រហ្ម** ។ អប្បមាណាភាព្រហ្មទាំងនោះ មានអាយុប្រមាណ ៤ កប្ប ។ អ្នកចម្រើនទុតិយឈាន និងតតិយឈានដ៏ប្រណីតកើតឡើង ឈ្មោះថា **អាភស្សរព្រហ្ម** ។ អាភស្សរព្រហ្មទាំងនោះ មានអាយុប្រមាណ ៨ កប្ប ។ ក្នុងទីនេះ ទ្រង់កាន់យកព្រហ្មទាំងអស់នោះ ដោយការកំណត់យ៉ាងឧក្រិដ្ឋ ។ ពិតហើយ ព្រហ្មទាំងអស់នោះ មានកាយដ៏ដូចគ្នា ចំណែកសញ្ញាផ្សេងគ្នា គឺ មិនមានវិតក្កមានត្រឹមតែវិចារៈខ្លះ មិនមានវិតក្កវិចារៈខ្លះ ។

បទថា **សុភកិណ្ហា (សុភកិណ្ហៈ)** បានដល់ ព្រហ្មទាំងឡាយមានរស្មីភ្លឺចិញ្ចាចទូទៅ អធិប្បាយថា មានរស្មីនៃសរីរៈស្រស់ស្អាត ជាដុំក្រាស់ ។ ពិតហើយ សុភកិណ្ហព្រហ្មទាំងនេះ មានរស្មីមិនដាច់ទៅដូចរបស់អាភស្សរ-

ព្រហ្ម និងសុភកិណ្ហព្រហ្ម មានអាយុ ១៦ កប្ប ៣២ កប្ប និង ៦៤ កប្ប ដោយអំណាចចតុត្ថឈានទន់ខ្សោយ យ៉ាងកណ្តាល និងយ៉ាងប្រណីត ។ ដូច្នោះ ព្រហ្មទាំងអស់នោះ គប្បីជ្រាបថាជា **ឯកត្តកាយា** (មានកាយដូចគ្នា) និង **ឯកត្តសញ្ញិនោ** (មានសញ្ញាដូចគ្នា) ដោយសញ្ញាក្នុងចតុត្ថឈាន ។

ចំណែកវេហប្ផលាព្រហ្ម រមែងរាប់ចូលក្នុងវិញ្ញាណដ្ឋិតិទី ៤ នោះឯង ។ ពួកអសញ្ញីសត្វ រមែងមិនសង្គ្រោះចូលក្នុងវិញ្ញាណដ្ឋិតិនេះ ព្រោះមិនមានវិញ្ញាណ តែសង្គ្រោះចូលក្នុងសត្តាវាសទាំងឡាយ ។ សុទ្ធាវាសព្រហ្ម តាំងនៅក្នុងចំណែកវិវដ្ដៈ (ចំណែកចម្រើន) រមែងមិនមានគ្រប់កាលវេលាទេ គឺ មិនកើតឡើងក្នុងលោក ដែលសូន្យចាកព្រះពុទ្ធអស់សែនកប្បខ្លះ មួយអសង្ខេយ្យខ្លះ កាលព្រះពុទ្ធទាំងឡាយទ្រង់ឧប្បត្តិឡើងហើយនោះ រមែងកើតឡើងខាងក្នុងខេត្ត កំណត់អាយុ ១៦.០០០ កប្ប រមែងដូចជាបន្ទាយស្នាក់នៅរបស់ព្រះមានព្រះភាគ ដែលទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបមិនរាប់ចូលក្នុងវិញ្ញាណដ្ឋិតិ និងសត្តាវាស ។ ចំណែកព្រះមហាថេរៈពោលថា សូម្បីព្រហ្មជាន់សុទ្ធាវាស ក៏រមែងរាប់ចូល

ក្នុងវិញ្ញាណដ្ឋិតិទី ៤ និងសត្តាវាសទី ៤ ដោយសូត្រនេះថា សារីបុត្រ ក្រៅអំពីទេវតាជាន់សុទ្ធាវាស ក៏សត្តាវាសដែលតថាគតមិនធ្លាប់អាស្រ័យនៅរហូតអស់កាលយូរយ៉ាងនេះ រមែងមិនមានឡើយ ។ ពាក្យនោះក៏ព្រមទទួលហើយ ព្រោះមិនមានព្រះសូត្រជំទាស់ ។ នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា មានវិញ្ញាណក៏មិនមែន មិនមានវិញ្ញាណក៏មិនមែន ព្រោះសូម្បីវិញ្ញាណក៏ជារបស់ល្អិត ដូចសញ្ញា ព្រោះដូច្នោះ នេវសញ្ញានាសញ្ញាយតនៈនោះ ទើបមិនត្រាស់ទុកក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ។

ចប់អដ្ឋកថា ចិត្តសូត្រទី ១

# អដ្ឋកថា បរិក្ខារសូត្រទី ២

## បរិក្ខារនៃសមាធិ

គប្បីជ្រាបវិនិច្ឆ័យក្នុង បរិក្ខាសូត្រទី ២ ដូចតទៅនេះ ៖

[៤២] បទថា *សមាធិបរិក្ខារា (បរិក្ខានៃសមាធិ)* បានដល់ អង្គប្រកបនៃសមាធិសម្បយុត្តដោយមគ្គ ។

ចប់ អដ្ឋកថា បរិក្ខារសូត្រទី ២

# អដ្ឋកថា បឋមអគ្គិសូត្រទី ៣

## ពោលដោយភ្លើង

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអគ្គិសូត្រទី ៣ ដូចតទៅនេះ ៖

[៤៣] កិលេសទាំងឡាយ មានរាគៈជាដើមសូម្បីទាំងអស់ ឈ្មោះថា **អគ្គិ** (ភ្លើង) ដោយអត្ថថា តាមដុត ។ ចំណែកក្នុងបទជាដើមថា **អាហុនេយ្យគ្គិ** (ភ្លើង គឺ អាហុនេយ្យបុគ្គល) នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ សក្ការៈ លោកហៅថា អាហុនៈ ក្នុងបទថា **អាហុនេយ្យ** នេះ ជនពួកណារមែងគួរដល់អាហុនៈ ហេតុនោះ ជនទាំងនោះឈ្មោះថា **អាហុនេយ្យបុគ្គល** (ជនអ្នកគួរដល់អាហុនៈ) ។ ពិតណាស់ មាតា និងបិតាទាំងឡាយរមែងគួរដល់អាហុនៈ ព្រោះលោកទាំងពីរជាអ្នកមានឧបការៈច្រើនដល់បុត្រទាំងឡាយ បុត្រទាំងឡាយអ្នកបដិបត្តិខុសក្នុងមាតា និងបិតាទាំង ២ នោះ រមែងកើតក្នុងអបាយ មាននរកជាដើម ព្រោះហេតុនោះ សូម្បីមាតា និងបិតាមិនបានតាមដុតក៏ពិត តែលោកទាំង ២ ប៉ុណ្ណោះ ក៏នៅជាបច្ច័យដល់ការតាមដុត ព្រោះហេតុនោះ លោកទើបហៅមាតាបិតាថា **ភ្លើង**

**គឺអាហុនេយ្យបុគ្គល** ដោយអត្ថថា តាមដុតនោះឯង ។ ក៏ម្ចាស់ផ្ទះ លោកហៅថា គហបតី ពិតហើយ គហបតីនោះ មានឧបការៈច្រើនដល់មាតុគ្រាមដោយការប្រគល់ទីដេក សំលៀកបំពាក់ និងគ្រឿងប្រដាប់ជាដើម មាតុ-គ្រាមអ្នកក្បត់ចិត្តពីស្វាមីនោះ រមែងកើតក្នុងអបាយ មាននរកជាដើម ព្រោះហេតុនោះ ស្វាមីនោះ ក៏ហៅថា **គហបតគ្គិ (ភ្លើងគឺគហបតី)** ដោយអត្ថថា តាមដុត ដោយន័យមុននោះឯង ។

ក៏បច្ច័យ ៤ ឈ្មោះថា ទក្ខិណា ក្នុងបទថា **ទក្ខិណេយ្យគ្គិ (ភ្លើងគឺទក្ខិណេយ្យបុគ្គល)** នេះ ភិក្ខុសង្ឃ ឈ្មោះថា ទក្ខិណេយ្យបុគ្គល (បុគ្គលគួរដល់ទក្ខិណា) ពិតណាស់ ភិក្ខុសង្ឃនោះ រមែងជាអ្នកមានឧបការៈច្រើនដល់គ្រហស្ថទាំងឡាយ ដោយការប្រកបទុក ក្នុងកល្យាណធម៌ទាំងឡាយមានជាអាទិ៍យ៉ាងនេះ គឺ ក្នុងសរណៈ ៣ សីល ៥ សីល ១០ ការទំនុកបម្រុងមាតា និងបិតា ការទំនុកបម្រុងសមណៈ និងព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ គ្រហស្ថអ្នកបដិបត្តិខុសក្នុងភិក្ខុសង្ឃនោះ ជេរបរិភាសភិក្ខុសង្ឃ រមែងកើតក្នុងអបាយទាំងឡាយ មាននរកជាដើម ព្រោះហេតុ

*នោះ ភិក្ខុសង្ឃនោះ ទើបហៅថា ទក្ខិណេយ្យគ្គិ (ភ្លើង គឺ ទក្ខិណេយ្យ-បុគ្គល) ព្រោះអត្ថថា តាមដុត ដោយន័យមុននោះឯង ។ ភ្លើងតាមប្រក្រតីដែលកើតអំពីឈើ ឈ្មោះថា កដ្ឋគ្គិ (ភ្លើងកើតអំពីអុស) ។*

ចប់អដ្ឋកថា បឋមអគ្គិសូត្រទី ៣

# អដ្ឋកថា ទុតិយអគ្គិសូត្រទី ៤

## ពោលដោយភ្លើង

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអគ្គិសូត្រទី ៤ ដូចតទៅនេះ ៖*

[៤៤] *បទថា* ***ឧគ្គតសរីរស្ស (ឧគ្គតសរីរៈ)*** *បានដល់ បានឮថា ព្រាហ្មណ៍មហាសាលនោះ ជាអ្នកមានអត្តភាពខ្ពស់ ដល់សារសម្បត្តិដោយភោគៈ ព្រោះហេតុនោះ ទើបប្រាកដឈ្មោះថា ព្រាហ្មណ៍អ្នកមានខ្លួនខ្ពស់ ។ បទថា* ***ឧបក្ខដោ (ត្រៀមបម្រុង)*** *បានដល់ ចាត់ចែង ។ បទថា* ***ថូណូបនីតានិ (ត្រូវនាំចូលទៅចងទុកត្រង់បង្គោល)*** *បានដល់ នាំចូលទៅកាន់សសរពោលគឺ បង្គោលសម្រាប់បូជាយញ្ញ ។ បទថា* ***យញ្ញត្ថាយ (ដើម្បីបូជាយញ្ញ)*** *បានដល់ ដើម្បីប្រយោជន៍ដល់ការសម្លាប់បូជាយញ្ញ ។ បទថា* ***ឧបសង្កមិ (បានចូលទៅគាល់)*** *បានដល់ បានឮថា ព្រាហ្មណ៍នោះត្រៀមគ្រឿងប្រកបយញ្ញទាំងអស់នោះ ហើយគិតថា បានឮថា ព្រះសមណគោតមទ្រង់មានបញ្ញាច្រើន ព្រះអង្គនឹងត្រាស់សរសើរយញ្ញរបស់យើងឬហ្ន៎ ឬថាត្រាស់តិះដៀល យើងទូលសួរហើយនឹងដឹង ព្រោះហេតុនោះ ទើបចូលទៅ*

គាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ បទថា **អគ្គិស្ស អាធានំ (ការតាំងទុកនូវភ្លើង)** បានដល់ ការតាំងទុកនូវភ្លើងដែលជាមង្គល ៩ ប្រការ ដើម្បីបូជាយញ្ញ ។ បទថា **សព្វេន សព្វំ (ប្រការទាំងអស់)** នេះ ឧគ្គតសរីរ-ព្រាហ្មណ៍សម្តែងថា សូត្រទាំងអស់ដែលយើងបានស្តាប់មកហើយ រមែងប្រៀបធៀបគ្នាបាន រមែងតែមួយដូចគ្នានឹងសូត្រទាំងអស់ ។

បទថា **សត្ថានិ (សស្ត្រា)** បានដល់ ដែលឈ្មោះថា សស្ត្រា ព្រោះជាគ្រឿងប្រហារ ដោយអត្ថថា ជាគ្រឿងបៀតបៀន ។ បទថា **សយំ បឋមំ សមារភតិ (រមែងប្រុងប្រៀបខ្លួនឯងជាមុន)** បានដល់ ផ្តើមដោយខ្លួនឯងមុនតែម្យ៉ាង ។ បទថា **ហញ្ញន្តុ (ត្រូវសម្លាប់)** បានដល់ ត្រូវប្រហារ ។ បទថា **បរិហាតព្វា (បរិហារ)** បានដល់ គប្បីបដិបត្តិ។ បទថា **ឥតោហយំ (ព្រោះបុគ្គលកើតមកអំពីមាតាបិតានេះ)** បានដល់ ព្រោះបុគ្គលនេះកើតអំពីមាតាបិតានេះ ។ បទថា **អាហុតោ (មក)** បានដល់ មកហើយ ។ បទថា **សម្ភូតោ (កើត)** បានដល់ កើតឡើងហើយ ។ បទថា **អយំ វុច្ចតិ ព្រាហ្មណ គហបតគ្គិ (នេះហៅថាភ្លើង គឺ គហបតី)** បានដល់ ពួកបុត្រ និងភរិយា

ជាដើមនេះ ហៅថា ភ្លើង គឺ គហបតី ព្រោះដូចជាគហបតី ដូចជាម្ចាស់ផ្ទះ ត្រាច់ទៅ ។ បទថា **អត្តានំ (ចិត្ត)** បានដល់ ចិត្ត ។ បទថា **ទមេន្តិ (ហ្វឹកហាត់)** បានដល់ រមែងហ្វឹកហាត់ ដោយការហ្វឹកហាត់ឥន្រ្ទិយ ។ បទថា **សមេន្តិ (ធ្វើ... ឲ្យស្ងប់)** បានដល់ ធ្វើចិត្តឲ្យស្ងប់ ដោយការស្ងប់រាគៈជាដើម ។ បទថា **បរិនិព្វាបេន្តិ (ធ្វើ... ឲ្យត្រជាក់)** ដោយការឲ្យកិលេស មានរាគៈជាដើមរលត់អស់ទៅ ។ បទថា **និក្ខិបិតព្វោ (គប្បីរក្សាទុក)** បានដល់ គប្បីរក្សាទុកដោយប្រការដែលនឹងមិនឲ្យវិនាស ។ បទថា **ឧបវាយតំ (ទទួល)** បានដល់ បក់ផ្លិតទៅ ។ ក៏ព្រាហ្មណ៍ កាលពោលយ៉ាងនេះហើយ ទើបឲ្យជីវិតដល់សត្វទាំងអស់នោះ ហើយបំផ្លាញកោងបូជាយញ្ញ នឹងជាអណ្តូងទឹកក្នុងសាសនារបស់ព្រះសាស្តានោះឯង ។

ចប់អដ្ឋកថា ទុតិយអគ្គិសូត្រទី ៤

# អដ្ឋកថា បឋមសញ្ញាសូត្រទី ៥

## *សញ្ញាដែលចម្រើនហើយមានផលច្រើន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសញ្ញាសូត្រទី ៥ ដូចតទៅនេះ ៖*

[៤៥] *បទថា **អមតោគធា** (ឈមទៅរកព្រះនិព្វាន) បានដល់ តាំងនៅក្នុងព្រះនិព្វាន ។ បទថា **អមតបរិយោសានា** (មានអមតៈជាទីបំផុត) បានដល់ មានព្រះនិព្វានជាទីបំផុត ។*

ចប់អដ្ឋកថា បឋមសញ្ញាសូត្រទី ៥

# អដ្ឋកថា ទុតិយសញ្ញាសូត្រទី ៦

## *សញ្ញាដែលចម្រើនហើយមានផលច្រើន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសញ្ញាសូត្រទី ៦ ដូចតទៅនេះ ៖*

[៤៦] *បទថា* ***មេថុនធម្មសមាបត្តិយា*** *(ចាកការជួបប្រសព្វដោយមេថុនធម្ម)* បានដល់ ចាកការព្រមព្រៀងដោយមេថុនធម្ម ។ *បទថា* ***ន្ហារុទទ្ទុលំ*** *(ទងសរសៃ)* បានដល់ សរសៃពួរ ឬសរសៃធ្លង ។ *បទថា* ***អនុសន្ទតិ*** *(រមែងហូរទៅ)* បានដល់ ប្រព្រឹត្តទៅ ។ *បទថា* ***នត្ថិ មេ បុព្វេនាបរំ វិសេសោ*** *(កាលខាងដើមនឹងកាលខាងចុងរបស់អញមិនទាន់ប្លែកគ្នាទេ)* បានដល់ ការប្លែកគ្នាក្នុងវេលាមុននៅមិនទាន់បានចម្រើនសញ្ញាជាមួយវេលាដែលបានចម្រើនសញ្ញាហើយរបស់អញ មិនមានទេ ។ *បទថា* ***លោកចិត្តេសុ*** *(ក្នុងការវិចិត្រនៃលោក)* បានដល់ ការវិចិត្រក្អែករបស់លោក ពោលគឺ លោកសន្និវាសដែលប្រកបដោយត្រៃធាតុ ។ *បទថា* ***អាលស្សេ*** *(ក្នុងការខ្ជិលច្រអូស)* បានដល់ ក្នុងភាពជាអ្នកខ្ជិលច្រអូស ។ *បទថា* ***វិស្សដ្ឋិយេ*** *(ទម្រន់)* បានដល់ ក្នុងការកន្ទ្រងហួស ។ *បទថា* ***អននុយោគេ***

(ក្នុងការមិនប្រកបសេចក្ដីព្យាយាម) បានដល់ មិនដាក់ចិត្តប្រកបសេចក្ដីព្យាយាម ។ បទថា **អហង្ការមមង្ការ មានាបគតំ** (ប្រាសចាកទិដ្ឋិថា យើង តណ្ហាថា របស់យើង និងការប្រកាន់ខ្លួន) បានដល់ ប្រាសចាកទិដ្ឋិថា ជាយើង ប្រាសចាកតណ្ហាថា របស់យើង ចាកមានះ ៩ យ៉ាង ។ បទថា **វិធាសមតិក្កន្តំ** (កន្លងបង់នូវកិលេស ៣ ប្រការ) បានដល់ កន្លងបង់មានះ ៣ យ៉ាង ។ បទថា **សន្តំ** (ស្ងប់រម្ងាប់) បានដល់ ស្ងប់ចាកកិលេសដែលជាសត្រូវដល់ការចម្រើនសញ្ញានោះ ។ បទថា **សុវិមុត្តំ** (ផុតស្រឡះដោយប្រពៃ) បានដល់ រួចផុតដោយល្អ ដោយវិមុត្តិ ៥ ។

ចប់អដ្ឋកថា ទុតិយសញ្ញាសូត្រទី ៦

# អដ្ឋកថា មេថុនសូត្រទី ៧

## *មេថុនសំយោគ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេថុនសូត្រទី ៧ ដូចតទៅនេះ ៖*

*[៤៧] បទថា **ឧបសង្កមិ** (បានចូលទៅគាល់) បានដល់ ជាណុ-ស្សោណិព្រាហ្មណ៍បរិភោគអាហារព្រឹកហើយ ហែហមទៅដោយទាសៈ និងកម្មករ បានចូរទៅគាល់ ។ បទថា **ភវំបិ នោ** (សូម្បីលោក) កែជា **ភវំបិ នុ** ។ បទថា **ព្រហ្មចារី បដិជានាតិ** (ក៏ទ្រង់ប្ដេជ្ញាថាជាព្រហ្មចារីឬ) បានដល់ ព្រាហ្មណ៍នោះសួរថា ព្រះគោតមអ្នកដ៏ចម្រើនប្ដេជ្ញាការប្រព្រឹត្តព្រហ្ម-ចរិយៈយ៉ាងនេះថា យើងជាអ្នកប្រព្រឹត្តព្រហ្មចរិយៈឬ ។ បានឮថា ព្រាហ្មណ៍មានការគិតយ៉ាងនេះថា ព្រាហ្មណ៍ទាំងឡាយរៀនវេទក្នុងលទ្ធិរបស់ព្រាហ្មណ៍ប្រព្រឹត្តព្រាហ្មចរិយៈអស់ ៤៨ ឆ្នាំ ឯព្រះសមណគោតមកាលនៅគ្រប់គ្រងផ្ទះ បានអភិរម្យជាមួយនាងស្រីស្នំ ៣ ពួក ក្នុងប្រសាទទាំង ៣ ឥឡូវព្រះសមណគោតមនឹងត្រាស់យ៉ាងណាហ្ន៎ ដូច្នេះហើយ ទើបបានសួរយ៉ាងនេះ គឺ សំដៅយកសេចក្ដីនេះ ។ លំដាប់នោះឯង ព្រះមានព្រះភាគកាល*

ទ្រង់បន្លឺសីហនាទ សំដៅយកសូម្បីត្រឹមតែវិតក្កៈ ក៏មិនកើតឡើងប្រារព្ធសុខក្នុងរាជសម្បត្តិ ឬការមានព្រមដោយស្រីរបាំក្នុងប្រសាទទាំងឡាយ ព្រោះព្រះអង្គទ្រង់ប្រព្រឹត្តសេចក្តីព្យាយាម ៦ វស្សា ក្នុងវេលាដែលព្រះអង្គទ្រង់នៅមានកិលេស ដូចមនុស្សប្រចាប់ក្បាលពស់វែកដោយមន្ត និងដូចយកជើងជាន់លើ.កសត្រូវ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **យញ្ហិ តំ ព្រាហ្មណ** (ព្រាហ្មណ៍... នរណា) ។

បណ្តាបទទាំងនោះ បទថា **ទ្វយទ្វយសមាបត្តឹ** (ភាពជាគូៗ) បានដល់ ការៈដែលបដិបត្តិគ្នានិងគ្នាជាគូៗ ។ បទថា **ទុក្ខស្មា** (ចាកកងទុក្ខ) បានដល់ ចាកទុក្ខក្នុងវដ្តៈទាំងអស់ ។ បទថា **សញ្ជគ្ឃតិ** (សើចលេង) បានដល់ សម្តែងភាពញឹមញញែម ។ បទថា **សំកីឡតិ** (រមែងចំអកឡកឡឺយ) បានដល់ ធ្វើការកំប្លែងលេង ។ បទថា **សំកេឡាយតិ** (សើចក្អាកក្អាយ) បានដល់ សើចសប្បាយក្អាកក្អាយ ។ បទថា **ចក្ខុនា ចក្ខុំ** (ចក្ខុ “នៃមាតុគ្រាម” ដោយចក្ខុរបស់ខ្លួន) បានដល់ ប្រើភ្នែករបស់ខ្លួនសម្លឹងភ្នែករបស់ស្រីនោះ ។ បទថា **តិរោកុឌ្ឍំ វា តិរោបាការំ វា** (ខាង

*ក្រៅជញ្ជាំងក្ដី ខាងក្នុងជញ្ជាំងក្ដី)* បានដល់ ត្រង់ជញ្ជាំងផ្ទះនោះ ឬកំពែងនោះ ។ បទថា *ទេវោ (ជាទេវតា)* បានដល់ រាជានៃទេវតាអង្គណាមួយ ។ បទថា *ទេវញ្ញតរោ (ទេវតាអង្គណាមួយ)* បានដល់ ទេវបុត្រអង្គណាមួយ ។ បទថា *អនុត្តរំ សម្មាសម្ពោធឹ (អនុត្តរសម្មាសម្ពោធិញ្ញាណ)* បានដល់ ព្រះអរហត្ត និងព្រះសព្វញ្ញុតញ្ញាណ ។

ចប់អដ្ឋកថា មេថុនសូត្រទី ៧

# អដ្ឋកថា សញ្ញោគសូត្រទី ៨

## ការទាក់ទងស្ត្រី និងបុរស

គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញោគសូត្រទី ៨ ដូចតទៅនេះ ៖

[៤៨] បទថា *សញ្ញោគវិសញ្ញោគំ (ជាសំញោគៈ និងវិសំញោគៈ)* បានដល់ ដែលធ្វើការទាក់ទង និងមិនទាក់ទងឲ្យសម្រេច ។ បទថា *ធម្មបរិយាយំ (ធម្មបរិយាយ)* បានដល់ ជាហេតុនៃធម៌ ។ បទថា *អជ្ឈត្តំ ឥត្ថិន្ទ្រិយំ (សភាពរបស់ស្ត្រីក្នុងខាងក្នុង)* បានដល់ ភាពជាស្ត្រីខាងក្នុងរបស់ខ្លួន ។ បទថា *ឥត្ថី កុត្តំ (កិរិយា)* បានដល់ កិរិយារបស់ស្រី ។ បទថា *ឥត្ថាកប្បំ (ឫកពា)* បានដល់ មារយាទរបស់ស្ត្រី មានការស្លៀក និងការដណ្តប់ជាដើម ។ បទថា *ឥត្ថីវិធំ (បែបផែននៃស្ត្រី)* បានដល់ ការប្រកាន់ខ្លួនរបស់ស្ត្រី ។ បទថា *ឥត្ថីច្ឆន្ទំ (សេចក្តីប្រាថ្នានៃស្ត្រី)* បានដល់ សេចក្តីពេញចិត្ត អធ្យាស្រ័យរបស់ស្ត្រី ។ បទថា *ឥត្ថិស្សរំ (សំឡេងនៃស្ត្រី)* បានដល់ សំឡេងរបស់ស្ត្រី ។ បទថា *ឥត្ថាលង្ការំ (អលង្ការនៃស្ត្រី)* បានដល់ គ្រឿងតាក់តែងរបស់ស្ត្រី ។ សូម្បីក្នុង *បុរិសិន្ទ្រិយំ*

*(សភាពរបស់បុរស)* ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **ពហិទ្ធា សញ្ញោគំ** *(សមាគមជាមួយបុរសក្នុងខាងក្រៅ)* បានដល់ សមាគមជាមួយបុរស ។ បទថា **អតិវត្តតិ** *(ទើបកន្លងផុត)* បានដល់ *(កន្លងផុតភាវៈនៃស្ត្រី និង បុរស)* ព្រោះបានសម្រេចអរិយមគ្គដោយវិបស្សនាមានកម្លាំង ដែលពោលទុកយ៉ាងនេះថា **អនតិវត្តោ** *(មិនត្រេកអរ)* ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ។

ចប់អដ្ឋកថា សញ្ញោគសូត្រទី ៨

# អដ្ឋកថា ទានសូត្រទី ៩

## ការឲ្យទាន មានផលានិសង្សមិនស្មើគ្នា

គប្បីជ្រាបវិនិច្ឆ័យក្នុង ទានសូត្រទី ៩ ដូចតទៅនេះ ៖

[៤៩] បទថា **សាបេក្ខោ (ដោយប្រាថ្នាផល)** បានដល់ មានសេចក្ដីប្រាថ្នា ។ បទថា **បដិពទ្ធចិត្តោ (ដោយមានចិត្តជាប់ចំពាក់)** បានដល់ មានចិត្តជាប់ចំពាក់ក្នុងផលទាន ។ បទថា **សន្និធិបេក្ខោ (ដោយបំណងសន្សំ)** បានដល់ ឲ្យទានទាំងសម្លឹងនូវការសន្សំទុក ។ បទថា **បេច្ច (ស្លាប់ទៅហើយ)** បានដល់ ទៅកាន់លោកដទៃហើយ ។ បទថា **តំកម្មំខេបេត្វា (អស់កម្ម... នោះហើយ)** បានដល់ ផលរបស់កម្មនោះអស់ទៅ ។ បទថា **ឥទ្ធី (ឫទ្ធិ)** បានដល់ ឫទ្ធិ គឺ វិបាក ។ បទថា **យសំ (យស)** បានដល់ ការដល់ព្រមដោយបរិវារ ។ បទថា **អាធិបតេយ្យំ (ភាពជាធំ)** បានដល់ ហេតុនៃភាពជាធំ ។ បទថា **អាគន្តា ឥត្ថត្តំ (មកកាន់សភាពយ៉ាងនេះ)** បានដល់ នៅត្រឡប់មកជាយ៉ាងនេះ គឺ ត្រឡប់មកកាន់ខន្ធបញ្ចកៈនេះ (ខន្ធ ៥ ទៀត) ។ អធិប្បាយថា គេនឹងមិនកើតក្នុងភពនោះទៀត នឹងមិន

កើតឡើងក្នុងកពខ្ពស់ឡើងទេ តែនឹងត្រឡប់មកកាន់កពខាងក្រោមប៉ុណ្ណោះ ។ បទថា **សាហុ ទានំ** (ទានជាការល្អ) បានដល់ ឈ្មោះថា ទាននេះ រមែងញុំាងប្រយោជន៍ឲ្យសម្រេច ល្អ ស្អាត ។ បទថា **តានិ មហាយញ្ញានិ** (បូជាមហាយញ្ញ) បានដល់ មហាទានទាំងនោះ សម្រេចដោយទឹកដោះថ្លា ទឹកដោះខាប់ ទឹកដោះជូរ ទឹកឃ្មុំ និងទឹកអំពៅជាដើម ។ បទថា **ចិត្តាលង្ការំ ចិត្តបរិក្ខារំ** (ជាគ្រឿងប្រដាប់នៃចិត្ត) បានដល់ ជាគ្រឿងប្រដាប់ និងជាបរិក្ខារនៃចិត្ត ដែលសម្បយុត្តដោយសមថៈ និងវិបស្សនា ។ បទថា **ព្រហ្មកាយិកានំ ទេវានំ សហព្យតំ** (ភាពជាសំឡាញ់នៃទេវតាជាន់ព្រហ្ម) បានដល់ គេមិនអាចកើតឡើងក្នុងភូមិនោះបានដោយទាន តែព្រោះហេតុដែលទាននោះជាគ្រឿងប្រដាប់ចិត្ត ដែលប្រកបដោយសមថៈ និងវិបស្សនា ដូច្នោះ គេទើបធ្វើឈាន និងអរិយមគ្គឲ្យកើតឡើងដោយចិត្តដែលប្រដាប់ដោយទាននោះហើយ រមែងកើតឡើងក្នុងភូមិនោះដោយឈាន ។

បទថា **អនាគាមី ហោតិ** (ជាអ្នកមិនត្រូវត្រឡប់មក) បានដល់ ជាអ្នកមិនត្រឡប់មកព្រោះឈាន (ព្រះអនាគាមី) ។ បទថា **អនាគន្តា ឥត្ថត្តំ**

(មិនមកកាន់សភាពជាយ៉ាងនេះ) បានដល់ មិនត្រឡប់មកកាន់ភាពជាយ៉ាងនេះទៀត ជាអ្នកកើតឡើងក្នុងភពខ្ពស់ៗ ឬជាអ្នកកើតឡើងក្នុងភពនោះៗ រមែងបរិនិព្វានក្នុងភពនោះឯង ។

ដូច្នោះ បណ្តាទានទាំងនេះ គឺ ៖

ទានទី ១ ឈ្មោះថា តណ្ហុត្តរិយទាន (ការឲ្យដោយការប្រាថ្នា)
ទានទី ២ ឈ្មោះថា ចិត្តីការទាន (ឲ្យដោយសេចក្តីកោតក្រែង)
ទានទី ៣ ឈ្មោះថា ហិរោត្តប្បទាន (ឲ្យដោយការខ្មាស និងការខ្លាច)
ទានទី ៤ ឈ្មោះថា និរវសេសទាន (ឲ្យដោយមិនឲ្យសេសសល់)
ទានទី ៥ ឈ្មោះថា ទក្ខិណេយ្យទាន (ឲ្យដល់ព្រះទក្ខិណេយ្យបុគ្គល)
ទានទី ៦ ឈ្មោះថា សោមនស្សូបវិចារទាន (ឲ្យអាស្រ័យសោមនស្ស)
ទានទី ៧ ឈ្មោះថា អលង្ការបរិវារទាន (ឲ្យជាគ្រឿងប្រដាប់ និងជាបរិវារនៃចិត្ត)

ចប់អដ្ឋកថា ទានសូត្រទី ៩

# អដ្ឋកថា មាតាសូត្រទី ១០

## រឿងដ៏អស្ចារ្យរបស់នាងនន្ទមាតា

*គប្បីជ្រាបវិនិច្ឆ័យក្នុង មាតាសូត្រទី ១០ ដូចតទៅនេះ ៖*

*[៥០] បានឮថា ព្រះសាស្តាទ្រង់ចាំវស្សា បវារណាហើយ ទ្រង់លះព្រះអគ្គសាវកទាំង ២ ទុក ស្តេចចេញទៅដោយបំណងថា តថាគតនឹងចារិកទៅក្នុងទក្ខិណាគិរីជនបទ ។ ព្រះបាទបសេនទិកោសល អនាថបិណ្ឌិកគហបតី វិសាខាមហាឧបាសិកា និងជនដទៃៗ ជាច្រើន មិនអាចនឹងនិមន្តឲ្យព្រះទសពលស្តេចត្រឡប់បាន ។ អនាថបិណ្ឌិកគហបតីអង្គុយគិតជញ្ជឹងក្នុងទីស្ងាត់ថា យើងមិនអាចនឹងនិមន្តឲ្យព្រះសាស្តាស្តេចត្រឡប់បាន ។ លំដាប់នោះ នាងទាសីឈ្មោះបុណ្ណា ឃើញដូច្នោះ ទើបសួរថា លោកម្ចាស់មានឥន្ទ្រិយមិនថ្លូវផង់ដូចពីមុន ព្រោះហេតុអ្វីទៅ ។ លោកគហបតីឆ្លើយថា ពិតហើយ បុណ្ណា ព្រះសាស្តាស្តេចចេញទៅកាន់ចារិកហើយ ខ្ញុំមិនអាចនិមន្តឲ្យព្រះអង្គស្តេចត្រឡប់បាន ទាំងមិនជ្រាបថា ព្រះអង្គស្តេចនឹងត្រឡប់មកវិញរហ័ស ឬក៏ទេ ព្រោះហេតុនោះ ខ្ញុំទើបអង្គុយគិត នាង*

ទាសីសួរថា បើនាងខ្ញុំនិមន្តព្រះទសពលឲ្យស្តេចត្រឡប់មកបាន លោកនឹងឲ្យអ្វីដល់នាងខ្ញុំ ។ លោកសេដ្ឋីឆ្លើយថា ខ្ញុំនឹងធ្វើឲ្យនាងជាអ្នកជា ។ នាងទាសីទៅថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាអនុគ្រោះស្តេចត្រឡប់ទៅវិញចុះព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ព្រោះហេតុតថាគតត្រឡប់ នាងនឹងធ្វើអ្វី ។ នាងទាសីទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាទ្រង់ជ្រាបថា នាងខ្ញុំជាមនុស្សអាស្រ័យអ្នកដទៃ នាងខ្ញុំមិនអាចធ្វើអ្វីដទៃបាន តែនាងខ្ញុំនឹងតាំងនៅក្នុងសរណៈ រក្សាសីល ៥ ។ ព្រះសាស្តាត្រាស់ថា ល្អហើយ ល្អហើយ បុណ្ណា ហើយស្តេចត្រឡប់ ក្នុងពាក្យតែម្តងប៉ុណ្ណោះ ព្រោះការគោរពក្នុងធម៌ ។ សមពិតដូចព្រះតម្រាស់ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតគោរពក្នុងធម៌ មានធម៌ជាទីគោរព ។ ព្រះសាស្តាស្តេចត្រឡប់ចូលទៅកាន់ព្រះជេតពនមហាវិហារ ។ មហាជនបានឲ្យសាធុការមួយពាន់ដល់នាងបុណ្ណា ។ ព្រះសាស្តាទ្រង់សម្តែងធម៌ក្នុងសមាគមនោះ ។ សត្វ ៨៤.០០០ ផឹកទឹកអម្រិតហើយ ។ ចំណែកនាងបុណ្ណាដែលសេដ្ឋីអនុញ្ញាតហើយ បានទៅកាន់

សម្នាក់របស់នាងភិក្ខុនី ហើយបព្វជ្ជា ។ ព្រះសម្មាសម្ពុទ្ធឲ្យត្រាស់ហៅព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានមក ហើយត្រាស់ថា តថាគតចេញចារិកទៅក្នុងទិសណា តថាគតមិនបានទៅក្នុងទិសនោះ ពួកអ្នកព្រមទាំងបរិស័ទរបស់អ្នក ចូរទៅកាន់ចារិកក្នុងទិសនោះចុះ ដូច្នេះ ហើយទើបត្រាស់ឲ្យទៅ ។ បទមានជាអាទិ៍ថា **ឯកំ សមយំ អាយស្មា សារីបុត្តោ** (សម័យមួយ ព្រះសារីបុត្រ) លោកពោល ព្រោះអត្ថុប្បត្តិ (ហេតុកើតឡើងនៃរឿង) នេះ ។

បណ្ដាបទទាំងនោះ បទថា **វេឡុកណ្ដកី** (ក្រុងឈ្មោះវេឡុកណ្ដកៈ) បានដល់ អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈ ។ បានឮថា អ្នកក្រុងទាំងឡាយនាំគ្នាដាំដើមឫស្សីព័ទ្ធជុំវិញកំពែង ដើម្បីនឹងរក្សាកំពែងក្រុងនោះ ។ ព្រោះហេតុនោះ ក្រុងនោះទើបមានឈ្មោះថា វេឡុកណ្ដកៈ នោះឯង ។ បទថា **បារាយនំ** (បារាយនសូត្រ) បានដល់ ធម៌ ដែលបានវោហារថាបារាយនៈ ព្រោះជាដំណើរទៅដល់ត្រើយ គឺ ព្រះនិព្វាន ។ បទថា **សរេន ភាសតិ** (សូត្រ... ធ្វើបទសារភញ្ញ) បានដល់ នន្ទមាតាអរិយសាវិកាអង្គុយក្នុងកន្លែង

មានការរក្សា ដែលគេចាត់ចែងទុកល្អហើយ លើផ្ទៃនៃប្រសាទជាន់ទី ៧ ឲ្យពាក់កណ្ដាលរាត្រីកន្លងទៅដោយកម្លាំងនៃសមាបត្តិ លុះចេញចាកសមាបត្តិហើយ គិតថា យើងនឹងឲ្យរាត្រីដែលសល់ត្រឹមតែប៉ុណ្ណេះ កន្លងទៅដោយសេចក្ដីត្រេកអរយ៉ាងណា ហើយធ្វើសេចក្ដីសម្រេចថា នឹងឲ្យកន្លងទៅដោយសេចក្ដីត្រេកអរក្នុងធម៌ អង្គុយហើយ សម្រេចផល ៣ (ជាព្រះអនាគាមី) ហើយ ទើបពោលបារាយនសូត្រ ប្រមាណ ២៥០ គាថា ដោយធ្វើបទសារភញ្ញដ៏ពីរោះ ។

បទថា អស្សោសិ ខោ (ទ្រង់បានស្ដាប់) បានដល់ ស្ដេចវេស្សវណមហារាជ ទ្រង់ប្រមើលមើលវិមានដែលតាំងនៅក្នុងអាកាសហើយ ឡើងលើយាននាវាហនៈ ស្ដេចចេញទៅដោយឆ្លងកាត់ចំណែកខាងលើប្រសាទនោះ បានឮសំឡេង (បារាយនសូត្រ) នោះ ។ បទថា **កថាបរិយោសានំ អាគមយមានោ អដ្ឋាសិ** (ក៏ប្រថាប់បន្អង់ចាំស្ដាប់ត្រាតែចប់) បានដល់ ស្ដេចវេស្សវណមហារាជនោះ ត្រាស់សួរថា នាយ នោះសំឡេងអ្វី ។ កាលយក្សបរិស័ទទូលថា នោះគឺ សំឡេងសូត្រដោយធ្វើបទសរភញ្ញរបស់នន្ទ-

មាតាឧបាសិកា ទើបស្តេចវេស្សវណប់ទេសនានេះថា **ឥទមវោច** (លុះត្រាស់ហើយ) ហើយប្រថាប់ឈរលើអាកាសក្នុងទីមិនឆ្ងាយ ។ បទថា **សាធុ ភគិនិ សាធុ ភគិនិ** (សាធុបងស្រី សាធុបងស្រី) បានដល់ ស្តេចវេស្សវណមហារាជត្រាស់ថា បងស្រី ព្រះធម្មទេសនាបងទទួលមកល្អហើយ ពោលល្អហើយ យើងមិនឃើញចន្លោះអ្វីដែលនឹងផ្សេងគ្នា ក្នុងថ្ងៃដែលព្រះសម្មា-សម្ពុទ្ធប្រថាប់ត្រង់បាសាណកចេតិយ ត្រាស់ដល់បារាយនិកព្រាហ្មណ៍ ១៦ នាក់ និងដែលនាងពោលក្នុងថ្ងៃនេះ ពាក្យដែលនាងពោលទុកហើយ ដូចនឹងព្រះតម្រាស់ដែលព្រះសាស្តាត្រាស់ហើយនោះឯង ដូចជាមាសដែលកាត់ត្រង់ពាក់កណ្តាល កាលនឹងឲ្យសាធុការ ទើបត្រាស់យ៉ាងនោះ ។

បទថា **កោ បនេសោ ភទ្ទមុខ** (លោកដែលមានមុខដ៏ចម្រើនលោកជានរណា) បានដល់ នន្ទមាតា អរិយសាវិកាដែលសម្រេចផល ៣ ហើយ ប្រាសចាកសេចក្តីភ័យខ្លាច បើកបង្អួចមានពណ៌ដូចផែនមាស កាលនឹងពោលជាមួយស្តេចវេស្សវណ ទើបបានពោលយ៉ាងនេះ ដោយសំឡេងយ៉ាងនេះ ក្នុងទីដែលមានការរក្សាយ៉ាងល្អនេះថា លោកអ្នកមានមុខស្រស់

លោកអ្នកមានមុខដ៏ចម្រើន លោកជានរណា ជានាគ ជាគ្រុឌ ជាទេវតា ជាមារ ឬជាព្រហ្ម ។ បទថា **អហាន្តេ ភគិនិ ភាតា** (បងស្រី យើងជាមហារាជឈ្មោះវេស្សវណ ជាប្អូនរបស់នាង) បានដល់ ស្តេចវេស្សវណទ្រង់សំគាល់ព្រះអរិយសាវិកា ដែលជាព្រះអនាគាមីថា បង ព្រោះព្រះអង្គឯងជាព្រះសោតាបន្ន ទើបត្រាស់ថា បងស្រី (ភគិនិ) ហើយសំគាល់ព្រះអរិយសាវិកាដែលជាព្រះអរិយអនាគាមីនោះថា ជាប្អូនរបស់ព្រះអង្គទៀត ព្រោះនាងនៅក្នុងបឋមវ័យ ព្រោះសំគាល់ថា ព្រះអង្គចាស់ជាង ព្រោះទ្រង់មានព្រះជន្មាយុដល់ ៩ លានឆ្នាំ ទើបត្រាស់ហៅព្រះអង្គឯងថា **ភាតា** (បងប្រុស) ។

បទថា **សាធុ ភទ្រមុខ** (លោកដែលមានមុខដ៏ចម្រើន ប្រពៃហើយ) បានដល់ លោកអ្នកមានមុខដ៏ចម្រើន ការមករបស់លោកជាប្រយោជន៍ ជាការល្អ ជាការមកដ៏ល្អ អធិប្បាយថា មកក្នុងឋានៈដែលសមគួរនឹងមកពិតៗ ។ បទថា **ឥទំ តេ ហោតុ អាតិថេយ្យំ** (សូមធម្មបរិយាយដែលខ្ញុំពោលហើយនេះ ចូរជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ) អធិប្បាយ

ថា សូមការពោលធម៌នេះឯង ចូរជាបណ្ណាការយ៉ាងល្អក្រៃលែងសម្រាប់លោក ព្រោះខ្ញុំមើលមិនឃើញវត្ថុដទៃ ដែលគួរឲ្យដល់ព្រះអង្គដ៏ក្រៃលែងជាងនេះ ។ បទថា **ឯវញ្ច មេ ភវិស្សតិ អាតិថេយ្យំ (ក៏ការធ្វើយ៉ាងនេះនឹងជាគ្រឿងបណ្ណាការរបស់ខ្ញុំ)** បានដល់ ស្តេចវេស្សវណនោះ លុះសូមបត្តិទានដើម្បីខ្លួនយ៉ាងនេះហើយ ទើបពោលថា នេះជាសក្ការៈដែលកើតអំពីការពោលធម៌សម្រាប់នាង ធ្វើជង្រុក ១.២៥០ ជង្រុក ឲ្យពេញដោយស្រូវសាលីក្រហម ហើយអធិដ្ឋានថា សូមស្រូវសាលីទាំងនេះ កុំឲ្យអស់ទៅដ៏រាបវេលាដែលឧបាសិកានេះរស់នៅ ហើយក៏ចៀសចេញទៅ ។ ជនទាំងឡាយមិនអាចនឹងឃើញបាតនៃជង្រុក ដ៏រាបដែលឧបាសិកានៅមានជីវិត ។ តាំងអំពីនោះមក ទើបកើតវោហារឡើងថា ដូចជង្រុកស្រូវរបស់នន្ទមាតា ។ បទថា **អកតបាតរាសោ (មិនទាន់បានឆាន់ក្នុងវេលាព្រឹកនៅឡើយ)** បានដល់ អ្នកនៅមិនទាន់បរិភោគអាហារព្រឹក ។

បទថា **បុញ្ញំ (ផលបុណ្យ "ក្នុងទាននេះ")** បានដល់ បុព្វចេតនា (ចេតនាមុនការឲ្យទាន) និងមុញ្ចនចេតនា (ចេតនាខណៈឲ្យទាន) ។ បទថា

បុញ្ញមហិតំ (ក៏ផលបុណ្យ... នោះ) បានដល់ អបរចេតនា (ចេតនាខាងក្រោយការឲ្យទានហើយ) ។ បទថា សុខាយ ហោតុ (ចូរប្រព្រឹត្តទៅដើម្បីសេចក្តីសុខ) បានដល់ ចូរមានដើម្បីជាប្រយោជន៍ដល់សេចក្តីសុខ ដើម្បីជាប្រយោជន៍ដល់សេចក្តីចម្រើន ។ ននុមាតាអរិយសាវិកា បានឲ្យបត្តិ-ទានដល់ស្តេចវេស្សវណក្នុងផលទានរបស់ខ្លួន ដោយប្រការដូច្នេះ ។ បទថា បករណេ (ព្រោះហេតុ) បានដល់ ព្រោះហេតុនោះ ។ បទថា ឱក្កស្ស បសយ្ហ (បានគ្របសង្កត់) បានដល់ ទាញមក គម្រាមកំហែង ។ បទថា យក្ខយោនឹ (កើតជាយក្ស) បានដល់ ភាពជាកុម្ភទេវតា ។ បទថា តេនេវ បុរិមេន អត្តភាវេន ឧទ្ទស្សេសិ (មកសម្តែងនូវអត្តភាពដល់ខ្ញុំដូចកាលមុន) បានដល់ កុម្ភទេវតានោះ និម្មិតរាងកាយឲ្យដូចជារាងកាយចាស់នោះឯង ប្រដាប់តាក់តែងហើយ សម្តែងខ្លួនលើទីដេកក្នុងបន្ទប់ដ៏មានសិរី ។ បទថា ឧបាសិកា បដិទេសិតា (សម្តែងខ្លួនជាឧបាសិកា) បានដល់ ខ្ញុំសម្តែងខ្លួនជាឧបាសិកាយ៉ាងនេះថា ខ្ញុំជាឧបាសិកា ។ បទថា យាវទេវ (ត្រឹមណា) បានដល់ ត្រឹមណានោះឯង ។ បទដ៏សេសក្នុងទីទាំងពួងងាយ

*យល់ទាំងអស់ហើយនោះឯង ។*

ចប់អដ្ឋកថា មាតាសូត្រទី ១០

## ចប់អដ្ឋកថា មហាយញ្ញវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ចប់បឋមបណ្ណាសកៈ

# វគ្គមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

## អព្យាកតវគ្គវណ្ណនាទី ១

## អដ្ឋកថា អព្យាកតសូត្រទី ១

*រឿងដែលទ្រង់មិនបានព្យាករណ៍*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អព្យាកតសូត្រទី ១ ដូចតទៅនេះ ៖*

[៥១] *បទថា* **អព្យាកតវត្ថូសុ** *(ក្នុងរឿងដែលទ្រង់មិនព្យាករណ៍) បានដល់ ក្នុងរឿងដែលព្រះមានព្រះភាគបានត្រាស់ដោយព្យាករណ៍ មានឯកង្សព្យាករណ៍ជាដើម ។ បទថា* **តថាគតោ** *(សត្វ) បានដល់ សត្វអ្នកនៅជាប់ជំពាក់ ។ បទថា* **ទិដ្ឋិគតមេតំ** *(ការប្រកាន់ដោយទិដ្ឋិ) នេះជាមិច្ឆាទិដ្ឋិ ។ ឈ្មោះថា សត្វអ្នកមិនត្រូវទិដ្ឋិនោះចាប់ទុក រមែងមិនមាន ។ បទថា* **បដិបទំ** *(បដិបទា) បានដល់ អរិយមគ្គ ។ បទថា* **ន ឆម្ភតិ** *(រមែងរន្ធត់) បានដល់ រមែងមិនញាប់ញ័រដោយអំណាចទិដ្ឋិ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា* **តណ្ហាគតំ** *(សេចក្ដីប្រាថ្នា) បានដល់*

តណ្ហាដែលសម្បយុត្តដោយទិដ្ឋិ ។ សូម្បីក្នុងពាក្យមានជាអាទិ៍ថា **សញ្ញាគតំ (សេចក្តីសម្គាល់)** ក៏ន័យនេះដូចគ្នា ។ ព្រោះថា បណ្តាបទទាំងនោះ សញ្ញាដែលសម្បយុត្តដោយទិដ្ឋិនោះឯង គប្បីជ្រាបថាជា **សេចក្តីសម្គាល់** មានះដែលអាស្រ័យទិដ្ឋិនោះនុ៎ះឯង ឬសេចក្តីសម្គាល់ ដែលអាស្រ័យទិដ្ឋិនោះឯង គប្បីជ្រាបថា **សេចក្តីសំគាល់** ។ ធម៌ជាហេតុឲ្យយឺតយូរដែលអាស្រ័យទិដ្ឋិនោះឯង គប្បីជ្រាបថា **ភាពស្និតស្នាញ** ។ ឧបាទាន ការប្រកាន់មាំដោយអំណាចទិដ្ឋិនោះឯង គប្បីជ្រាបថា **ការប្រកាន់មាំ ភាវៈ** គឺ ការរលឹកខុសដោយអំណាចទិដ្ឋិនោះឯង គប្បីជ្រាបថា ឈ្មោះថា **សេចក្តីក្តៅក្រហាយ** ។ ក្នុងសូត្រនេះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកទិដ្ឋិ ៦២ ដោយទិដ្ឋិស័ព្ទ និងទ្រង់កាន់យកសោតាបត្តិមគ្គនោះឯង ដោយទិដ្ឋិនិរោធគាមិនីបដិបទាស័ព្ទ ។

ចប់អដ្ឋកថា អព្យាកតសូត្រទី ១

# អដ្ឋកថា បុរិសគតិសូត្រទី ២

## ភូមិជាទីទៅរបស់មនុស្ស

គប្បីជ្រាបវិនិច្ឆ័យក្នុង បុរិសគតិសូត្រទី ២ ដូចតទៅនេះ ៖

[៥២] បទថា *បុរិសគតិយោ (បុរិសគតិ)* បានដល់ ញាណគតិរបស់បុរស ។ បទថា *អនុបាទាបរិនិព្វានំ (អនុបាទាបរិនិព្វាន)* បានដល់បរិនិព្វានដែលរកបច្ច័យមិនបាន ។ បទថា *នោ ចស្ស (បើកម្មក្នុងអតីតមិនមានសោត)* បានដល់ បើកម្មដែលកើតក្នុងអត្តភាពជាអតីតនឹងមិនមានសោត ។ បទថា *នោ ច មេ សិយា (អត្តភាពក្នុងលោកបច្ចុប្បន្ន ក៏មិនគប្បីមានដល់យើង)* បានដល់ អត្តភាពនេះ ក្នុងកាលឥឡូវនេះក៏មិនគប្បីមានដល់យើង ។ បទថា *ន ភវិស្សតិ (បើកម្មក្នុងបច្ចុប្បន្នមិនមានទេ)* បានដល់ ឥឡូវនេះ កម្មដែលនឹងញ៉ាំងអត្តភាពជាអនាគតរបស់យើងឲ្យកើតនឹងមិនមាន ។ បទថា *ន មេ ភវិស្សតិ (អត្តភាពក្នុងអនាគតនឹងមិនមានដល់យើង)* បានដល់ អត្តភាពរបស់យើងក្នុងអនាគតនឹងមិនមាន ។ បទថា *យទត្ថិ យំ ភូតំ (បញ្ចក្ខន្ធណាដែលកំពុងកើត ដែលមានមកហើយ)*

បានដល់ បញ្ចក្ខន្ធដែលកំពុងមាន ដែលមានហើយ គឺ ដែលជាបច្ចុប្បន្ន (កើតឡើងចំពោះមុខ) ។ បទថា **តំ បជហាមីតិ ឧបេក្ខំ បដិលភតិ (បានការប្រងើយថា... យើងរមែងលះបាន)** បានដល់ រមែងបានឧបេក្ខាដែលសម្បយុត្តដោយវិបស្សនាញាណថា យើងនឹងលះបញ្ចក្ខន្ធនោះ ដោយការលះឆន្ទរាគៈក្នុងបញ្ចក្ខន្ធនោះចេញ ។ បទថា **ភវេ ន រជ្ជតិ (រមែងមិនអាល័យក្នុងបញ្ចក្ខន្ធដែលជាអតីត)** បានដល់ រមែងមិនអាល័យក្នុងបញ្ចក្ខន្ធដែលជាអតីតដោយតណ្ហា និងទិដ្ឋិ ។ បទថា **សម្ភវេ ន រជ្ជតិ (មិនប្រាថ្នាក្នុងបញ្ចក្ខន្ធដែលជាអនាគត)** បានដល់ រមែងមិនប្រាថ្នាក្នុងបញ្ចក្ខន្ធសូម្បីជាអនាគតយ៉ាងនោះនុ៎ះឯង ។ បទថា **អត្តុត្តរិ បទំ សន្តំ (បទដែលស្ងប់យ៉ាងក្រៃលែងមាន)** បានដល់ ឈ្មោះថា បទ គឺ ព្រះនិព្វាន ជាបទដ៏ស្ងប់យ៉ាងក្រៃលែងមាន ។ បទថា **សម្មប្បញ្ញាយ បស្សតិ (រមែងពិចារណាឃើញ... ដោយបញ្ញាដ៏ប្រពៃ)** បានដល់ រមែងឃើញដោយប្រពៃនូវបទ គឺ ព្រះនិព្វាននោះ ដោយមគ្គប្បញ្ញាព្រមដោយវិបស្សនា ។ បទថា **ន សព្វេន សព្វំ (មិនបានដោយអាការទាំងពួង)** បានដល់ ឈ្មោះថា មិន

បានដោយអាការទាំងពួង ព្រោះលះកិលេសពួកខ្លះមិនទាន់បាន ព្រោះកម្ចាត់សេចក្តីងងឹតដែលជាគូបរិទប្រាំងសច្ចៈមិនបានដោយអាការទាំងពួង ។ បទថា **ហញ្ញមានេ (កាលបើមេជាងពូកែវាយ)** បានដល់ កាលបើមេជាងយកដង្កាប់ចាប់ហើយយកញញួរដំ ។

បទថា **អន្តរាបរិនិព្វាយី** បានដល់ ចាប់ផ្តើមពីកាលដែលជាលំដាប់នៃការកើតឡើង មិនដល់ពាក់កណ្តាលនៃអាយុ ក្នុងរវាងនេះ ព្រះអនាគាមិបុគ្គល រមែងបរិនិព្វានដោយកិលេសបរិនិព្វាន ។ បទថា **អនុបហច្ច-តលំ (ធ្លាក់មិនទាន់ដល់ផែនដី)** បានដល់ ព្រះមានព្រះភាគទ្រង់សម្តែងអន្តរាបរិនិព្វាយីបុគ្គលទុក ៣ ពួក ដោយឧបមា ៣ ចំណុចប៉ុណ្ណេះជាដើមថា កម្ទេចផ្កាភ្លើងខ្ទាតឡើង គឺ មិនកន្លងផ្ទៃអាកាស បានដល់ មិនទាន់ធ្លាក់ដល់ដី ក៏រលត់ក្នុងអាកាសនោះឯង ។ បទថា **ឧបហច្ចបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គល កន្លងផុតពាក់កណ្តាលអាយុ រហូតដល់ទីបំផុតនៃចិត្តជួងចុងក្រោយ ហើយបរិនិព្វាន ។ បទថា **ឧបហច្ច តលំ (ធ្លាក់ដល់ដីហើយ)** បានដល់ ក្រមផ្កាភ្លើងដែលជាប់ដោយភ្លើង កន្លងផ្ទៃ

អាកាស ឬខ្ទាតប៉ះនឹងផែនដី ត្រឹមតែធ្លាក់ទៅដល់ដីប៉ុណ្ណោះហើយ ក៏រលត់ទៅ ។ ព្រះអនាគាមិបុគ្គលអ្នកធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយត្រូវប្រើកម្លាំងខ្លាំង គឺ ត្រូវប្រកបសេចក្ដីព្យាយាមច្រើន ហើយបរិនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា **អសង្ខារបរិនិព្វាយី** ។ ព្រះអនាគាមិ-បុគ្គលអ្នកធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយប្រើកម្លាំងខ្លាំងក្លា គឺ ត្រូវប្រកបសេចក្ដីព្យាយាមច្រើន ហើយបរិនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា **សសង្ខារិកបរិនិព្វាយី** ។ បទថា **គច្ឆំ** (គុម្ពឈើ) បានដល់ព្រៃដែលប្រាសចាកការរក្សា ។ បទថា **ទាយំ** (ព្រៃឈើ) បានដល់ ព្រៃដែលមានការរក្សា គឺ ដែលលោកឲ្យ ដើម្បីប្រយោជន៍ដល់ការឲ្យអភ័យហើយ ។ ពាក្យដ៏សេសក្នុងទីនេះមាន សេចក្ដីងាយយល់ហើយនោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះអរិយបុគ្គលទាំងឡាយនោះឯង ។

ចប់អដ្ឋកថា បុរិសគតិសូត្រទី ២

# អដ្ឋកថា តិស្សសូត្រទី ៣

## តិស្សព្រហ្ម

គប្បីជ្រាបវិនិច្ឆ័យក្នុង តិស្សព្រហ្មសូត្រទី ៣ ដូចតទៅនេះ ៖

[៥៣] បទថា *ភិក្ខុនិយោ (ភិក្ខុនី)* បានដល់ ភិក្ខុប្រមាណ ៥០០ រូប ដែលជាបរិវាររបស់ព្រះនាងមហាបជាបតី ។ បទថា *វិមុត្តា (រួចផុតហើយ)* បានដល់ រួចផុតហើយដោយវិមុត្តិទាំង ៥ ។ បទថា *អនុបាទិសេសា (ព្រោះមិនមានឧបាទិសល់នៅ)* បានដល់ រួចផុតហើយដោយមិនមានសេសសល់ព្រោះវិមុត្តិទាំង ៥ ដោយមិនមានសល់ឧបាទាន ។ បទថា *សឧបាទិសេសេ វា សឧបាទិសេសោ (ក្នុងបុគ្គលអ្នកនូវមានឧបាទិដ៏សេសថា នូវមានឧបាទិដ៏សេស)* បានដល់ ក្នុងបុគ្គលនៅមានឧបាទានដ៏សេសថា បុគ្គលអ្នកនៅមានឧបាទានដ៏សេស ។ សូម្បីក្នុងបទក្រៅពីនេះ ក៏មានន័យនេះដូចគ្នា ។ បទថា *តិស្សោ (តិស្ស)* បានដល់ ព្រហ្មដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ ។ បទថា *អនុលោមិកានិ (ដែលសមគួរ)* បានដល់ ដែលសមគួរដល់ការបដិបត្តិ គឺ ស្វាត់ បានដល់ តាំងនៅខាងចុង

បំផុត (វត្ត) ។ បទថា **ឥន្ទ្រិយានិ (ឥន្ទ្រិយ)** បានដល់ ឥន្ទ្រិយក្នុងវិបស្សនា មានសទ្ធាជាដើម ។

បទថា **សមន្នានយមានោ (អប់រំ)** បានដល់ រួបរួមមកតាំងទុក ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធពាក្យនេះថា **ន ហិ បន តេ (ក៏... មិនបាន "សម្តែង" ... ដល់អ្នកឬ)** ដូចម្តេច ។ ដើម្បីទ្រង់សម្តែងបុគ្គលទី ៧ ។ ព្រោះថា តិស្សព្រហ្ម មិនបានសម្តែងភិក្ខុអ្នកជាសទ្ធានុសារីបុគ្គលទី ៧ ទុក ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសទ្ធានុសារីបុគ្គលនោះ ដោយអំណាចអ្នកចម្រើនវិបស្សនាយ៉ាងខ្ជាំងក្លា ទើបត្រាស់យ៉ាងនេះ ។ បណ្តាបទទាំងនោះ បទថា **សព្វនិមិត្តានំ (និមិត្តទាំងពួង)** បានដល់ និមិត្តទាំងអស់ មាននិច្ចនិមិត្តជាដើម ។ បទថា **អនិមិត្តំ (ដែលរកនិមិត្តមិនបាន)** បានដល់ វិបស្សនាសមាធិដែលមានកម្លាំង ។

ចប់អដ្ឋកថា តិស្សសូត្រទី ៣

# អដ្ឋកថា សីហសូត្រទី ៤

## សីហសេនាបតី

គប្បីជ្រាបវិនិច្ឆ័យក្នុង សីហសូត្រទី ៤ ដូចតទៅនេះ ៖

[៥៤] បទថា **មច្ឆរី** (កំណាញ់) បានដល់ បុគ្គលអ្នកប្រកបដោយសេចក្ដីកំណាញ់ ៥ យ៉ាង ។ បទថា **កទរិយោ** (ស្វិតស្វាញ) បានដល់ បុគ្គលអ្នកមានសេចក្ដីកំណាញ់ស្វិត រមែងហាមទានសូម្បីដែលជនពួកដទៃនឹងឲ្យ ។ បទថា **អនុប្បទានរតោ** (ក្នុងការកពូនទូវទាន) បានដល់ កាលនឹងឲ្យទានរឿយៗ ក៏រមែងត្រេកអរ ។ បទថា **អនុកម្បន្តោ** (កាលអនុគ្រោះ) បានដល់ បុគ្គលអនុគ្រោះដោយគិតយ៉ាងនេះថា ថ្ងៃនេះយើងនឹងអនុគ្រោះនរណា ពួកយើងនឹងគប្បីទទួលទេយ្យធម៌របស់នរណា ឬពួកយើងនឹងគប្បីសម្ដែងធម៌ដល់នរណា ។

ចប់អដ្ឋកថា សីហសូត្រទី ៤

# អដ្ឋកថា រក្ខិតសូត្រទី ៥

## ឋានៈដែលព្រះតថាគតមិនត្រូវរក្សា)

*គប្បីជ្រាបវិនិច្ឆ័យក្នុង រក្ខិតសូត្រទី ៥ ដូចតទៅនេះ ៖*

[៥៥] *បទថា* **និមិត្តំ** *(**និមិត្ត**) បានដល់ ធម្មនិមិត្តខ្លះ បុគ្គលនិមិត្តខ្លះ ។ ពិតណាស់ ព្រះតថាគត កាលពិចារណាមិនឃើញសូម្បីបទមួយក្នុងធម៌ដែលព្រះអង្គទ្រង់សម្តែងហើយ ថាជាធម៌ដែលពោលមិនល្អ នាំសត្វចេញចាកទុក្ខក្នុងវដ្តៈមិនបាន ឈ្មោះថា មិនត្រាស់ដឹងធម្មនិមិត្ត ។ ព្រះតថាគត កាលពិចារណាមិនឃើញសូម្បីបុគ្គលណាម្នាក់ ដែលនឹងក្រោកឡើងឆ្លើយតបថា ធម៌ដែលព្រះអង្គពោលខុសហើយ ធម៌ដែលព្រះអង្គពោលហើយមិនល្អ ឈ្មោះថា មិនឃើញនូវបុគ្គលនិមិត្ត ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា រក្ខិតសូត្រទី ៥

# អដ្ឋកថា កិមិលសូត្រទី ៦

## ព្រះកិមិលៈ

[៥៦] *សូត្រនេះ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថា សត្តធម្មសូត្រទី ៧

## *ពោលដោយធម៌ ៧ ប្រការ*

[៥៧] *សូត្រនេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថា មោគ្គល្លានសូត្រទី ៨

## ព្រះមោគ្គល្លានៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសូត្រទី ៨ ដូចតទៅនេះ ៖

[៥៨] បទថា **ចបលាយមានោ (ងោកងក់)** សេចក្តីថា ព្រះមហាមោគ្គល្លានចូលទៅអាស្រ័យស្រុកនោះ ធ្វើសមណធម៌ក្នុងដងព្រៃមួយកន្លែងមានរាងកាយលំបាក ព្រោះត្រូវសេចក្តីព្យាយាមក្នុងការចង្រ្កមអស់ ៧ ថ្ងៃបៀតបៀន ទើបអង្គុយងោកងក់នៅខាងចុងនៃទីចង្រ្កម ។ បទថា **ចបលាយសិ នោ** កែជា **និទ្ទាយសិ នុ** បានដល់ អ្នកងងុយឬ ។ បទថា **អនុមជ្ជិត្វា (យកទឹកលាងភ្នែក)** បានដល់ ស្ទាបអង្អែលហើយ ។ បទថា **អាលោកសញ្ញំ (អាលោកសញ្ញា)** បានដល់ សេចក្តីសំគាល់ក្នុងពន្លឺ ដើម្បីបន្ទោបង់សេចក្តីងោកងក់ ។ បទថា **ទិវាសញ្ញំ (សេចក្តីសម្គាល់ក្នុងវេលាថ្ងៃ)** បានដល់ សេចក្តីសម្គាល់ថា ជាវេលាថ្ងៃ ។ បទថា **យថា ទិវា តថា រត្តឹ (ពេលថ្ងៃយ៉ាងណា ពេលយប់ក៏យ៉ាងនោះ)** បានដល់ អ្នកតាំងសេចក្តីសម្គាល់ថា ពន្លឺពេលថ្ងៃយ៉ាងណា អ្នកតាំងសេចក្តីសំគាល់ថា ពន្លឺ

នោះ សូម្បីក្នុងវេលាយប់ ក៏ដូច្នោះ ។ បទថា **យថា រត្តឹ តថា ទិវា** (ពេលយប់យ៉ាងណា ពេលថ្ងៃក៏យ៉ាងនោះ) បានដល់ អ្នកតាំងសេចក្តីសំគាល់ថា ពន្លឺក្នុងវេលាយប់យ៉ាងណា អ្នកតាំងសេចក្តីសំគាល់ថា ពន្លឺនោះសូម្បីក្នុងវេលាថ្ងៃ ក៏ដូច្នោះ ។ បទថា **សប្បភាសំ** (មានពន្លឺភ្លឺស្វាង) បានដល់ អ្នកគប្បីឲ្យចិត្តប្រព្រឹត្តព្រមជាមួយពន្លឺ ដើម្បីប្រយោជន៍ដល់ទិព្វចក្ខុញ្ញាណ ។ បទថា **បច្ឆាបុរេសញ្ញី** (កំណត់ខាងដើមខាងចុង) បានដល់ អ្នកមានសេចក្តីតាំងចិត្ត ដោយការតាំងចិត្តនឹងនាំទៅទាំងខាងមុខ និងខាងក្រោយ ។ បទថា **អន្តោគតេហិ ឥន្ទ្រិយេហិ** (សង្រួមឥន្ទ្រិយ) បានដល់ មានឥន្ទ្រិយ ៥ ដែលមិនរាយមាយទៅខាងក្រៅ គឺ ចូលមកតាំងទុកក្នុងខាងក្នុងប៉ុណ្ណោះ ។ បទថា **មិទ្ធសុខំ** (សេចក្តីសុខក្នុងការដេកងុយ) បានដល់ សេចក្តីសុខដែលកើតពីការដេកលក់ ។ ព្រះមានព្រះភាគសម្តែងកម្មដ្ឋាន ជាគ្រឿងបន្ទោបង់សេចក្តីងោកងក់ដល់ព្រះថេរៈ ដោយឋានៈមានប្រមាណប៉ុណ្ណោះ ។

បទថា **សោណ្ឌំ** (ប្រមោយ) បានដល់ ប្រមោយ គឺ មានះ ។ ក្នុង

បទថា **កិច្ចករណីយានិ** (មានករណីយកិច្ចច្រើនយ៉ាង) នេះ មានវិនិច្ឆ័យដូចតទៅនេះ កម្មដែលខ្វះគប្បីធ្វើពិត ឈ្មោះថា **កិច្ច** (កិច្ចកម្មដែលជាតួនាទីទាំងឡាយ) ចំណែកកិច្ចក្រៅពីនេះ ឈ្មោះថា **ករណីយៈ** (កិច្ចដែលគួរធ្វើទាំងឡាយ) ។ បទថា **មង្កុភាវោ** (សេចក្តីអៀនខ្មាស) បានដល់ភាពជាអ្នកគ្មានអំណាច សេចក្តីទាស់ចិត្ត ។ ព្រះសាស្តាត្រាស់កិច្ចាចារវត្តដល់ព្រះថេរៈដោយឋានៈមានប្រមាណប៉ុណ្ណេះ ។ ឥឡូវ កាលទ្រង់នឹងដឹកនាំឲ្យធ្វើទីបំផុតក្នុងការឆ្លើយតប (ដឹងក្នុងការគួរនិយាយ និងមិនគួរនិយាយ) ព្រះអង្គទើបត្រាស់ពាក្យជាដើមថា **តស្មាតិហ** (ព្រោះហេតុនោះឯង) ។ បណ្តាបទទាំងនោះ បទថា **វិគ្គាហិកកថំ** (ពាក្យដែលជាហេតុឲ្យទាស់ទែងគ្នា) បានដល់ ពាក្យដែលជាហេតុឲ្យប្រកែកគ្នា ដែលប្រព្រឹត្តទៅដោយន័យជាដើមថា លោកមែនមិនដឹងធម៌ និងវិន័យនេះ ។ ដើម្បីវៀរចាកការសេពគប់ជាមួយបាបមិត្រ ព្រះសាស្តាទើបត្រាស់ពាក្យមានជាអាទិ៍ថា **នាហំ មោគ្គល្លាន** (នែ៎មោគ្គល្លាន តថាគត... មិន) ។

បទថា **កិត្តាវតា នុ ខោ** (ដោយវត្តបដិបត្តិត្រឹមណាហ្ន៎) បានដល់

យ៉ាងណាហ្ន៎ ។ បទថា **តណ្ហាសង្ខយវិមុត្តោ ហោតិ (ទើបជាអ្នករួចផុតហើយព្រោះអស់តណ្ហា)** បានដល់ ភិក្ខុឈ្មោះថា ជាអ្នករួចផុតហើយព្រោះអស់តណ្ហា ព្រោះជាអ្នកមានចិត្តរួចផុតហើយក្នុងនិព្វាន ដែលជាសភាវៈអស់ទៅនៃតណ្ហា គឺ រួចផុតហើយ ព្រោះធ្វើនិព្វាននោះឲ្យជាអារម្មណ៍ ។ ព្រះមហាមោគ្គល្លានទូលសួរថា ដោយសង្ខេបនូវវត្តបដិបត្តិដូចម្ដេច គឺ ដោយវត្តបដិបត្តិណា ភិក្ខុឈ្មោះថា ជាអ្នករួចផុតហើយព្រោះអស់តណ្ហា សូមព្រះអង្គទ្រង់អនុគ្រោះសម្ដែងវត្តបដិបត្តិនុ៎ះឯង ដែលជាបដិបទាចំណែកខាងដើមរបស់ភិក្ខុព្រះខីណាស្រពដោយសង្ខេបចុះ ។

បទថា **អច្ចន្តនិដ្ឋោ (មានសេចក្ដីសម្រេចដល់ទីបំផុត)** មានវិគ្រោះថា ឈ្មោះថា ដល់ទីបំផុត ព្រោះអត្ថថា កន្លងទីបំផុត ពោលគឺ ការអស់ទៅ និងសេចក្ដីវិនាសទៅ ។ សេចក្ដីសម្រេចដល់ទីបំផុតមានដល់ភិក្ខុនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មានសេចក្ដីសម្រេចដល់ទីបំផុត** អធិប្បាយថា មានសេចក្ដីសម្រេចដោយចំណែកមួយ មានសេចក្ដីសម្រេចជាប់តគ្នា ។ បទថា **អច្ចន្តយោគក្ខេមី (មានសេចក្ដីក្សេមចាកយោគធម៌**

*ដល់ទីបំផុត) បានដល់ អ្នកមានធម៌ជាដែនក្សេមចាកយោគៈដ៏ក្រៃលែង អធិប្បាយថា មានធម៌ជាដែនក្សេមចាកយោគៈជានិច្ច ។ បទថា* ***អច្ចន្ត-ព្រហ្មចារី*** *(ជាព្រហ្មចារីបុគ្គលដល់ទីបំផុត) បានដល់ ជាព្រហ្មចារីបុគ្គលដ៏ក្រៃលែង អធិប្បាយថា ជាព្រហ្មចារីបុគ្គលជានិច្ច ។ បទថា* ***អច្ចន្ត-បរិយោសានោ*** *(មានទីបំផុតដល់ទីបំផុត) បានដល់ មានទីបំផុតដ៏ក្រៃលែងដោយន័យមុននោះឯង ។* បទថា ***សេដ្ឋោ ទេវមនុស្សានំ*** *(ប្រសើរបំផុតជាងទេវតា និងមនុស្សទាំងឡាយ)* បានដល់ ប្រសើរបំផុត គឺ ឧត្តមជាងទេវតា និងមនុស្សទាំងឡាយ ។ ព្រះមហាមោគ្គល្លានទូលសួរថា ភិក្ខុឈ្មោះថា ឃើញបែបនេះ ដោយវត្តបដិបត្តិត្រឹមណា សូមព្រះអង្គទ្រង់អនុគ្រោះសម្ដែងវត្តបដិបត្តិរបស់ភិក្ខុនោះដោយសង្ខេបចុះ ។

ក្នុងបទថា ***សព្វេ ធម្មា នាលំ អភិនិវេសាយ*** *(ធម៌ទាំងពួងមិនគួរប្រកាន់មាំ)* នេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា ធម៌ទាំងពួង គឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ធម៌ទាំងអស់នោះមិនគួរ គឺ មិនត្រូវ មិនគប្បី មិនសមគួរនឹងប្រកាន់មាំដោយអំណាចតណ្ហា និងទិដ្ឋិ ។ ព្រោះហេតុ

អ្វីធម៌ទាំងនោះ ទើបមិនគួរប្រកាន់មាំ ។ ព្រោះធម៌ទាំងនោះមិនតាំងនៅដោយអាការដែលនឹងគប្បីប្រកាន់ ។ ពិតហើយ ធម៌ទាំងនោះ សូម្បីខ្លួនប្រកាន់ថា ទៀង ជាសុខ និងជាអត្តា ក៏រមែងសម្រេចផលជារបស់មិនទៀង ជាទុក្ខ និងជាអនត្តានោះឯង ព្រោះដូច្នោះ ទើបមិនគួរប្រកាន់មាំ ។ បទថា **អភិជានាតិ (រមែងដឹងច្បាស់)** បានដល់ រមែងច្បាស់ គឺ ដឹងដោយញាតបរិញ្ញាថា ធម៌ទាំងពួងមិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **បរិជានាតិ (រមែងកំណត់ដឹង)** បានដល់ រមែងកំណត់ដឹងដោយតីរណ-បរិញ្ញានុ៎ះឯង ។ បទថា **យំកិញ្ចិ វេទនំ (វេទនាណាមួយ)** បានដល់ រមែងសោយវេទនាណាមួយ សូម្បីមានប្រមាណតិច ដោយហោចទៅសូម្បីប្រកបដោយបញ្ចវិញ្ញាណ ។ ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងវេទនា ដោយការកំណត់អរូបធម៌ (នាមធម៌) ដល់ព្រះថេរៈ ។

បទថា **អនិច្ចានុបស្សី (ពិចារណាឃើញមិនទៀង)** បានដល់ ពិចារណាឃើញដោយភាពជារបស់មិនទៀង ។ បទថា **វិរាគានុបស្សី (ពិចារណាឃើញរឿយៗ នូវការប្រាសចាកតម្រេក)** នេះ ការប្រាសចាកតម្រេកមាន

២ យ៉ាងគឺ ការប្រាសចាកតម្រេកព្រោះការអស់ទៅ (ខយវិរាគៈ) ១ ការប្រាសចាកតម្រេកដោយសមុច្ឆេទ (អច្ចន្តវិរាគៈ) ១ ។ ក្នុង ២ យ៉ាងនោះ វិបស្សនាដែលឃើញការអស់ទៅនៃសង្ខារទាំងឡាយ ដោយការអស់ទៅក្តី មគ្គញ្ញាណ គឺ ការឃើញការប្រាសចាកតម្រេកដោយសមុច្ឆេទ គឺ ព្រះនិព្វាន ដោយការប្រាសចាកតម្រេកក្តី ឈ្មោះថា ការពិចារណាឃើញការប្រាសចាកតម្រេក (វិរាគានុបស្សនា) ។ បុគ្គលអ្នកព្រមព្រៀងដោយការប្រាសចាកតម្រេកទាំង ២ នោះ ឈ្មោះថា អ្នកពិចារណាឃើញការប្រាសចាកតម្រេក (វិរាគានុបស្សី) ព្រះមានព្រះភាគទ្រង់សំដៅដល់បុគ្គលអ្នកព្រមព្រៀងដោយការប្រាសចាកតម្រេកនោះ ទើបត្រាស់ត្រាស់ថា **ពិចារណាឃើញការប្រាសចាកតម្រេក (វិរាគានុបស្សី)** អធិប្បាយថា បុគ្គលអ្នកពិចារណាឃើញដោយការប្រាសចាកតម្រេក ។ សូម្បីក្នុង **បុគ្គលពិចារណាឃើញការរលត់** ក៏ន័យនេះដូចគ្នា ។ ក៏សូម្បីការរលត់ក៏មាន ២ យ៉ាងដូចគ្នា គឺ ការរលត់ព្រោះអស់ទៅ (ខយនិរោធ) ១ ការរលត់ដោយសមុច្ឆេទ (អច្ចន្តនិរោធ) ១ ។ បទថា **បដិនិស្សគ្គានុបស្សី** (ពិចារណាឃើញនូវការ

លះបង់) នេះ ការលះបង់ (វោសគ្គៈ) ហៅថា កិរិយាលះបង់ , (បដិ-និស្សគ្គៈ) ការលះបង់នោះ ក៏មាន ២ យ៉ាងគឺ កិរិយាលះបង់ដោយការបរិច្ចាគ (បរិច្ចាគវោសគ្គៈ) ១ ការលះបង់ដោយការស្ទុះទៅ (បក្ខន្ទន-វោសគ្គៈ) ១ ។ បណ្ដាកិរិយាលះបង់ទាំង ២ យ៉ាងនោះ វិបស្សនាឈ្មោះថា កិរិយាលះបង់ដោយការបរិច្ចាគ ។ ពិតណាស់ វិបស្សនានោះរមែងលះបង់បាននូវកិលេស និងខន្ធ ដោយអំណាចតទង្គប្បហាន ។ មគ្គឈ្មោះថា ការលះបង់ដោយការស្ទុះទៅ ។ ពិតហើយ មគ្គនោះរមែងស្ទុះទៅកាន់ព្រះនិព្វានដោយជាអារម្មណ៍ ។ម្យ៉ាងទៀត មគ្គនោះ ឈ្មោះថា កិរិយាលះបង់ ព្រោះហេតុសូម្បីទាំងពីរ គឺ ព្រោះលះបង់ខន្ធ និងកិលេសដោយសមុច្ឆេទប្បហាន និងព្រោះកិរិយាស្ទុះទៅក្នុងព្រះនិព្វាន វិបស្សនាឈ្មោះថា កិរិយាលះបង់ដោយការបរិច្ចាគ ព្រោះលះកិលេស និងខន្ធទាំងឡាយ , មគ្គ ឈ្មោះថា កិរិយាលះដោយការស្ទុះទៅ ព្រោះចិត្តរមែងស្ទុះទៅក្នុងការរលត់ គឺ និព្វានធាតុ ព្រោះហេតុនោះ បទទាំងពីរនេះ ទើបចាត់ចូលបានក្នុងមគ្គ បុគ្គលអ្នកព្រមព្រៀងដោយវិបស្សនា និងមគ្គ ទាំងពីរ

នោះ រមែងឈ្មោះថា បុគ្គលពិចារណាឃើញកិរិយាលះបង់ ព្រោះប្រកបដោយការពិចារណាឃើញកិរិយាលះបង់នេះ ។ ព្រះមានព្រះភាគទ្រង់សំដៅយកបុគ្គលនោះ ទើបត្រាស់យ៉ាងនេះ ។

បទថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ (រមែងមិនប្រកាន់អ្វីៗក្នុងលោក)** បានដល់ ភិក្ខុនោះរមែងមិនប្រកាន់ មិនកាន់យក មិនចាប់ប្រកាន់ធម្មជាតិណា គឺ សង្ខារសូម្បីណាមួយដោយអំណាចតណ្ហា ។ បទថា **អនុបាទិយំ ន បរិត្តស្សតិ (កាលមិនប្រកាន់មាំហើយ រមែងមិនតក់ស្លុត)** បានដល់ កាលមិនប្រកាន់មាំ រមែងមិនតក់ស្លុត ញាប់ញ័រ ព្រោះការតក់ស្លុតដោយអំណាចតណ្ហា ។ បទថា **បច្ចត្តញ្ញេវ បរិនិព្វាយតិ (ក៏រមែងរំលត់កិលេសឲ្យស្ងប់ចំពោះតែម្យ៉ាង)** បានដល់ រមែងរំលត់ ដោយការរំលត់កិលេសដោយខ្លួនឯងតែម្យ៉ាង ។ ក៏បច្ចវេក្ខណញ្ញាណរបស់ភិក្ខុនោះ ព្រះមានព្រះភាគត្រាស់សម្តែងដោយន័យជាដើមថា **ខីណា ជាតិ (ជាតិអស់ហើយ)** ។ ព្រះមានព្រះភាគ ត្រូវព្រះមហាមោគ្គល្លានទូលសួរដល់បដិបទាដែលជាចំណែកខាងដើមរបស់ព្រះខីណាស្រព ដោយសង្ខេបហើយ ទើប

ត្រាស់ដោយសង្ខេបដូចគ្នា ។ តែព្រះសូត្រនេះមានទាំងព្រះឱវាទ មានទាំងវិបស្សនាសម្រាប់ព្រះថេរៈ ។ ព្រះថេរៈនោះចម្រើនវិបស្សនាអាស្រ័យព្រះសូត្រនេះហើយ ក៏បានសម្រេចព្រះអរហត្ត ។

ចប់អដ្ឋកថា មោគ្គលានសូត្រទី ៨

# អដ្ឋកថា បុញ្ញវិបាកសូត្រទី ៩

## ផលនៃបុណ្យ

គប្បីជ្រាបវិនិច្ឆ័យក្នុង បុញ្ញវិបាកសូត្រទី ៩ ដូចតទៅនេះ ៖

[៥៩] បទថា **មា ភិក្ខវេ បុញ្ញានំ ភាយត្ថ (ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឡើយ)** បានដល់ ពួកអ្នកកាលនឹងធ្វើបុណ្យ កុំខ្លាចបុណ្យទាំងនោះឡើយ ។ ដោយបទថា **មេត្តចិត្តំ ភាវេសឹ (តថាគតបានចម្រើនមេត្តាចិត្ត)** ព្រះមានព្រះភាគទ្រង់សំដែងថា តថាគតអប់រំចិត្តធ្វើឲ្យប្រណីតឲ្យប្រកបដោយមេត្តា ដែលប្រកបដោយឈានពួក ៣ និងពួក ៤ ។ បទថា **សំវដ្ដមានេ សុទាហំ (បានឮថា... ដល់នូវការវិនាស)** កាត់បទជា **សំវដ្ដមានេ សុទំ អហំ** ។ បទថា **សំវដ្ដមានេ (ដល់នូវសេចក្ដីវិនាស)** បានដល់ កាលលោកនេះដែលវិនាសដោយភ្លើង គឺ ដែលភ្លើងធ្វើឲ្យវិនាស ។ បទថា **ធម្មិកោ (តាំងនូវក្នុងធម៌)** បានដល់ ប្រកបដោយកុសលធម៌ ១០ ប្រការ ។ បទថា **ធម្មរាជា (ជាធម្មរាជា)** នេះជាវេវចនៈរបស់ពាក្យថា តាំងនៅក្នុងធម៌នោះ ។ម្យ៉ាងទៀត ឈ្មោះថា

ធម្មរាជា ព្រោះទ្រង់បានរាជសម្បត្តិដោយធម៌ ។ បទថា **ចាតុរន្តោ (ក្នុងទីបំផុតនៃសមុទ្រទាំង ៤)** បានដល់ មានភាពជាធំលើដែនដីដែលឈ្មោះថា ចតុរន្ត ដោយអំណាចមានមហាសមុទ្រទាំង ៤ មាន ក្នុងទិសបូព៌ាជាដើម ។ បទថា **វិជិតាវី (អ្នកឈ្នះសង្គ្រាម)** បានដល់ អ្នកពិជិតសង្គ្រាម ។ ជនបទរបស់ស្តេចចក្រពត្តិនោះ ដល់នូវភាពគង់វង្សស្ថិតស្ថេរ ព្រោះហេតុនោះ ទើបឈ្មោះថា **ជនបទត្ថាវរិយប្បត្តោ (មានជនបទដល់នូវភាពមាំមួន)** ។

បទថា **បរោសហស្សំ (ច្រើនពាន់)** បានដល់ មានព្រះឱរសច្រើនជាង ១.០០០ ព្រះអង្គ ។ បទថា **សូរា (សុទ្ធតែជាអ្នកក្លៀវក្លា)** បានដល់ អ្នកមិនខ្លាច ។ ក្នុងបទថា **វីរង្គរូបា (ជាអ្នកជាញជ័យ)** មានវិគ្រោះដូចតទៅនេះ អង្គរបស់អ្នកក្លាហាន ឈ្មោះថា អង្គអ្នកក្លាហានជាញជ័យ ។ ពាក្យនេះជាឈ្មោះនៃសេចក្តីព្យាយាម ។ អង្គអ្នកក្លាហាន ជាអង្គរបស់ឱរសទាំងនោះ ព្រោះហេតុនោះ ឱរសទាំងនោះឈ្មោះថា **អ្នកជាញជ័យ** ។ អធិប្បាយថា ឱរសទាំងនោះមិនខ្ជិលច្រអូស ជាអ្នកមានសេចក្តីព្យាយាម

ជាប្រក្រតី មានសេចក្តីព្យាយាមជាសការៈ និងមានសេចក្តីព្យាយាមច្រើន សូម្បីនឹងច្បាំងទាំងថ្ងៃទាំងយប់ក៏មិនទៀយហត់ ។ បទថា **សាគរបរិយន្តំ (ដែលមានសាគរជាទីបំផុត)** បានដល់ មានមហាសមុទ្រទល់នឹងភ្នំចក្រវាឡជាដែនព័ទ្ធជុំវិញ ។ បទថា **អទណ្ឌេន (មិនចាំបាច់ប្រើអាជ្ញា)** បានដល់ វៀរចាកអាជ្ញា គឺ ការទទួលសំណូកដោយទ្រព្យខ្លះ ដាក់អាជ្ញាផ្ទូវច្បាប់ខ្លះ ដោយដាក់គុក កាត់ដៃជើង និងប្រហារជីវិតខ្លះ ។ បទថា **អសត្ថេន (មិនបាច់ប្រើគ្រឿងសស្ត្រា)** បានដល់ វៀរចាកសស្ត្រាជាគ្រឿងបៀតបៀនអ្នកដទៃ មានសស្ត្រាមានមុខម្ខាងជាដើម ។ បទថា **ធម្មេន អភិវិជិយ (គ្រប់គ្រង... ដោយធម៌)** បានដល់ ព្រះរាជាដែលជាសត្រូវ ទ្រង់ទទួលស្តេចនោះយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គមេត្តាស្តេចមកចុះ ។ ទ្រង់ឈ្នះអស់ទាំងផែនដី មានប្រការដូចពោលហើយ ដោយធម៌តែម្យ៉ាង ដោយន័យមានជាអាទិ៍ថា មិនគប្បីសម្លាប់ជីវិតសត្វ ។

ដោយបទថា **សុខេសិនំ (អ្នកស្វែងរកសេចក្តីសុខ)** ព្រះមានព្រះភាគត្រាស់ហៅសត្វទាំងឡាយដែលស្វែងរកសេចក្តីសុខ ។ បទថា **សុញ្ញព្រហ្ម-**

*ឋគោ (ចូលដល់វិមានព្រហ្មលោកដែលសូន្យ) បានដល់ អ្នកចូលដល់វិមានរបស់ព្រហ្មដែលសូន្យទទេ ។ បទថា* ***ឋឋវឹ ឥមំ*** *(ឋឋវីមណ្ឌលនេះ) បានដល់ ក្នុងផែនដីធំដែលមានសាគរព័ទ្ធជុំវិញនេះ ។ បទថា* ***អសាហ-សេន*** *(មិនកំហែងគំរាម) បានដល់ ដោយកម្មដែលមិនបាច់កំហែងគំរាម ។ បទថា* ***សមេន មនុសាសិ តំ*** *(ទូន្មាន... ដោយធម៌ដ៏ស្មើ) បានដល់ ប្រៀនប្រដៅដោយកម្មដ៏ស្មើ ។ បទថា* ***តេហិ ឯតំ សុទេសិតំ*** *(ឋានៈដូចដែលពោលមកនេះ ព្រះពុទ្ធទាំងឡាយ... ទ្រង់សំដែងទុកល្អហើយ) បានដល់ ឋានៈនេះ គឺ មានប្រមាណប៉ុណ្ណោះ ដែលព្រះពុទ្ធទាំងឡាយទ្រង់សង្គ្រោះមនុស្សលោក ទ្រង់មានព្រះមហាករុណាទាំងនោះ ទ្រង់សំដែងល្អហើយ ត្រាស់ល្អហើយ ។ បទថា* ***ឋថព្យា*** *(ជាស្តេចផែនដី) បានដល់ ជាម្ចាស់ផែនដី ។*

ចប់អដ្ឋកថា បុញ្ញាភិចាកសូត្រទី ៩

# អដ្ឋកថា ភរិយាសូត្រទី ១០

## ភរិយា ៧ ពួក

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភរិយាសូត្រទី ១០ ដូចតទៅនេះ ៖*

*[៦០] បទថា **កេវដ្ដា មញ្ញេ មច្ឆេ វិលោបេតិ** (ទំនងដូចជាព្រានសន្ទូចចាប់ត្រី) បានដល់ ក្នុងទីដែលពួកព្រានសន្ទូចដាក់សំណាញ់ (ចាប់ត្រី) រាំងទុក ពេលលើកសំណាញ់ឡើងផុតអំពីទឹកប៉ុណ្ណោះ អ្នកចាប់ត្រីក៏បញ្ចេញសំឡេងលាន់ឡើង ។ ព្រះមានព្រះភាគត្រាស់សំដៅយកសំឡេងនោះ ទើបត្រាស់ពាក្យនោះ ។ បទថា **សុជាតា** (នាងសុជាតា) បានដល់ នាងជាប្អូនស្រីរបស់នាងវិសាខាមហាឧបាសិកា ។ បទថា **សា នេវ សស្សុំ អាទិយតិ** (នាងមិនជឿម្ដាយក្មេក) បានដល់ នាងសុជាតានោះមិនធ្វើវត្តបដិបត្តិ ដែលស្រីកូនប្រសារគប្បីធ្វើដល់មាតារបស់ស្វាមី ទាំងមិនរាប់អានមាតាស្វាមីថា ជាម្ដាយក្មេក ។ បទថា **ន សស្សុំ អាទិយតិ** (មិនអើពើនឹងឪពុកក្មេក) បានដល់ នាងសុជាតានោះមិនជឿ មិនស្ដាប់សូម្បីពាក្យរបស់ឪពុកក្មេក ។ ព្រោះដូច្នោះ ទើបឈ្មោះថា នាងមិនស្ដាប់ មិនជឿ*

ព្រោះនាងមិនអើពើខ្វះ ព្រោះនាងមិនគោរពខ្វះ ។ សូម្បីក្នុងពាក្យដ៏សេស ក៏ន័យនេះដូចគ្នា ។ អនាថបិណ្ឌិកសេដ្ឋីនាំយករឿងមារយាទរបស់ស្ត្រីកូនប្រសារមក ហើយអង្គុយចំពោះព្រះភក្ត្ររបស់ព្រះសាស្ដា ដោយប្រការដូច្នេះ ។ ចំណែកនាងសុជាតានោះគិតថា សេដ្ឋីនេះនឹងពោលសរសើរគុណរបស់យើងក្នុងសំណាក់ព្រះទសពល ឬនិងពោលទោស ហើយបានទៅឈរស្ដាប់ក្នុងទីជិត ។ លំដាប់នោះ ព្រះសាស្ដាត្រាស់ហៅនាងមកដោយព្រះតម្រាស់ថា មកចុះ សុជាតា ។

បទថា **អហិតានុកម្បិនី** (មិនអនុគ្រោះនូវប្រយោជន៍) បានដល់ជាអ្នកមិនអនុគ្រោះដោយប្រយោជន៍ដ៏ចម្រើន ។ បទថា **អញ្ញេសុ** (ក្នុងប្រុសដទៃ) បានដល់ ក្នុងបុរសដទៃៗ ។ បទថា **អតិមញ្ញតេ** (មើលងាយ) រមែងមើលងាយដោយអំណាចការមើលងាយ និងប្រមាថ ។ បទថា **ធនេន កីតស្ស** (ជាអ្នកដែលគេទិញមកដោយទ្រព្យ) កាត់បទជា **ធនេន កីតា អស្ស** ។ បទថា **វធាយ ឧស្សុក្កា** (ព្យាយាមដើម្បីសម្លាប់ប្តី) បានដល់ដល់នូវសេចក្តីព្យាយាមដើម្បីសម្លាប់ ។ បទថា **យំ ឥត្ថិយា វិន្ទតិ សាមិ-**

*កោ ធនំ (ស្វាមីរបស់ស្រី... បានដោយទ្រព្យណាមក)* បានដល់ ស្វាមីរបស់ស្ត្រីរមែងបានមកនូវទ្រព្យណា ។ បទថា **អប្បម្បិ តស្មា អបហាតុមិច្ឆតិ** *(ប្រាថ្នាដើម្បីកិបកេងយកនូវទ្រព្យសូម្បីបន្តិចបន្តួច)* បានដល់ កិរិយាប្រាថ្នានឹងលួចទ្រព្យសូម្បីបន្តិចបន្តួច គឺ ព្យាយាមនឹងលួចទ្រព្យសូម្បីតិចតួចមានអង្ករដែលដាក់ក្នុងថ្នាំង ដែលលើកឡើងដាំលើចង្ក្រានភ្លើង ។ បទថា **អលសា** *(ខ្ជិលច្រអូស)* បានដល់ ជាអ្នកអង្គុយកុកក្នុងទីដែលខ្លួនអង្គុយឈរកុកក្នុងទីដែលខ្លួនឈរ ។ បទថា **ផរុសា** *(រឹងរូស)* បានដល់ ជាអ្នករឹងរូស ។ បទថា **ទុរុត្តវាទិនី** *(ពោលនូវពាក្យអាក្រក់)* បានដល់ ជាអ្នកមានប្រក្រតីពោលវាចាជាទុព្ភាសិត វាចាអាក្រក់ គឺ ពោលពាក្យអាក្រក់និងរឹងរូសនោះឯង ។ បទថា **ឧដ្ឋាយកានំ អភិភុយ្យ វត្តតិ** *(ប្រព្រឹត្តគ្របសង្កត់នូវស្វាមីដែលមានព្យាយាមប្រឹងប្រែង)* នេះ មានវិនិច្ឆ័យដូចតទៅនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់ស្វាមីដែលសម្បូរដោយសេចក្តីព្យាយាមជាគ្រឿងក្រោកឡើង ដោយស័ព្ទជាពហុវចនៈថា **ឧដ្ឋាយកានំ** *(អ្នកព្យាយាម)* ដូច្នេះ ។ កិរិយាប្រព្រឹត្តគ្របសង្កត់ស្វាមីអ្នកបរិបូរដោយសេចក្តីព្យាយាម

ប្រឹងប្រែងនោះ ហើយធ្វើស្វាមីនោះឲ្យនូវក្នុងអំណាចរបស់ខ្លួន ។ បទថា **បមោទតិ (ត្រេកអររីករាយ)** បានដល់ រមែងជាអ្នករីករាយ ។ បទថា **កោលេយ្យកា (ជាស្ត្រីមានត្រកូល)** បានដល់ ជាស្ត្រីប្រកបព្រមដោយត្រកូល ។ បទថា **បតិព្វតា (មានវត្តបដិបត្តិដល់ស្វាមី)** បានដល់ ជាអ្នកមានស្វាមីដូចទេវតា ។ បទថា **វទទណ្ឌតជ្ជិតា**[1] **(ស្ត្រីដែលស្វាមីជេរ វាយ គំរាមដោយដំបង)** បានដល់ ភរិយាដែលស្វាមីកាន់កំណាត់ឈើគំរាមដោយការសម្លាប់ ពោលថា អញនឹងវាយឯង ។ បទថា **ទាសីសមំ (អ្នកស្មើដោយទាសី)** បានដល់ នាងសុជាតាក្រាបទូលថា សូមព្រះមានព្រះភាគទ្រង់ចាំខ្ញុំព្រះអង្គថា ជាទាសីអ្នកបរិបូរដោយវត្តបដិបត្តិក្នុងស្វាមី ហើយតាំងនូវក្នុងសរណៈទាំង ៣ ។

ចប់អដ្ឋកថា ភរិយាសូត្រទី ១០

---

(១) បិដកជា វធទណ្ឌតជ្ជិតា ។

# អដ្ឋកថា កោធនាសូត្រទី ១១

## បុគ្គលអ្នកក្រោធរមែងបានធម៌ ៧ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង កោធនាសូត្រទី ១១ ដូចតទៅនេះ ៖

[៦១] បទថា **សបត្តកន្តា (ជាសេចក្តីបំណងនៃសត្រូវ)** បានដល់ ជាទីពេញចិត្ត គឺ ជាទីរីករាយរបស់បុគ្គលជាសត្រូវ របស់បុគ្គលមានពៀរនឹងគ្នា គឺ បុគ្គលជាសត្រូវប៉ុណ្ណោះ ត្រូវការហើយ ប្រាថ្នាហើយ ។ បទថា **សបត្តការណា (ជាសេចក្តីត្រូវការរបស់បុគ្គលជាសត្រូវ)** បានដល់ ជាហេតុនៃប្រយោជន៍របស់បុគ្គលជាសត្រូវ របស់បុគ្គលមានពៀរនឹងគ្នា ។ បទថា **កោធបរេតោ (មានសេចក្តីក្រោធរួបរឹតហើយ)** បានដល់ ជាអ្នកនៅក្នុងអំណាចសេចក្តីក្រោធ ។ បទថា **បចុរត្ថតាយ (ឲ្យ...មានសេចក្តីចម្រើន)** បានដល់ ដើម្បីប្រយោជន៍ដ៏ច្រើន ដើម្បីប្រយោជន៍ដ៏ធំទូលាយ ។ បទថា **អនត្ថំបិ (សូម្បីនឹងកាន់យកវត្ថុដែលមិនមានប្រយោជន៍)** បានដល់ សូម្បីដល់នូវសេចក្តីមិនចម្រើន ។ បទថា **អត្ថោ មេ គហិតោ (យើងកាន់យកវត្ថុដែលជាប្រយោជន៍)** បានដល់ យើងប្រកាន់យកតែសេចក្តីចម្រើន ។

បទថា **អថោ អត្ថំ គហេត្វាន (កាន់យកវត្ថុដែលមានប្រយោជន៍ហើយ)** បានដល់ លុះកាន់យកសេចក្តីចម្រើនបានហើយ ។ បទថា **អនត្ថំ បដិបជ្ជតិ (ត្រឡប់បដិបត្តិវត្ថុដែលមិនជាប្រយោជន៍)** បានដល់ រមែងកំណត់ថា យើងកាន់យកវត្ថុដែលមិនជាប្រយោជន៍ហើយ ។ បទថា **វធំ កត្វាន (ធ្វើបាណាតិបាត)** បានដល់ ធ្វើកម្ម គឺ បាណាតិបាតហើយ ។ **កោធសម្មាទសម្មត្តោ (ជាអ្នកស្រវឹងព្រោះសេចក្តីក្រោធ)** បានដល់ ជាបុគ្គលស្រវឹងហើយដោយសេចក្តីស្រវឹង គឺ សេចក្តីក្រោធ អធិប្បាយថា ជាអ្នកត្រូវសេចក្តីស្រវឹងចាប់យកហើយ ។ បទថា **អាយសក្យំ (ការមិនមានយស)** បានដល់ ភាពមិនមានយស អធិប្បាយថា ជាអ្នករកយសមិនបាន គឺ ជាអ្នកគ្មានយស ។ បទថា **អន្តរតោ ជាតំ (ដែលកើតមកពីខាងក្នុងនោះ)** បានដល់ កើតឡើងហើយក្នុងខាងក្នុង ។ បទថា **អត្ថំ ន ជានាតិ (រមែងមិនដឹងអត្ថ)** បានដល់ មិនដឹងប្រយោជន៍ គឺ សេចក្តីចម្រើន ។ បទថា **ធម្មំ ន បស្សតិ (មិនឃើញនូវធម៌)** បានដល់ រមែងមិនឃើញធម៌ គឺ សមថៈ និងវិបស្សនា ។ បទថា **អន្ធតមំ (សេចក្តីងងឹត)** បានដល់

សេចក្ដីធ្ងន់ដែលធ្វើឲ្យខ្វាក់ ឬសេចក្ដីធ្ងន់ស្ទះ ។ បទថា **សហតេ** (គ្រប សង្កត់) រមែងគ្របសង្កត់ ។ បទថា **ទុម្មង្កុយំ** (ធ្វើមុខក្រញូវ) បានដល់ ការមិនពេញចិត្ត គឺ ភាពជាអ្នកមិនគួរកោតក្រែង បានដល់ ភាពជាអ្នក មានទឹកមុខសៅហ្មង ។ បទថា **យតោ បតាយតិ** (កាលណា... កើត ឡើង) បានដល់ កើតឡើងក្នុងកាលណា ។ បទថា **ន វាចោ ហោតិ គារវោ** (ពាក្យនិយាយក៏មិនគួរគោរព) បានដល់ សូម្បីពាក្យសំដីក៏មិន គួរជាទីគោរព ។ បទថា **ន ទីបំ ហោតិ កញ្ចិនំ** (រមែងមិនមានទីពឹង សូម្បីតែបន្តិចឡើយ) បានដល់ ឈ្មោះថា ទីពឹងណាៗ រមែងមិនមាន ។ បទថា **តបនិយានិ** (ដែលឲ្យកើតសេចក្ដីក្ដៅក្រហាយ) បានដល់ កម្មដែល ធ្វើឲ្យកើតសេចក្ដីក្ដៅក្រហាយ ។ បទថា **ធម្មេហិ** (អំពីធម៌ទាំងឡាយ) បានដល់ អំពីធម៌ គឺ សមថៈ និងវិបស្សនា ។ បទថា **អារកា** (ទៅឆ្ងាយ) បានដល់ ក្នុងទីឆ្ងាយ ។ បទថា **ព្រាហ្មណំ** (ព្រាហ្មណ៍) បានដល់ ព្រាហ្មណ៍ គឺ ព្រះខីណាស្រព ។

បទថា **យាយ មាតុ កតោ** (ដែលមាតាចិញ្ចឹមហើយ) បានដល់

អ្នកដែលមាតាណាចិញ្ចឹម គឺ ទំនុកបម្រុងហើយ ។ បទថា **បាណទទឹ សន្តឹ** (ជាអ្នកឲ្យនូវជីវិត គឺ ការរស់) បានដល់ អ្នកឲ្យជីវិត ។ បទថា **ហន្តិ កុទ្ធា បុថុត្តានំ** (បុគ្គលក្រោធ... រមែងសម្លាប់ខ្លួនឯងបាន ព្រោះហេតុផ្សេងៗ) បានដល់ បុគ្គលក្រោធហើយ រមែងសម្លាប់ខ្លួនឯង ដោយហេតុផលផ្សេងៗ ជាច្រើន ។ បទថា **នានារូបេសុ មុច្ឆិតោ** (ដែលជ្រប់ទៅក្នុងរូបផ្សេងៗ) បានដល់ ជាអ្នកជ្រប់ហើយក្នុងអារម្មណ៍ផ្សេង ៗ ។ បទថា **រជ្ជុយា ពទ្ធា មិយ្យន្តិ** (យកខ្សែចងកសម្លាប់ខ្លះ) បានដល់ ប្រើខ្សែចងកសម្លាប់ ។ បទថា **បព្វតាមបិ កន្ទរេ** (លោតពីភ្នំសម្លាប់ខ្លួនខ្លះ) បានដល់ លោតពីកំពូលភ្នំសម្លាប់ខ្លួនក៏មាន ។ បទថា **ភូតហច្ចានិ** (មានតែសេចក្តីវិនាស) បានដល់ ដែលកម្ចាត់សេចក្តីចម្រើនចេញហើយ ។ សព្ទថា **ឥតាយំ** (តាមដែលពោលមក សេចក្តីក្រោធនេះ) កាត់បទថា **ឥតិ អយំ** ។ បទថា **តំ ទមេន សមុច្ឆិន្ទេ** (គប្បីលះសេចក្តីក្រោធនោះអស់បាន ដោយការហ្វឹកហាត់ខ្លួន) បានដល់ គប្បីកាត់សេចក្តីក្រោធបានដោយទមៈ (ការទូន្មានខ្លួន) ។ សួរថា ដោយ ទមៈ ដូចម្តេច ។ ឆ្លើយថាដោយ ទមៈ គឺ បញ្ញា វិរិយៈ និងទិដ្ឋិ ។ បទថា **បញ្ញាវិរិយេនទិដ្ឋិយា**

*(គឺ បញ្ញា សេចក្ដីព្យាយាម និងសម្មាទិដ្ឋិ) បានដល់ ដោយបញ្ញាដែលសម្បយុត្តដោយវិបស្សនា ដោយសេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្តដែលសម្បយុត្តដោយវិបស្សនា និងដោយសម្មាទិដ្ឋិក្នុងមគ្គ ។ បទថា* ***តថេវ ធម្មំ សិក្ខេថ*** *(គប្បីសិក្សាក្នុងធម៌ដូច្នោះ) បានដល់ បុគ្គលគប្បីលះអកុសលចេញបានដោយប្រការណា គប្បីសិក្សាក្នុងធម៌ គឺ សមថៈ និងវិបស្សនាដោយប្រការនោះនុ៎ះឯង ។ បទថា* ***មា នោ ទុម្មង្កុយំ អហុ*** *(សូមកាពជាអ្នកមានមុខក្រញូវកុំមានដល់យើងទាំងឡាយ) បានដល់ ប្រាថ្នាប្រយោជន៍នេះថា សូមភាពជាអ្នកមានមុខក្រញូវកុំមានហើយដល់យើងទាំងឡាយ ។ បទថា* ***អនាយាសា*** *(មិនមានការចង្អៀតចង្អល់ចិត្ត) បានដល់ មិនមានសេចក្ដីទាស់ចិត្ត ។ បទថា* ***អនិស្សុកា*** *(មិនមានសេចក្ដីប្រណែន) បានដល់ មិនដល់សេចក្ដីខ្វល់ខ្វាយក្នុងទីណាៗ ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ហើយ ។*

ចប់អដ្ឋកថា កោធនាសូត្រទី ១១

## ចប់អដ្ឋកថា អព្យាកតវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អដ្ឋកថា មហាវគ្គវណ្ណនាទី ២

## អដ្ឋកថា ហិរិសូត្រទី ១

### *កាលហិរិវិបត្តិ ធម៌ដទៃក៏វិបត្តិ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ហិរិសូត្រទី ១ ដូចតទៅនេះ ៖*

*[៦២] បទថា **ហតុបនិសោ** (មានទីអាស្រ័យត្រូវកម្ចាត់) បានដល់ មានហេតុត្រូវកម្ចាត់ហើយ គឺ មានបច្ច័យត្រូវកម្ចាត់ហើយ ។ បទថា **យថាភូតញ្ញាណទស្សនំ** (យថាភូតញ្ញាណទស្សនៈ) បានដល់ វិបស្សនាញាណទន់ខ្ចី ។ បទថា **និព្វិទាវិរាគោ** (និព្វិទា និងវិរាគៈ) បានដល់ វិបស្សនាដ៏មានកម្លាំង និងមគ្គ ។ បទថា **វិមុត្តិញ្ញាណទស្សនំ** (វិមុត្តិញ្ញាណទស្សនៈ) បានដល់ អរហត្តវិមុត្តិ និងបច្ចវេក្ខណញ្ញាណ ។*

ចប់អដ្ឋកថា ហិរិសូត្រទី ១

# អដ្ឋកថា សុរិយសូត្រទី ២

## ព្រះអាទិត្យ ៧ ដួង

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុរិយសូត្រទី ២ ដូចតទៅនេះ ៖*

[៦៣] *ព្រោះហេតុដែលទេសនារឿងព្រះអាទិត្យ ៧ ដួង ប្រព្រឹត្តទៅដោយអំណាចការសម្តែងសំវដ្តកប្ប ដែលវិនាសដោយភ្លើង ដូច្នោះ គប្បីជ្រាបបុរេចារិកកថា (ពាក្យដែលពោលនាំមុខ) នៃព្រះសូត្រនេះមុន តាំងអំពីដើមដូចតទៅនេះថា សំវដ្តកប្បមាន ៣*[១] *សំវដ្តសីមាមាន ៣*[២] *សំវដ្តមូលមាន ៣*[៣] *កោលាហលមាន ៣*[៤] *។ បុរេចារិកកថានោះ បានពោលទុកពិស្តារហើយក្នុងបុព្វេនិវាសានុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា ឯតទវោច (ត្រាស់ព្រះតម្រាស់នេះថា) បានដល់ ដើម្បីទ្រង់នឹង*

---

១- ដីកា = សំវដ្តកប្ប (កប្បវិនាស) : មាន ៣ គឺ វិនាសដោយទឹក, ដោយភ្លើង, ដោយខ្យល់ ។

២- សំវដ្តសីមា មាន ៣ គឺ អាភស្សរា (កើតដោយអំណាចតតិយជ្ឈាន) , សុភកិណ្ហា (តតិយជ្ឈាន) , វេហប្ផលា (ចតុត្ថជ្ឈាន) ។ ភ្លើងឆេះចាប់ពីក្រោមអាភស្សរាចុះមក ។ ទឹកធម្មាយកប្បចាប់ពីក្រោម សុភកិណ្ហាចុះមក , ខ្យល់ធម្មាយកប្បចាប់ពីខាងក្រោមវេហប្ផលាចុះមក ។

៣- សំវដ្តមូល ៣ គឺ ហេតុដែលធ្វើឲ្យវិនាស គឺ លោភៈ ទោសៈ មោហៈ ។

៤- កោលាហល ៣ គឺ កប្បកោលាហល , ពុទ្ធកោលាហល , ចក្រពត្តិកោលាហល ។

សំដែងការវិបត្តិរបស់សង្ខារទាំងឡាយ ទាំងដែលមានចិត្តគ្រប់គ្រង និង មិនមានចិត្តគ្រប់គ្រង តាមអធ្យាស្រ័យរបស់ភិក្ខុ ៥០០ រូប អ្នកចម្រើន អនិច្ចកម្មដ្ឋាន ព្រះមានព្រះភាគទើបត្រាស់ព្រះសូត្រនាំយកព្រះអាទិត្យ ៧ ដួង មកប្រៀបធៀប មានពាក្យជាដើមយ៉ាងនេះថា **អនិច្ចា ភិក្ខវេ សង្ខារា (ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀង)** ។

បណ្ដាបទទាំងនោះ បទថា **អនិច្ចា (មិនទៀង)** បានដល់ សង្ខារ ទាំងឡាយ ឈ្មោះថា មិនទៀង ដោយអត្ថថា មានហើយត្រឡប់ជាមិនមាន វិញ ។ បទថា **សង្ខារា (សង្ខារទាំងឡាយ)** បានដល់ សង្ខារធម៌ទាំងដែល មានចិត្តគ្រប់គ្រង និងមិនមានចិត្តគ្រប់គ្រង ។ បទថា **អទ្ធុវា (មិនឋិតថេរ)** បានដល់ ឈ្មោះថា មិនឋិតថេរ ដោយអត្ថថា មិនគង់វង្ស ។ បទថា **អនស្សាសិកា (មិនគួររីករាយ)** បានដល់ វៀរចាកធូរស្រាលនៃ ចិត្ត ។ បទថា **អជ្ឈោគាឡ្ហោ (លិចចុះ)** បានដល់ លិចចុះទៅក្នុងទឹក ។ បទថា **អច្ចុគ្គតោ (ខ្ពស់)** បានដល់ ងើបឡើងហើយអំពីផ្ទៃទឹក ។ បទថា **ទេវោ ន វស្សតិ (ភ្លៀងមិនបង្អុរចុះ)** បានដល់ ជាដំបូង ឈ្មោះថា មេឃ

ភ្លៀងដែលកើតក្នុងវេលាកប្បវិនាស(១) រួមគ្នាជាភ្លៀងតែមួយក្រុមដូចគ្នាតែមួយ ធ្លាក់ចុះក្នុងសែនកោដិចក្រវាឡ ។ ក្នុងកាលនោះ ពូជដែលដុះចេញមកហើយ រមែងមិនត្រឡប់ចូលទៅកាន់ផ្ទះវិញ(២) ។ តាំងអំពីនោះ ទឹករមែងដូចទឹកក្នុងធម្មក្រក (តម្រងទឹក) ក៏រីងស្ងួតទៅ ភ្លៀងសូម្បីមួយតំណក់ក៏មិនធ្លាក់ចុះទៀត ព្រោះហេតុនោះ ព្រះធម្មកថាដែលកាន់យកឧបមានេះជាប្រមាណ (ទ្រង់ប្រើឧបមានេះក្នុងព្រះធម្មទេសនា) ។ ក៏កាលលោកកំពុងវិនាស គឺ វិនាសតាំងអំពីអវិចីមហានរកមក រមែងវិនាសមុន ។ សត្វទាំងឡាយដែលចាកពីអវិចីមហានរកនោះ នឹងមកកើតក្នុងមនុស្សលោក និងក្នុងសត្វតិរច្ឆាន ។ សូម្បីសត្វដែលកើតក្នុងសត្វតិរច្ឆាន ក៏បានមេត្តាក្នុងបុត្រ និងបងប្អូន លុះស្លាប់ហើយ ក៏ទៅកើតក្នុងទេវតា និងមនុស្សទាំងឡាយ ។ ទេវតាទាំងឡាយត្រាច់ទៅផ្លូវអាកាស ស្រែកប្រាប់គ្នាថា ទីនេះក៏ជាទីមិនទៀង ទាំងមិនឋិតថេរ ពួកអ្នកចូលចម្រើនមេត្តា ចម្រើន

---

១ ភូមា = ឧបកប្បនមេឃោ ប្រែតាមច្បាប់ភូមា ។

២ ដីកា = ភ្លៀងធ្លាក់តែម្តងក៏ល្មមឲ្យពូជដុះចាន តែភ្លៀងក៏លែងធ្លាក់តទៅទៀត ពូជដែលដុះហើយក៏ងាប់អស់ មិនបង្កើតផលដើម្បីនាំត្រឡប់ចូលទៅកាន់ផ្ទះវិញ ។

ករុណា មុទិតា ឧបេក្ខាដល់គ្នានឹងគ្នាចុះ ។ សត្វទាំងនោះ លុះចម្រើនមេត្តាជាដើមហើយ ចុតិចាកទីនោះហើយ រមែងកើតក្នុងព្រហ្មលោក ។

ក្នុងបទថា **វិជគាមា (ពីជគាម)** មានវិនិច្ឆ័យដូចតទៅនេះ ពូជ ៥ ប្រភេទ ឈ្មោះថា ពីជគាម[១] ។ ពូជពណ៌ខៀវដែលមានឫស និងស្លឹកដុះលូតលាស់ហើយប្រភេទមួយ ឈ្មោះថា ភូតគាម ។ បទថា **ឱសថតិណវនប្បតយោ (រុក្ខជាតិថ្នាំ តិណជាតិ និងព្រៃឈើជាធំ)** មានវិនិច្ឆ័យដូចតទៅនេះ ដើមឈើដែលគេប្រើផ្សំថ្នាំរក្សារោគ ឈ្មោះថា **ឱសថ (រុក្ខជាតិថ្នាំ)** ។ ដើមឈើដែលមានខ្លឹមខាងក្រៅ ដូចជា ដើមត្នោត និងដើមដូងជាដើម ឈ្មោះថា **តិណជាតិ (ជាតិ)** ។ ដើមឈើដែលចម្រើនក្នុងព្រៃ ឈ្មោះថា **ព្រៃឈើធំ** ។ ខ្សែទឹកដ៏សេស វៀរស្ទឹងធំ ៥ ខ្សែ ឈ្មោះថា **កុន្នទិយោ (ស្ទឹង)** ។ អន្លង់ទឹកដ៏សេស វៀរស្រះធំ ៧ ឈ្មោះថា **កុសោព្ភា (បាភយណ៍)** ។ ក្នុងបទថា **ទុតិយោ សុរិយោ (ព្រះអាទិត្យដួងទី ២)** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ក្នុងកាលដែលមានព្រះអាទិត្យ

---

១ ពូជ ៥ យ៉ាងគឺ = ដុះអំពីឫស, ដុះអំពីដើម, ដុះអំពីថ្នាំង, ដុះអំពីត្រួយ, ដុះអំពីគ្រាប់ ។

ជួនទី ២ ជួនមួយរះ ជួនមួយលិច ។ ក្នុងគ្រាដែលមានព្រះអាទិត្យជួនទី ៣ ជួនមួយរះ ជួនមួយលិច ជួនមួយតាំងនៅកណ្តាល (ផ្ទៃមេឃ) ។ ក្នុងគ្រាដែលមានព្រះអាទិត្យជួនទី ៤ រមែងតាំងឡើងរៀងគ្នាជាលំដាប់ ដូចភិក្ខុ ៤ រូប ដែលត្រាច់បិណ្ឌបាតក្នុងផ្ទះ ៤ គ្រួសារ ឈរតាមលំដាប់ទ្វារផ្ទះ ដូច្នោះ ។ សូម្បីក្នុងគ្រាដែលមានព្រះអាទិត្យជួនទី ៥ ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **បលុជ្ជន្តិ** (រមែងដាច់រាត់រាយ) បានដល់ ដាច់ធ្លាក់ចុះ ។ បទថា **នេវ ឆារិកា បញ្ញាយតិ ន មសិ** (ផេះក៏មិនប្រាកដ កំញមក៏មិនប្រាកដ) បានដល់ ក្នុងទីមានប្រមាណប៉ុណ្ណោះ គឺផែនដីធំក្នុងចក្រវាឡ ស្តេចភ្នំសិនេរុ ភ្នំហិមពាន្ត ភ្នំចក្រវាឡ កាមាវចរ-សួគ៌ ៦ ជាន់ និងព្រហ្មលោកជាន់បឋមឈាន ត្រូវភ្លើងឆេះហើយ ផេះឬកំញម សូម្បីត្រឹមតែទឹងចាប់ដោយម្រាមដៃក៏មិនប្រាកដ ។

បទថា **កោ មន្តា កោ សទ្ធាតា** (នរណាដឹង នរណាជឿ) បានដល់ នរណាអាចនឹងឲ្យបុគ្គលដឹង និងជឿក្នុងរឿងនោះ ឬនរណាជាអ្នកជឿរឿងនោះ ។ បទថា **អញ្ញត្រ ទិដ្ឋបទេហិ** (ក្រៅអំពីអរិយសាវកអ្នកមានបទ

ដែលបានឃើញហើយ) បានដល់ ពួកអរិយសាវកដែលជាសោតាបន្ន អ្នកមានបទ (គឺព្រះនិព្វាន) ដែលខ្លួនឃើញហើយ អធិប្បាយថា នរណាហ្ន៎ នឹងជឿអ្នកដទៃ ។ បទថា **វីតភគោ (ប្រាសចាកសេចក្តីត្រេកអរ)** បានដល់ អ្នកប្រាសចាកភគៈ ដោយអំណាចវិក្ខម្ភនប្បហាន (លះបានដោយការគ្របសង្កត់) ។ បទថា **សាសនំ អាជានីសុ (ដឹងច្បាស់នូវពាក្យប្រៀនប្រដៅ)** បានដល់ សាវកទាំងឡាយដឹងពាក្យប្រៀនប្រដៅ គឺ ប្រព្រឹត្តតាមផ្លូវដើម្បីភាពជាសំឡាញ់នៃស្តេចព្រហ្ម ។ បទថា **សមសមគតិយោ (ជាអ្នកមានគតិស្មើ)** បានដល់ អ្នកមានគតិស្មើគ្នា គឺ មានគតិដូចគ្នា ដោយអាការទាំងពួង ក្នុងភពទី ២ ។ បទថា **ឧត្តរិ មេត្តំ ភាវេយ្យំ (គួរចម្រើនមេត្តាឲ្យក្រៃលែងឡើងទៀត)** បានដល់ អាត្មាអញគប្បីចម្រើនមេត្តាឲ្យលើសលុបឡើងទៅជាឧបចារឈាន គឺ ធ្វើឲ្យប្រណីតរហូតដល់ឈានពួក ៣ និងឈានពួក ៤ ។

បទថា **ចក្ខុមា (ទ្រង់មានព្រះចក្ខុ)** បានដល់ ព្រះសាស្តាទ្រង់មានព្រះចក្ខុ ៥ ។ បទថា **បរិនិព្វុតោ (បរិនិព្វាន)** បានដល់ ស្តេចបរិនិព្វាន

ដោយកិលេសបរិនិព្វាន ត្រង់ពោធិបល្ល័ង្កនោះឯង ។ លុះព្រះសាស្តាទ្រង់សម្តែងអនិច្ចលក្ខណៈហើយ ទ្រង់លើកយកព្រះធម្មទេសនាយ៉ាងនេះ ភិក្ខុដែលចម្រើនអនិច្ចកម្មដ្ឋានទាំង ៥០០ នោះ បញ្ជូនញាណទៅតាមក្រសែទេសនា សម្រេចព្រះអរហត្តលើអាសនៈដែលខ្លួនអង្គុយនុ៎ះឯង ។

ចប់អដ្ឋកថា សុរិយសូត្រទី ២

# អដ្ឋកថា នគរោបមសូត្រទី ៣

## *ព្រះសទ្ធម្មដូចជាគ្រឿងការពារនគរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នគរោបមសូត្រទី ៣ ដូចតទៅនេះ ៖*

[៦៤] *បទថា* **យតោ** *(ក្នុងកាលណា)* បានដល់ កាលណា ។ *បទថា* **បច្ចន្តិមំ** *(បច្ចន្តនគរ)* បានដល់ នគរដែលតាំងនៅក្នុងទីបំផុតនៃរដ្ឋ គឺ ចុងរដ្ឋ ។ ក៏កិច្ចនៃការរក្សានគរក្នុងមជ្ឈិមប្រទេស រមែងមិនមានដោយហេតុនោះ ទើបទ្រង់មិនបញ្ចូលក្នុងមជ្ឈិមប្រទេសនោះ ។ *បទថា* **នគរបរិក្ខារេហិ សុបរិក្ខិត្តំ** *(ការពារទុកល្អដោយគ្រឿងការពារ)* បានដល់ ធ្វើការប្រុងប្រៀបដោយគ្រឿងការពារនគរ ។ *បទថា* **អករណីយំ** *(ធ្វើអន្តរាយ... មិនបាន)* បានដល់ ដែលសត្រូវខាងក្រៅគប្បីធ្វើមិនបាន គឺយកឈ្នះមិនបាន ។ *បទថា* **គម្ភីរនេមា** *(ជីករណ្តៅដ៏ជ្រៅ)* បានដល់ រណ្តៅជ្រៅ ។ *បទថា* **សុនិខាតា** *(ដាំទុកយ៉ាងល្អ)* បានដល់ ដាំទុកល្អហើយ ។ ក៏ពួកអ្នកនគរ រមែងសាងសសរគោលនោះដោយឥដ្ឋខ្លះ ដោយថ្មខ្លះ ដោយឈើខ្លឹមមានឈើគគីជាដើមខ្លះ កាលសាងសសរគោលនោះ

ដើម្បីប្រយោជន៍ដល់ការគ្រប់គ្រង កសាងទុកខាងក្រៅព្រះនគរ កាលសាង ដើម្បីប្រយោជន៍តាក់តែង កសាងទុកក្នុងព្រះនគរ ។ កាលធ្វើសសរគោល នោះឲ្យសម្រេចដោយឥដ្ឋ ដ៏ជីករណ្តៅធំជ្រៅ ដាំចុះទៅ ឯខាងលើធ្វើជា ៨ ជ្រុង លាបដោយកំបោរ.ស ។ កាលណាដំរីយកប្រមោយទាញ ក៏មិន កម្រើក កាលនោះ សសរគោលនោះរមែងឈ្មោះថា ដាំចុះល្អហើយ ។ សសរគោល សូម្បីនឹងសម្រេចដោយសសរថ្មជាដើម ជាសសរមានប្រាំបី ជ្រុងនោះឯង ។ បើសសរទាំងនោះប្រវែង ៨ ហត្ថសោត ក៏ដាំចុះក្នុង រណ្តៅប្រមាណ ៤ ហត្ថ ខាងលើប្រមាណ ៤ ហត្ថ ។ សូម្បីក្នុងសសរ ប្រវែង ១៦ ហត្ថ ឬ ២០ ហត្ថ ក៏ន័យនេះដូចគ្នា ។ ក៏សសរបង្គោល ទាំងអស់ កប់ចុះទៅខាងក្រោមពាក់កណ្តាល ខាងលើពាក់កណ្តាល សសរ ទាំងអស់នោះ កោងដូចនោមគោ ព្រោះហេតុនោះ បុគ្គលរមែងអាចរៀប ឈើក្នុងចន្លោះសសរទាំងនោះហើយធ្វើការងារបាន ។ ម្យ៉ាងទៀត សសរ ទាំងនោះគេធ្វើក្បាច់ទុក លើកទង់ទុកផង ។ បទថា **បរិក្ខា** (គូ) បានដល់ គូទឹកដែលជីកទុកជុំវិញ ។ បទថា **អនុបរិយាយបថោ** (មានផ្លូវដើរតាម

ជុំវិញគូបាន) បានដល់ ផ្លូវធំខាងក្នុងក្បែរកំពែង ។ ដែលទាហានទាំងឡាយ តាំងនៅ ច្បាំងជាមួយពួកទាហានដែលតាំងនៅខាងក្រៅកំពែង ។ បទថា **សលាកំ (អាវុធមានលំពែង)** បានដល់ អាវុធមានកូនសរ និងលំពែង ជាដើម ។ បទថា **ជេវនិកំ (អាវុធដ៏មុត)** បានដល់ អាវុធដ៏សេស មាន អាវុធមានមុខម្ខាងជាដើម ។

បទថា **ហត្ថារោហា (ពលដំរី)** បានដល់ ជនទាំងពួងមានអាចារ្យ ហ្វឹកហាត់សេះ ពេទ្យរក្សាដំរី និងមនុស្សចាំមើលដំរីជាដើម ។ បទថា **អស្សារោហា (ពលសេះ)** បានដល់ ជនទាំងឡាយ មានអាចារ្យអ្នកហ្វឹក-ហាត់សេះ ពេទ្យរក្សាសេះ និងមនុស្សចិញ្ចឹមសេះជាដើម ។ បទថា **រថិកា (ពលរថ)** បានដល់ ជនទាំងពួង មានអាចារ្យអ្នកហ្វឹកហាត់ការបររថ ពល បររថ ពលរក្សារថ ។ បទថា **ធនុគ្គហា (ពលធ្នូ)** បានដល់ ទាហាន បាញ់ធ្នូ ។ បទថា **ចេលកា (កងកាន់ទង់)** បានដល់ ពួកទាហានអ្នក កាន់ទង់ជ័យនាំមុខក្នុងទីលានចម្បាំង ។ បទថា **ចលកា (អ្នកចាត់ចែងក្បួន ទ័ព)** បានដល់ អ្នកចាត់ចែងក្បួនទ័ពយ៉ាងនេះថា តំណែងព្រះរាជានៅទីនេះ

តាំណែងមហាមាត្យឈ្មោះនោះ នៅទីនេះ ។ បទថា **បិណ្ឌទាយកោ (កង នាំស្បៀង)** បានដល់ ទ័ពស្រួចវាយសំរុកចូល ។ បានឮថា ទាហានទាំង នោះវាយសំរុកទៅកាន់កងទ័ពសត្រូវ ទម្លាយពួកសត្រូវ ដូចទម្លាយដុំបាយ អធិប្បាយថា ទម្លាយទ្វារចូលទៅ ។ ន័យម្យ៉ាងទៀត ទាហានពួកណា នាំយកបាយ និងទឹកចូលទៅឲ្យដល់កងទ័ព ក្នុងកណ្ដាលសង្គ្រាមបាន ពាក្យ ថា បិណ្ឌទាយកានោះ ជាឈ្មោះរបស់ទាហានសូម្បីទាំងនោះ ។ បទថា **ឧគ្គា រាជបុត្តា (កងសេនាធិការ)** បានដល់ ពួកទាហានដែលជាកូនចៅ មានត្រកូលខ្ពស់ៗ ជំនាញក្នុងសង្គ្រាម ។ បទថា **បក្ខន្ទិនោ (កងវាយ លុកចូល)** បានដល់ ពួកទាហានដែលសួរគ្នាថា ពួកយើងនឹងទៅនាំយក សីសៈ ឬអាវុធរបស់នរណាមក បានទទួលពាក្យឆ្លើយថា របស់ទាហាន ឯណោះ ដូច្នេះ ហើយក៏លោតចូលទៅកាន់សង្គ្រាមនាំយកសីសៈ ឬអាវុធ នោះមកបាន ។ ទាហានពួកនេះ រមែងស្ទុះចូលទៅ ហេតុនោះ ទើបឈ្មោះ ថា **កងវាយលុក** ។ កងវាយលុក ដូចស្ដេចដំរីស្ទុះចូលទៅកាន់សង្គ្រាម ឈ្មោះថា **មហានាគា (ដូចដំរីរត់ចូលទៅ)** ។ ពាក្យនេះជាឈ្មោះរបស់ពួក

ទាហានដែលមិនថយក្រោយ ក្នុងកាលដំរីជាដើមមកប្រឈមមុខហើយ ។

បទថា **សូរា (កងទាហានក្លាហាន)** បានដល់ ពួកទាហានដែលក្លៀវ-ក្លាឯក សូម្បីពាក់អាវក្រោះក្រឡាសំណាញ់ក៏អាចឆ្លងសមុទ្រទៅបាន ។ បទថា **ចម្មយោធិនោ (កងទាហានអាវក្រោះ)** បានដល់ ទាហានដែលពាក់អាវក្រោះ ឬកាន់ខែលធ្វើចម្បាំង ។ បទថា **ទាសកបុត្តា (កងទាហានទាសៈ)** បានដល់ ទាហានទាសៈក្នុងផ្ទះ ដែលមានសេចក្ដីស្មោះស្ម័គ្រក្នុងចៅហ្វាយនាយយ៉ាងខ្លាំងក្លា ។ បទថា **ទោវារិកោ (ទាហានយាម)** បានដល់ ទាហានយាមទ្វារ ។ បទថា **វាសនលេបនសម្បន្នា (ព្រមដោយបន្ទាយដែលរៀបឥដ្ឋលាបកំបោរយ៉ាងល្អ)** បានដល់ កំពែងដែលប្រកបដោយការ.កឥដ្ឋ បិទប្រហោងទាំងពួង ដោយការបូកលាបកំបោរស ម្យ៉ាងទៀត ប្រកបដោយការ.កឥដ្ឋ ពោលគឺ កំពែងដែលប្រកបដោយបន្ទា និងបូកលាបដោយកំបោរសដ៏ក្រាស់រលោង ។ នៅតាមថែវនៃកំពែងដែលមានក្បាច់ ក៏មានការតាំងថ្នាំងពេញដោយទឹក និងលើកទង់ឡើង ។ បទថា **តិណកដ្ឋោទកំ (ស្មៅ ឈើ និងទឹក)** បានដល់ ស្មៅដែលនាំមករក្សាទុកក្នុងទីប្រេីនកន្លែង ដើម្បី

ជាអាហាររបស់សត្វ មានដំរី សេះជាដើម និងដើម្បីប្រយោជន៍ដល់ការប្រក់ផ្ទះ ឈើដែលនាំមកគរទុក ដើម្បីប្រយោជន៍ធ្វើផ្ទះ និងអុសជាំស្ងួតជាដើម និងទឹកដែលប្រើយន្តបូមចូលមក ក៏រក្សាទុកក្នុងស្រះបោក្ខរណី ។ បទថា **សន្និចិតំ ហោតិ (មានការសន្សំ)** បានដល់ រមែងជាការសន្សំទុកយ៉ាងល្អក្នុងទីច្រើនកន្លែង ត្រៀមទុកជាមុន ។ បទថា **អព្ភន្តរានំ រតិយា (ដើម្បីសេចក្តីសប្បាយ... នៃជនខាងក្នុង)** បានដល់ ដើម្បីប្រយោជន៍ដល់ភាពកក់ក្តៅចិត្តរបស់ពួកមនុស្សនៅក្នុងក្រុង ។ បទថា **អបរិតស្សាយ (មិនភ័យខ្លាច)** បានដល់ ដើម្បីប្រយោជន៍ដល់ការមិនភ័យខ្លាច ។ បទថា **សាលិយវកំ (ស្រូវខ្សាយ និងស្រូវដំណើប)** បានដល់ ស្រូវខ្សាយ និងស្រូវដំណើបជាច្រើន ។ បទថា **តិលមុគ្គមាសាបរណ្ណំ (មានល្ង សណ្តែកខៀវ សណ្តែកកាជមាស និងអបរណ្ណជាតិ)** បានដល់ ល្ង សណ្តែកខៀវ សណ្តែកកាជមាស និងអបរណ្ណជាតិដ៏សេស ។

ឥឡូវនេះ ព្រោះហេតុនៃកិច្ចកម្មក្នុងព្រះនគររបស់ព្រះតថាគតមិនមាន តែឧបមាមកហើយយ៉ាងនេះថា ក៏តថាគតនឹងសំដែងអរិយសាវកឲ្យ

ដូចជានគរ សទ្ធម្ម ៧ ឲ្យដូចជាគ្រឿងហែហមនគរ និងឈាន ៤ ឲ្យដូចជាអាហារ ៤ ទើបត្រឡប់ព្រះទេសនា ដាក់ព្រះអរហត្តចូលក្នុងឋានៈ ១១ ដូច្នោះ ដើម្បីនឹងប្រកាសទេសនានោះ ទើបទ្រង់ផ្តើមពាក្យមានជាអាទិ៍ថា **ឯវមេវ ខោ (ដូច្នោះដូចគ្នា)** ។ បណ្តាបទទាំងនោះ បទថា **សទ្ធម្មេហិ (ដោយព្រះសទ្ធម្ម)** បានដល់ ដោយធម៌ដ៏ប្រសើរ ។

បទថា **សទ្ធោ (អ្នកមានសទ្ធា)** បានដល់ ប្រកបដោយការជឿ និងដោយការជឿព្រោះផលប្រចក្ស ។ ក្នុងការជឿ ២ យ៉ាងនោះ សេចក្តីជឿ ដែលជឿផលនៃទាន និងសីលជាដើម ហើយបំពេញបុណ្យដែល មានទានជាដើម ឈ្មោះថា បង្អោនចិត្តជឿ (ឱកប្បនសទ្ធា) ។ ការជឿ ដែលមកហើយដោយមគ្គ ឈ្មោះថា ការជឿដោយឃើញច្បាស់ (បច្ចក្ខសទ្ធា) ។ សូម្បីក្នុងពាក្យថា ការជឿដោយសេចក្តីជ្រះថ្លា ក៏ជាការជឿដោយការឃើញច្បាស់ ។ គប្បីបង្ហាញលក្ខណៈជាដើមរបស់សទ្ធានោះ ឲ្យជាក់ច្បាស់ ។ លក្ខណៈនេះ ដោយពាក្យថា មហាបពិត្រ សទ្ធាមានការស្ទុះទៅជាលក្ខណៈ និងមានការផូរផង់ជាលក្ខណៈ ឈ្មោះថា លក្ខណៈរបស់សទ្ធា ។ ម្យ៉ាង

ទៀត ព្រះតម្រាស់ដែលត្រាស់ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ គប្បីជ្រាបបុគ្គលអ្នកមានសទ្ធា អ្នកជ្រះថ្លាហើយដោយឋានៈ ៣ យ៉ាង ។ ឋានៈ ៣ យ៉ាង ដូចម្តេច គឺ ជាអ្នកប្រាថ្នាឃើញបុគ្គលអ្នកមានសីលទាំងឡាយ ឈ្មោះថា ជានិមិត្តនៃសទ្ធា ។ ក៏អាហារនេះ ក្នុងព្រះបាលីថា ក៏អ្វីជាអាហាររបស់សទ្ធា ។ គួរពោលថា ការស្តាប់ព្រះសទ្ធម្ម ឈ្មោះថា ជាអាហាររបស់សទ្ធានោះ ។ ធម៌នេះ ក្នុងព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកច្រើនទៅដោយសេចក្តីនឿយណាយក្នុងរូប យ៉ាងណា ធម៌នេះ ឈ្មោះថា ជាធម៌សមគួរដល់ភិក្ខុអ្នកបួសដោយសទ្ធា ឈ្មោះថា អនុធម៌ (ធម៌សមគួរ) ដល់ភិក្ខុនោះ ។ ក៏សទ្ធានោះ មានកិច្ចច្រើនយ៉ាង ដោយការៈដែលនឹងឃើញសមគួរដូចជាកញ្ចប់បាយ ដែលខ្ចប់រួមគ្នាទុកជាដើម ព្រះមានព្រះភាគប្រកាសទុកហើយ ក្នុងព្រះសូត្រទាំងឡាយ មានជាអាទិ៍ថា សទ្ធារមែងរួបរួមទុកនូវស្បៀង សិរីជាទីដេកនៃភោគទ្រព្យទាំងឡាយ សទ្ធាជាមិត្រទីពីររបស់បុរស បុគ្គលរមែងឆ្លងឱឃៈបានដោយសទ្ធា សទ្ធាជាពូជ តបៈជាភ្លៀង ស្តេចដំរី គឺ ព្រះអរហន្ត មានសទ្ធាជាប្រមោយ មានឧបេក្ខា

ជាភ្នកដ៏ស្អាត ។ តែក្នុងឆកោបមសូត្រនេះ ព្រះមានព្រះភាគទ្រង់សំដែង សទ្ធានេះ ឲ្យដូចជាសសរគោល ព្រោះតាំងនៅដោយល្អ មិនញាប់ញ័រ ។

បទថា *សទ្ធេសិកោ (អ្នកមានសទ្ធាប្រៀបដូចសសរគោល)* បានដល់ ព្រះអរិយសាវក ធ្វើសទ្ធាឲ្យដូចជាសសរខឿន រមែងលះអកុសលបាន ។ ដូច្នោះ គប្បីធ្វើវាចាប្រកបដោយសេចក្តីក្នុងគ្រប់ៗ បទ ដោយន័យនេះ ។ ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ ការសង្រួមក្នុងទ្វារទាំង ៣ រមែងសម្រេច ផលដោយហិរិ និងឱត្តប្បៈ ការសង្រួមជាបារិសុទ្ធិសីល ៤ ។ ដូច្នោះ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគ ទ្រង់ដាក់ព្រះអរហត្ត ចូលក្នុងឋានៈ ១១ ហើយ ទ្រង់កាន់យកជាកំពូលនៃទេសនា ។

ចប់អដ្ឋកថា ឆកោបមសូត្រទី ៣

# អដ្ឋកថា ធម្មញ្ញូសូត្រទី ៨

## បុគ្គលអ្នកដឹងធម៌

គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មញ្ញូសូត្រទី ៨ ដូចតទៅនេះ ៖

[៦៨] បទថា **កាលំ ជានាតិ** (រមែងដឹងកាល) បានដល់ រមែងស្គាល់កាលដែលគួរ ដែលមកដល់ហើយ ។ បទថា **អយំ កាលោ ឧទ្ទេសស្ស** (នេះជាកាលនៃការសិក្សា) បានដល់ នេះជាវេលារៀនព្រះពុទ្ធវចនៈ ។ បទថា **បរិបុច្ឆាយ** (នៃការសាកសួរ) បានដល់ នៃការសាកសួរដល់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ហេតុ និងមិនមែនហេតុ ។ បទថា **យោគស្ស** (ប្រកបសេចក្តីព្យាយាម) បានដល់ នៃការលះបង់ចំពោះការងារក្នុងសេចក្តីព្យាយាម ។ បទថា **បដិសល្លានស្ស** (ពួនសម្ងំ) បានដល់ ការពួនសម្ងំ គឺ ភាពជាអ្នកនៅម្នាក់ឯង ។ បទថា **ធម្មានុធម្មប្បដិបន្នោ** (បដិបត្តិធម៌សមគួរដល់ធម៌) បានដល់ ជាអ្នកបដិបត្តិបដិបទាដែលជាចំណែកខាងដើមនៃធម៌ សមគួរដល់លោកុត្តរធម៌ ៩ ។ បទថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ បុគ្គលបរោបរញ្ញូ** (ភិក្ខុជាបុគ្គលបរោបរញ្ញូដោយ

ដោយប្រការដូច្នេះ) បានដល់ ភិក្ខុរមែងជាអ្នកស្គាល់ដល់កាលក្រៃលែង និង ទន់ខ្សោយ គឺ សេចក្តីចាស់ក្លា និងសេចក្តីទន់ខ្សីនៃបុគ្គលទាំងឡាយ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ធម្មញ្ញូសូត្រទី ៤

# អដ្ឋកថា បារិច្ឆត្តកសូត្រទី ៥

## ប្រៀបភិក្ខុដូចដើមបារិច្ឆត្តកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង បារិច្ឆត្តកសូត្រទី ៥ ដូចតទៅនេះ ៖

[៦៦] បទថា *បណ្ឌុបលាសោ (ស្លឹកមានពណ៌លឿង)* បានដល់ ស្លឹកឈើ ដែលទុំជ្រុះហើយ ។ បទថា *ជាលកជាតោ (កញ្ចុំនៃស្លឹក និងផ្កា)* បានដល់ មានកញ្ចុំស្លឹក និងផ្កាកើតព្រមគ្នា ។ ព្រោះថា កញ្ចុំស្លឹក និងកញ្ចុំផ្ការបស់ដើមបារិច្ឆត្តកៈនោះ ចេញព្រមៗ គ្នា ។ បទថា *ខារកជាតោ (ជាកញ្ចុំផ្កា និងកញ្ចុំស្លឹក)* បានដល់ ប្រកបហើយដោយកញ្ចុំស្លឹកឈើ និងកញ្ចុំផ្កា ដ៏ស្រស់ស្អាតដោយនៅបែបគ្នាជាចំណែកៗ ។ បទថា *កុឌុមលកជាតោ (ជាផ្កាក្តោប)* បានដល់ កើតជាផ្កាក្រពុំ ។ បទថា *កោកាសកជាតោ (ផ្តើមរីក)* បានដល់ ប្រកបដោយផ្កាទាំងឡាយ ដែលមានត្របកប្រេះ មានផ្ទៃផ្កាធំ នៅមិនទាន់រីក ។ បទថា *សព្វផាលិផុល្លោ (រីកស្គុសស្គាយ)* បានដល់ រីកល្អហើយដោយអាការទាំងពួង ។ បទថា *ទិព្វេ ចត្តារោ មាសេ (អស់រយៈ ៤ ខែ ជាទិព្វ)* បានដល់ រហូត ៤ ខែ

ដោយអាយុទិព្វ ។ តែសូម្បីរាប់តាមអាយុមនុស្ស រមែងមានអាយុដល់មួយម៉ឺនពីរពាន់ឆ្នាំ ។ បទថា **បរិចារេន្តិ** (ទំនុកបំរុង) បានដល់ ទេវតាទាំងនោះ រមែងញុំាងឥន្ទ្រិយទាំងឡាយឲ្យត្រាច់ទៅខាងនេះ ខាងនោះ អធិប្បាយថា រមែងលេង រមែងរីករាយ ។

បទថា **អាភាយ ផុដំ ហោតិ** (ផ្សាយរស្មីទៅ) បានដល់ ស្ថានទីទាំងនេះដែលរស្មីពាល់ត្រូវហើយ ក៏រស្មីរបស់ផ្កាឈើទាំងនោះ រមែងដូចជាពន្លឺព្រះអាទិត្យដែលស្រទន់ៗ ត្របកផ្ការបស់ផ្កាឈើទាំងនោះ មានខ្នាតប៉ុនឆ័ត្រធ្វើអំពីស្លឹកឈើ ខាងក្នុងផ្កាមានលំអងកេសរខ្នាតប៉ុននាឡិធំ ។ តែកាលដើមបារិច្ឆត្តកៈមានផ្ការីកហើយ មិនមានកិច្ចក្នុងការតោងឡើង មិនមានកិច្ចយកឈើច្នក់ទម្លាក់ មិនត្រូវយកប្រអប់ដាក់ផ្កាឈើមក ។ ខ្យល់សម្រាប់កាត់ក៏កើតឡើង កាត់ផ្កាឈើអំពីទង ។ ខ្យល់សម្រាប់ទទួល ក៏នឹងទទួលផ្កាឈើទុក ខ្យល់សម្រាប់បញ្ចូន ក៏នឹងបញ្ចូនទៅកាន់សុធម្មាទេវសភា ។ ខ្យល់សម្រាប់បោសសម្អាត ក៏បោសសម្អាតផ្កាឈើចាស់ៗ ចេញ ខ្យល់សម្រាប់ក្រាល ក៏រោយស្លឹក ត្របក និងកេសរ ។ មានធម្មាសនៈ

នៅត្រង់កណ្តាលសុធម្មាទេវសភា ។ បន្ទាប់ពីធម្មាសនៈ ក៏ក្រាលអាសនៈសម្រាប់សក្កៈទេវរាជ មានស្វេតច័ត្រទំហំ ៣ យោជន៍ បាំងខាងលើរតនបល្ល័ង្កដែលមានទំហំ ១ យោជន៍ ។ តពីនោះ ក៏ជាអាសនៈរបស់ទេវបុត្រ ៣៣ អង្គ តពីនោះ ក៏ជាអាសនៈរបស់ទេវតាអ្នកមានស័ក្តិធំពួកដទៃ តពីនោះ បាច់ផ្កាឈើក៏ជាអាសនៈសម្រាប់ទេវតាពួកមួយ ។ ពួកទេវតានាំគ្នាចូលទៅកាន់ទេវសភានោះ ហើយក៏អង្គុយចុះ ។ លំដាប់នោះ លំអងកេសរផុសចេញផ្កាឈើហុយឡើងទៅទល់ដល់ពិតាន (នៃសុធម្មាទេវសភា) ហើយធ្លាក់ចុះមក ធ្វើឲ្យអត្តភាពប្រមាណ ៣ គាវុត របស់ទេវតាទាំងឡាយដូចការតុបតែងស្រោចដោយទឹកល័ក្ខ ឬដូចជាលាបលនដោយលំអងមាសដូច្នោះ ។ តែទេវតាពួកខ្លះ កាន់យកផ្កាឈើមួយអន្លូងមួយផ្កា លេងវាយគ្នានឹងគ្នា ។ សូម្បីវេលាដែលលេងវាយគ្នា លំអងកេសរខ្ចាតប៉ុននាឡិធំក៏ខ្ចាយចេញ ធ្វើឲ្យសរីរៈដូចជាជ្រលក់ដោយមនោសិលា (ទឹកជាត) ដែលកើតឯងអំពីលំអងក្រអូបដែលបរិបូណ៌ដោយរស្មី ។ ការលេងនោះ ៤ ខែ ទើបចប់ ដោយអាការយ៉ាងនេះ ។ បទថា **អយមានុភាវោ** (អានុភាព...

មានដូច្នេះ) បានដល់ នេះជាអានុភាពដែលផ្សាយទៅតាមលំដាប់ ។

ឥឡូវនេះ ព្រោះហេតុដែលព្រះសាស្ដាមិនមានបំណង ដោយដើមបារិច្ឆត្តកព្រឹក្ស តែទ្រង់បំណងនឹងទ្រង់សំដែងអរិយសាវក ៧ ពួក ប្រៀបដូចដើមបារិច្ឆត្តកព្រឹក្សនោះ ដូច្នោះ ដើម្បីទ្រង់នឹងសំដែងដល់ព្រះអរិយ-សាវកទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវមេវ ខោ** (ដូច្នោះដូចគ្នា) ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **បព្វជ្ជាយ ចេតេតិ** (គិតនឹងចេញបួស) បានដល់ ព្រះអរិយសាវកគិតថា យើងនឹងបួស ។ បទថា **ទេវានំ** (ប្រៀបដូច... **របស់ទេវតា**) បានដល់ ដូចរបស់ពួកទេវតា ។ បទថា **យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆតិ** (សំឡេងក៏ឮផ្សាយឡើងទៅដរាបដល់ព្រហ្មលោក) បានដល់ សំឡេងសាធុការ រាប់តាំងអំពីផែនដីដរាបដល់ព្រហ្មលោក ជាសំឡេងតែមួយដូចគ្នា ។ បទថា **អយមានុភាវោ** (អានុភាព.. មានដូច្នេះ) បានដល់ នេះជាអានុភាពដែលផ្សាយទៅតាមលំដាប់របស់ភិក្ខុដែលជាព្រះខីណាស្រព ។ តែក្នុងព្រះសូត្រនេះ ចតុប្បារិសុទ្ធិសីលដែលអាស្រ័យបព្វជ្ជា កសិណបរិកម្មដែលទំនាក់ទំនងដល់បឋមឈាន ។ មគ្គ

៣ ផល ៣ ព្រមដោយវិបស្សនាដែលទំនាក់ទំនងរហូតដល់អរហត្តមគ្គ ។ ទេសនាវមែងកំណត់បាន យ៉ាងទាបខ្លះ ខ្ពស់ខ្លះ ទាំង ២ យ៉ាងខ្លះ ។ តែក្នុងព្រះសូត្រនេះ កំណត់ទាំង ២ យ៉ាង ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យនេះទុក ។ ក៏ក្នុងព្រះសូត្រនេះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទាំងសេចក្តីសាបសូន្យ និងសេចក្តីចម្រើនទុកដោយសង្ខេប ។

ចប់អដ្ឋកថា ចារិជ្ជត្តកសូត្រទី ៥

# អដ្ឋកថា សក្កច្ចសូត្រទី ៦

## *សេចក្តីគោរពក្នុងព្រះសាស្តាជាដើម*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សក្កច្ចសូត្រទី ៦ ដូចតទៅនេះ ៖*

[៦៧] *បទថា* ***បរិសុទ្ធា ច ភវិស្សន្តិ***[១] *(និងបរិសុទ្ធិ) បានដល់ធម៌ទាំងនេះនឹងបរិសុទ្ធ គ្មានមន្ទិលក្រៃលែងឡើងៗ ទៅ ។* ***ស*** *អក្សរក្នុងបទថា* ***សកម្មារគតោ*** *(ទៅដល់ជាងមាស) នេះ ត្រឹមតែជានិបាត ។ អធិប្បាយថា ទៅដល់ជាងហើយ គឺ ដល់ចង្ក្រានរបស់ជាងមាសហើយ ។*

ចប់អដ្ឋកថា សក្កច្ចៈសូត្រទី ៦

---

១ ក្នុងបិដកឃើញមានតែពាក្យថា = បរិសុទ្ធា ចេវ ភវិស្សន្តិ ។

# អដ្ឋកថា ភាវនាសូត្រទី ៧

## ភិក្ខុព្យាយាមចម្រើនភាវនា

គប្បីជ្រាបវិនិច្ឆ័យក្នុង ភាវនាសូត្រទី ៧ ដូចតទៅនេះ ៖

[៦៨] បទថា **អននុយុត្តស្ស (មិនព្យាយាមចម្រើន)** បានដល់ កាលបើភិក្ខុមិនប្រកបរឿយៗ ។ បទថា **សេយ្យថាបិ ភិក្ខវេ កុក្កុដិយា (ប្រៀបដូចមេមាន់មានពង... យ៉ាងណា)** បានដល់ ព្រះមានព្រះភាគត្រាស់ឧបមានេះទុកជាពីរប្រការ គឺ ធម៌ចំណែកខ្មៅ និងធម៌ចំណែកស (អកុសលនិងកុសល) ។ ក្នុងឧបមា ២ យ៉ាងនោះ ឧបមានៃធម៌ចំណែកខ្មៅ មិនធ្វើប្រយោជន៍ឲ្យសម្រេច , ឧបមានៃធម៌ចំណែកស ធ្វើប្រយោជន៍ឲ្យសម្រេច ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបប្រយោជន៍ដោយឧបមានៃធម៌ចំណែកសនោះឯង ។ ស័ព្ទថា **សេយ្យថា** ជានិបាតប្រើក្នុងអត្ថនៃឧបមា ។ ស័ព្ទថា **អបិ** ជានិបាតប្រើក្នុងអត្ថនៃសម្ភាវនៈ (សរសើរ) ។ ព្រះមានព្រះភាគទ្រង់សំដែងថា **សេយ្យថាបិ នាម ភិក្ខវេ (ប្រៀបដូច... យ៉ាងណា)** ដូច្នេះ ។ ក៏ក្នុងព្រះបាលីនេះថា **កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា**

(មេមាន់មានពង ៨ ក្តី ១០ ក្តី ១២ ក្តី ) មានវិនិច្ឆ័យដូចតទៅនេះ សូម្បី មាន់មានពងខ្វះ ឬលើសដោយប្រការដែលត្រាស់ទុកហើយក៏ពិត ដូច្នោះ ព្រះអង្គក៏ត្រាស់ពាក្យនេះទុក ដើម្បីឲ្យទេសនាពីរោះ ។ ព្រោះថា សេចក្តីពីរោះនៃពាក្យក្នុងលោក រមែងមានដោយប្រការដូច្នេះ ។ បទថា **តានស្សុ** (ពងទាំងនោះ) កាត់បទជា **តានិ អស្សុ** បានដល់ ពងមាន់ទាំងនោះគប្បីមាន ។ បទថា **កុក្កុដិយា សម្មា អធិសយិតានិ** (មេមាន់ក្រាបល្អហើយ) បានដល់ កាលបើមេមាន់ដែលឲ្យកំណើតនោះ សំឡបស្លាបដេកក្រាបលើពងទាំងនោះ ឈ្មោះថា **ក្រាបល្អហើយ** ។ បទថា **សម្មា បរិសេទិតានិ** (ឲ្យភាពកក់ក្តៅល្មមប្រមាណហើយ) បានដល់ កាលមាន់ឲ្យពងបានទទួលកំដៅ ផ្សាយកំដៅចូលដល់យ៉ាងល្អគ្រប់កាល អធិប្បាយថា ធ្វើឲ្យក្តៅសព្វហើយ ។ បទថា **សម្មា បរិភាវិតានិ** (ក្រាស់ល្អហើយ) បានដល់ អប់កំដៅដោយជុំវិញដោយល្អតាមកាលកំណត់ អធិប្បាយថា ពងបានទទួលក្លិន និងភាពកក់ក្តៅរបស់មេមាន់ ។

ពាក្យថា **កិញ្ចាបិ តស្សា កុក្កុដិយា** (សូម្បីមេមាន់នោះ... ក៏ពិត)

បានដល់ ព្រោះមេមាន់នោះធ្វើសេចក្ដីមិនប្រមាទ ដោយកិរិយា ៣ យ៉ាងនេះ មិនកើតសេចក្ដីប្រាថ្នាយ៉ាងនោះក៏ពិត ។ បទថា **អថខោ ភិក្ខវេ ភព្វា តេ** (សូម្បីដូច្នោះ កូនមាន់ទាំងនោះក៏អាច) បានដល់ ដែលពិតកូនមាន់ទាំងនោះគួរចោះចេញទៅបានដោយសួស្ដី ដោយន័យដែលពោលហើយ ក៏ព្រោះហេតុពងទាំងនោះ ដែលមេមាន់នោះ ឲ្យការថែរក្សាដោយអាការ ៣ យ៉ាងនេះ ទើបមិនស្អុយ ពងទាំងនោះនៅមានជ័រស្រស់ណា ជ័រស្រស់នោះដល់នូវការអស់ទៅ សំបកពងទើបស្ដើង ក្រចកជើង និងចុងចំពុះជារបស់រឹង កូនមាន់ទាំងឡាយរមែងចោះបំបែកបានឯង ព្រោះសំបកពងជារបស់ស្ដើង ពន្លឺខាងក្រៅរមែងប្រាកដចូលដល់ខាងក្នុង ដូច្នោះកូនមាន់ទាំងនោះនាំគ្នាគិតថា ពួកយើងដេកវៀនដៃជើង នៅក្នុងទីចង្អៀតអស់វេលាយូរហើយ ក៏ពន្លឺនេះរមែងប្រាកដខាងក្រៅ ឥឡូវនេះ ពួកយើងនឹងនៅជាសុខក្នុងទីខាងក្រៅនោះ បំណាងនឹងចេញទៅ យកជើងធាក់សំបកពងអើត.កចេញទៅ ។ តពីនោះ សំបកពងនោះក៏បែកជា ២ ចំណែក ។ កូនមាន់ទាំងនោះ រលាស់ស្លាប បញ្ចេញសំឡេងតាមសមគួរដល់វេលានោះ

ដើរចេញទៅ កាលចេញទៅបាន ក៏ត្រាច់ធ្វើខេត្តនៃផ្ទះឲ្យស្អាត ។

បទថា **ឯវមេវ ខោ** (ដូច្នោះដូចគ្នា) នេះ ជាការឧបមាឧបមេយ្យ ។ បទនោះគប្បីជ្រាបបាន ក៏ព្រោះប្រៀបធៀបដោយប្រការយ៉ាងនេះ ។ ពិតណាស់ កាលភិក្ខុនេះធ្វើអនុបស្សនា ៣ ថា បញ្ចក្ខន្ធ មិនទៀង ជាទុក្ខ ជាអនត្តា ក្នុងសន្តានចិត្តរបស់ខ្លួន ប្រៀបដូចជាមេមាន់នោះធ្វើកិរិយា ៣ យ៉ាង មានការដេកក្រាបពងជាដើម ការមិនធ្វើវិបស្សនាញាណឲ្យវិនាសដោយភិក្ខុអ្នកព្យាយាមប្រកបភាវនា ធ្វើអនុបស្សនា ៣ ឲ្យដល់ព្រម ប្រៀបដូចពងមាន់មិនស្អុយ ព្រោះកិរិយា ៣ យ៉ាង នៃមេមាន់ដល់ព្រមហើយ ការអស់ទៅនៃជ័រស្អិត គឺ សេចក្ដីពេញចិត្តដែលប្រព្រឹត្តទៅក្នុងភព ៣ ព្រោះអាស្រ័យភិក្ខុនោះធ្វើអនុបស្សនា ៣ ឲ្យដល់ព្រម ប្រៀបដូចការអស់ទៅនៃជ័រស្អិតនៃពងទាំងឡាយ ព្រោះមេមាន់នោះធ្វើកិរិយា ៣ យ៉ាង ភាពស្ដើងនៃសំបកពង គឺ អវិជ្ជា ត្រូវស្រាលស្ដើង ព្រោះអាស្រ័យភិក្ខុធ្វើអនុបស្សនា ៣ យ៉ាង ឲ្យដល់ព្រម ប្រៀបដូចភាពស្ដើងរបស់សំបកពងដោយការធ្វើកិរិយា ៣ យ៉ាង របស់មេមាន់ វិបស្សនាញាណជាធម៌ជាតិ

មុត រឹង ផូរផង់ និងក្លៀវក្លា ព្រោះភិក្ខុធ្វើអនុបស្សនា ៣ ឲ្យដល់ព្រម ប្រៀបដូចការដែលក្រចកនិងចំពុះរបស់កូន ប្រៀបដូចក្រចក និងចំពុះកូនមាន់ដែលចាស់ក្លា រឹង អាស្រ័យមេមាន់ធ្វើកិរិយា ៣ យ៉ាង វេលាប្រែប្រួល វេលាចម្រើន **វេលាតាំងគភ៌** [១] (ផ្តើមឲ្យផល) នៃវិបស្សនាញាណ ព្រោះភិក្ខុធ្វើអនុបស្សនា ៣ ឲ្យដល់ព្រម ប្រៀបដូចកូនមាន់ដែលប្រែប្រួលដោយការធ្វើកិរិយា ៣ យ៉ាងរបស់មេមាន់ វេលាដែលភិក្ខុនោះញុំាងវិប-ស្សនាញាណឲ្យតាំងគភ៌ ដោយការធ្វើអនុបស្សនា ៣ ឲ្យដល់ព្រមហើយប្រព្រឹត្តទៅ ជាអ្នកបានឧតុជាទីសប្បាយខ្លះ ភោជនជាទីសប្បាយខ្លះ បុគ្គលជាទីសប្បាយខ្លះ ធម្មស្សវនជាទីសប្បាយខ្លះ ដ៏សមគួរដល់វិបស្សនាញាណនោះហើយ អង្គុយលើអាសនៈមួយ ចម្រើនវិបស្សនា ទម្លាយសំបក គឺ អវិជ្ជា ដោយអរហត្តមគ្គ ដែលខ្ជួនលុះហើយដោយលំដាប់ ហើយទទះស្លាប គឺ អភិញ្ញា សម្រេចព្រះអរហត្តដោយសួស្តី គប្បីជ្រាបថា ដូចវេលាដែលកូនមាន់ទាំងឡាយទម្លាយសំបកដោយចុងក្រចកជើង ឬដោយចំពុះ ហើយ

---

១ តាំងនៅក្នុងអនុលោមញ្ញាណ មុននឹងជាគោត្រភូញ្ញាណ ។

ទទះស្លាបចេញទៅដោយសួស្តី ព្រោះការធ្វើនូវកិរិយា ៣ យ៉ាងរបស់មេមាន់ ឲ្យដល់ព្រម ។ មេមាន់ដឹងថា កូនមាន់ទាំងឡាយប្រែប្រួលហើយ រមែងទម្លាយសំបកពងមាន់ យ៉ាងណា សូម្បីព្រះសាស្តាក៏ដូច្នោះ ទ្រង់ជ្រាបថា ភិក្ខុនោះមានញាណចាស់ក្លាហើយ ទ្រង់ផ្សាយរស្មីទម្លាយសំបកពង គឺ អវិជ្ជា ដោយគាថាមានន័យអាទិ៍ថា ៖

អ្នកចូរដកចេញនូវសេចក្តីអាល័យរបស់ខ្លួន ដូចបុគ្គល
យកដៃដកគុម្ពផ្កាឈូកក្រហមក្នុងសារទកាល អ្នកចូរ
ចម្រើនឡើងនូវផ្លូវដ៏ស្ងប់ ព្រោះថា និព្វានដែលព្រះ
សុគតសំដែងទុកហើយ ។

ក្នុងវេលាចប់ព្រះគាថា ភិក្ខុនោះទម្លាយសំបកពង គឺ អវិជ្ជា ហើយក៏សម្រេចអរហត្ត ។ តាំងអំពីនោះមក កូនមាន់ទាំងនោះ ក៏ធ្វើទីនៃខេត្តឲ្យល្អ ហើយត្រាច់ទៅក្នុងខេត្តនោះ យ៉ាងណា ព្រះមហាខីណាស្រពសូម្បីនេះ ក៏ដូច្នោះ ចូលផលសមាបត្តិដែលមានព្រះនិព្វានជាអារម្មណ៍ហើយ ធ្វើសង្ឃារាមឲ្យល្អ ហើយត្រាច់ទៅ ។

បទថា **ពលគណ្ឌស្ស (នាយជាងឈើ)** បានដល់ ជាងឈើ ។ ក៏ជាងឈើនោះទ្រទ្រង់ទុកនូវកម្លាំង ពោលគឺ ឈើទ្រ រមែងនាំយកគ្រឿងឈើទៅបាន ព្រោះដូច្នោះ ទើបហៅថា ពលគណ្ឌៈ[១] ។ បទថា **វាសិជដេ (ត្រង់មានកាំបិត)** បានដល់ ត្រង់មានកាំបិតដែលចាប់កាន់ ។

បទថា **ឯត្តកំ វា មេ អជ្ជ អាសវានំ ខីណំ (ថ្ងៃនេះអាសវៈរបស់តថាគតអស់ទៅប៉ុណ្ណោះ)** បានដល់ ក៏អាសវៈទាំងឡាយរបស់បព្វជិត រមែងអស់ទៅអស់កាលជានិច្ច ដោយការលះ គឺ បព្វជ្ជា ដោយឧទ្ទេស ដោយបរិបុច្ឆា ដោយយោនិសោមនសិការ ដោយវត្តបដិបត្តិ ។ អធិប្បាយថា ក៏កាលអាសវៈទាំងឡាយអស់ទៅយ៉ាងនេះ ភិក្ខុនោះរមែងមិនដឹងថា ថ្ងៃនេះអាសវៈអស់ទៅប៉ុណ្ណោះ ថ្ងៃនេះអាសវៈអស់ទៅប៉ុណ្ណោះ ដូច្នេះ ។ ព្រះអង្គទ្រង់សំដែងអានិសង្សនៃវិបស្សនាដោយឧបមាយ៉ាងនេះ ។ បទថា **ហេមន្តិកេន (ដល់រដូវរងា)** បានដល់ ដោយហេមន្តសម័យ គឺ រដូវរងា ។

---

១ ភូមា = ផលគណ្ឌស្ស បានដល់ ជាងឈើ ។ ជាងឈើនោះប្រើកូនតីង ដើម្បីកំណាត់ចំណែកឈើដែលលៀនចេញចំណែកខាងក្រោម ហើយឈូសចំណែកដែលលៀនចេញនោះ រមែងឈូសខ្ទឹមឈើនោះ ទើបហៅថា ផលគណ្ឌៈ ។

បទថា បដិប្បស្សម្ភន្តិ (រមែងពុកផុយដោយងាយ) បានដល់ រមែងវិនាសទៅ ។

ក្នុងបទថា ឯវមេវ ខោ (ដូច្នោះដូចគ្នា) នេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ព្រះសាសនា (ពាក្យប្រៀនប្រដៅ) គប្បីឃើញដូចមហាសមុទ្រ យោគាវចរ ដូចទូក ការត្រាច់ទៅក្នុងសម្នាក់របស់អាចារ្យ និងឧបជ្ឈាយ៍ ក្នុងវេលាដែលខ្លួនមានវស្សាតិចជាង ៥ របស់ភិក្ខុនោះ ដូចទូកស្ទុះទៅមកនៅក្នុងសមុទ្រ ភិក្ខុដែលមានសញ្ញោជនៈទាំងឡាយស្រាលស្តើង ដោយការបន្ទោបង់ គឺ បព្វជ្ជា ដោយកិច្ច មានឧទ្ទេស និងបរិបុច្ឆាជាដើមនោះឯង ដូចផ្តៅដែលចងទូកត្រាំក្នុងទឹកមហាសមុទ្រ ក៏ត្រូវធ្វើឲ្យរមាសស៊ីជាច់បន្តិចម្តងៗ វេលាដែលភិក្ខុជានិស្សយមុត្តកៈ (ផុតនិស្ស័យ) កំណត់កម្មដ្ឋានទៅក្នុងព្រៃ ដូចវេលាដែលទូកត្រូវគេលើកឡើងទុកខាងលើគោក ជ័រ គឺ តណ្ហារមែងស្ងួតទៅដោយវិបស្សនាញាណ ដូចខ្សែរមែងពុកផុយទៅ ដោយខ្យល់ និងកំដៅថ្ងៃ ការរីករាយនៃចិត្តដោយបីតិ និងបាមោជ្ជៈ ដែលអាស្រ័យកម្មដ្ឋានកើតឡើង ដូចខ្សែដែលសើមដោយដំណក់ទឹកសន្សើម ក្នុងវេលាយប់

ការដែលសញ្ញោជនៈទាំងឡាយមានកម្លាំងថយចុះ ដោយបីតិ និងបាមោជ្ជៈ ដែលសម្បយុត្តដោយវិបស្សនាញាណ ដូចផ្តៅចងទូកដែលត្រូវកំដៅដុត ក្នុងវេលាថ្ងៃ និងត្រូវជំណក់ទឹកសន្សើមផ្សើមនៅក្នុងវេលាយប់ រមែងធ្វើឲ្យវិនាសទៅ អរហត្តមគ្គញាណ ដូចភ្លៀងដែលធ្លាក់ចុះ ភិក្ខុអ្នកប្រារព្ធវិបស្សនា ចម្រើនវិបស្សនាដោយអំណាចនៃអារម្មណ៍ មានពួក ៧ នៃរូប[១] ជាដើម កាលកម្មដ្ឋានប្រាកដច្បាស់ហើយ ក្នុងថ្ងៃមួយបានឧតុជាទីសប្បាយជាដើម អង្គុយលើបល្ល័ង្កតែមួយ ក៏សម្រេចព្រះអរហត្តផល ដូចផ្តៅដែលចងទូកពុកផុយ ព្រោះទឹកភ្លៀងដែលធ្លាក់ចុះមក និងទឹកក្នុងមហាសមុទ្រ កាលជាព្រះអរហន្តអ្នកអស់សញ្ញោជនៈហើយ លោកក៏អនុគ្រោះមហាជន តាំងនៅរហូតអាយុខយ្យ ដូចទូកមានគ្រឿងចងពុកផុយហើយ ក៏តាំងនៅតែមួយរយៈ កាលព្រះខីណាស្រពបរិនិព្វានហើយ ដោយអនុបាទិសេស-និព្វានធាតុ ព្រោះការបែកធ្លាយនៃឧបាទានក្ខន្ធ សង្ខារដែលមានចិត្តគ្រប់

---

១ វិសុទ្ធិមគ្គ មគ្គាមគ្គញ្ញាណទស្សននិទ្ទេស = បដិសន្ធិ និងចុតិ ១, ការវិនាស ការចម្រើន និងការរលត់ ២ , រូបកើតពីអាហារ ៣ , រូបកើតពីឧតុ ៤ , រូបកើតពីកម្ម ៥ , រូបមានចិត្តជាសមុដ្ឋាន ៦, រូបធម្មជាតិ (រូបទាក់ទងនឹងអិន្ទ្រិយខាងក្រៅ) ។

គ្រង ក៏រកបញ្ញត្តិមិនបាន ដូចទូកដែលមានគ្រឿងពុកផុយទៅ ក៏បែកបាក់ទៅដោយលំដាប់ រកបញ្ញត្តិមិនបាន ។ ព្រះមានព្រះភាគទ្រង់សំដែងដល់សញ្ញោជនៈទាំងឡាយមានកម្លាំងថយចុះ ដោយឧបមានេះ ។

ចប់អដ្ឋកថា ភាវនាសូត្រទី ៧

# អដ្ឋកថា អគ្គិក្ខន្ធោបមសូត្រទី ៨

## ប្រៀបមនុស្សស្រីជាមួយគំនរភ្លើង

គប្បីជ្រាបវិនិច្ឆ័យក្នុង អគ្គិក្ខន្ធោបមសូត្រទី ៨ ដូចតទៅនេះ ៖

[៦៩] ព្រះមានព្រះភាគត្រាស់ទុកហើយ ព្រោះមានរឿងកើតឡើង ។ ក៏ការកើតឡើងនៃរឿងរបស់ព្រះសូត្រនេះ ខ្ញុំធ្លាប់ពោលទុកដោយពិស្តារហើយ ក្នុងអដ្ឋកថាចូឡច្ឆរាសង្ឃាតសូត្រ ។ បទថា **បស្សថ នោ** (អ្នកទាំងឡាយឃើញ... ឬទេ) កាត់បទជា **បស្សថ នុ** បានដល់ អ្នកទាំងឡាយឃើញឬទេ ។ បទថា **អាលិង្គិត្វា** (ក្រសោប) បានដល់ ឱបក្រសោប ។ បទថា **ឧបនិសីទេយ្យ** (ចូរទៅអង្គុយ) បានដល់ គប្បីចូលទៅអង្គុយជិត ។ បទថា **ឧបនិបជ្ជេយ្យ** (ដេក) បានដល់ គប្បីចូលទៅដេក ។ បទថា **អារោចយាមិ** (តថាគតនឹងប្រាប់) បានដល់ តថាគតនឹងពោល ។ បទថា **បដិវេទយាមិ** (ពន្យល់) បានដល់ តថាគតនឹងពោលប្រកាស ដាស់តឿនឲ្យយល់ ។ បទថា **វាលរជ្ជុយា** (ដោយខ្សែកន្ទុយសត្វ) បានដល់ ដោយខ្សែដែលបុគ្គលវេញហើយ ដោយកន្ទុយសេះ និងកន្ទុយគោ ។ បទថា

បច្ចារស្មឹ (ចំដើមទ្រូង) បានដល់ ត្រង់កណ្ដាលទ្រូង ។ បទថា ផេណុ-ទ្ទេហកំ (ដូចថ្ងៃបណ្ដើរកូន) បានដល់ ញ៉ាំងពពុះឲ្យផុសឡើង អធិប្បាយថា ឲ្យតាំងឡើង ។ បទថា អត្តត្ថំ (ប្រយោជន៍ខ្លួន) បានដល់ ប្រយោជន៍ខ្លួនដែលជាលោកិយៈ និងលោកុត្តរៈ ទាំងប្រព្រឹត្តក្នុងភពនេះ និងភពមុខ ។ សូម្បីក្នុង ប្រយោជន៍អ្នកដទៃ និង ប្រយោជន៍ទាំងពីរ ក៏ន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះដែលគួរពោលទាំងអស់ បានពោលទុកហើយព្រោះហេតុកើតនៃរឿង ក្នុងចូឡច្ឆរាសង្ឃាតសូត្រនោះឯង ។ ព្រះសាស្ដាកាលត្រាស់សូត្រនេះហើយ ទើបត្រាស់ចូឡច្ឆរាសង្ឃាតសូត្រ ។

ចប់អដ្ឋកថា អគ្គិក្ខន្ធោបមសូត្រទី ៨

# អដ្ឋកថា សុនេត្តអនុសាសនីសូត្រ ៩

*ពាក្យទូន្មានរបស់សុនេត្តសាស្ដាជាដើម*

[៧០] *សុនេត្តអនុសាសនីសូត្រទី ៩ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សុនេត្តអនុសាសនីសូត្រទី ៩

# អដ្ឋកថា អរកានុសាសនីសូត្រទី ១០

## ពាក្យទូន្មានរបស់អរកសាស្តា

គប្បីជ្រាបវិនិច្ឆ័យក្នុង អរកានុសាសនីសូត្រទី ១០ ដូចតទៅនេះ ៖

[៧១] បទថា **បរិត្តំ** (តិច) បានដល់ តិច គឺ តិចតួច ។ ពិតហើយ ជីវិតនោះឈ្មោះថា មានប្រមាណតិចប៉ុណ្ណោះ ព្រោះមានកិច្ចនាទីតិចតួចខ្លះ ព្រោះដោយខណៈតិចខ្លះ ព្រោះតាំងនៅដោយខណៈតិចខ្លះ ។ ជីវិតនោះ ឈ្មោះថា **លហុកំ** (លឿនរហ័ស) បានដល់ ព្រោះកើតរហ័សរលត់រហ័ស ។ បទថា **មន្តាយ ពោទ្ធព្វំ** (គប្បីដឹងបានដោយបញ្ញា) បានដល់ គប្បីពាល់ត្រូវដោយការដឹង អធិប្បាយថា គប្បីដឹងដោយបញ្ញា ។ បទថា **បព្វតេយ្យា** (ហូរចុះអំពីភ្នំ) បានដល់ ដែលកើតអំពីភ្នំ ។ បទថា **ហារហារិនី** (នាំទៅនូវវត្ថុដែលគួរនាំទៅបាន) បានដល់ អាចនឹងបន្សាត់នាំវត្ថុដែលគប្បីនាំទៅបាន ដូចដើមឈើ ដើមបបុស និងដើមឫស្សីជាដើម ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ហើយ ។

ចប់អដ្ឋកថា អរកានុសាសនីសូត្រទី ១០

### ចប់អដ្ឋកថា មហាវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# វិនយធរវគ្គវណ្ណនាទី ៣[១]

## អដ្ឋកថា បឋមវិនយសូត្រទី ១

*ព្រះវិនយធរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវិនយសូត្រទី ១នៃវគ្គទី ៣ ដូចតទៅនេះ ៖*

*[៧២] បទថា **អាបត្តឹ ជានាតិ (ដឹងអាបត្តិ)** បានដល់ រមែងដឹងអាបត្តិនោះថា ជាអាបត្តិ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា បឋមវិនយធរសូត្រទី ១

---

១ បិដក ជា វិនយវគ្គ ។

# អដ្ឋកថា ទុតិយវិនយធរសូត្រទី ២

## ព្រះវិនយធរ

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវិនយសូត្រទី ២ ទៅនេះ ៖

[៧៣] បទថា *ស្វាគតានិ (ស្ទាត់ជំនាញ)* បានដល់ មកល្អហើយ គឺ ចេះចាំដោយល្អហើយ ។ បទថា *សុវិភត្តានិ (ចែករំលែកដោយល្អ)* បានដល់ បែងចែកជាចំណែកទុកដោយល្អហើយ ។ បទថា *សុប្បវត្តីនិ (បរិយាយល្អហើយ)* បានដល់ ប្រព្រឹត្តទៅដោយល្អ ក្នុងទីដែលនឹកបានៗ គឺ សូត្របានយ៉ាងស្ទាត់ជំនាញ ។ បទថា *សុវិនិច្ឆិតានិ (មានវិនិច្ឆ័យល្អហើយ)* បានដល់ វិនិច្ឆ័យហើយដោយល្អ ។ បទថា *សុត្តសោ (ទាំងដោយសូត្រ)* បានដល់ ដោយវិភង្គ ។ បទថា *អនុព្យញ្ជនសោ (និងដោយអនុព្យញ្ជនៈ)* បានដល់ ដោយខន្ធកៈ និងបរិវារៈ ។

ចប់អដ្ឋកថា ទុតិយវិនយធរសូត្រទី ២

# អដ្ឋកថា តតិយវិនយធរសូត្រទី ៣

## *ព្រះវិនយធរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយវិនយធរសូត្រទី ៣ ដូចតទៅនេះ ៖*

*[៧៤] បទថា* ***វិនយេ ខោ បន ឋិតោ ហោតិ*** *(ខ្ជាប់ខ្ជួននៅក្នុងព្រះវិន័យ) បានដល់ តាំងមាំនៅក្នុងលក្ខណៈនៃវិន័យ ។ បទថា* ***អសំហីរោ*** *(មិនឃ្លេងឃ្លោង) បានដល់ មិនអាចនឹងឲ្យលះបង់ការប្រកាន់ក្នុងវត្ថុដែលប្រកាន់ហើយ ។*

ចប់អដ្ឋកថា តតិយវិនយធរសូត្រទី ៣

# អដ្ឋកថា ចតុត្ថវិនយធរសុត្រទី ៤

*ព្រះវិនយធរ*

[៧៥] *ក្នុងសូត្រទី ៤ នេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ចតុត្ថវិនយធរសុត្រទី ៤

# អដ្ឋកថា បឋមវិនយធរសោភណសូត្រទី ៥

## ព្រះវិនយធរល្អ

*[៧៦] សូត្រទី ៥ នេះ ព្រះអដ្ឋកថាមិនបានកែអត្ថទុកទេ ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថា ទុតិយវិនយធរសោភណសូត្រទី ៦

*ព្រះវិនយធរល្អ*

[*៧៧*] *សូត្រទី ៦ នេះ ព្រះអដ្ឋកថាមិនបានកែអត្ថទុកទេ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថា តតិយវិនយធរសោភណសូត្រទី ៧

## *ព្រះវិនយធរល្អ*

[៧៨] *សូត្រទី ៧ នេះ ព្រះអដ្ឋកថាមិនបានកែអត្ថទុកទេ ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថា ចតុត្ថវិនយធរសោភណសូត្រទី ៨

*ព្រះវិនយធរល្អ*

[៧៩] *សូត្រទី ៨ នេះ ព្រះអដ្ឋកថាមិនបានកែអត្ថទុកទេ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថា សត្ថុសាសនសូត្រទី ៩

## *ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សត្ថុសាសនសូត្រទី ៩ ដូចតទៅនេះ ៖*

*[៨០] បទថា **ឯកោ** (ម្នាក់ឯង) បានដល់ មិនមានអ្នកទី ២ ។ បទថា **វូបកដ្ឋោ** (ជាអ្នកគេចចេញចាកពួក) បានដល់ ចៀសចេញទៅហើយ គឺ ស្ងាត់ហើយ នៅឆ្ងាយហើយ ផ្លូវកាយក៏ឆ្ងាយចាកគណៈ ផ្លូវចិត្តក៏ឃ្លាតចាកកិលេសទាំងឡាយ ។ បទថា **អប្បមត្តោ** (មិនប្រមាទ) បានដល់ តាំងនៅហើយក្នុងការមិនប្រាសចាកសតិ ។ បទថា **បហិតត្តោ** (បញ្ជូនចិត្ត) បានដល់ មានចិត្តតាំងមាំ ។ បទថា **និព្វិទាយ** (ដើម្បីសេចក្តីនឿយណាយ) បានដល់ ដើម្បីប្រយោជន៍ដល់ការធុញទ្រាន់ក្នុងវដ្តៈ ។ បទថា **វិរាគាយ** (ដើម្បីប្រាសចាកតម្រេក) បានដល់ ដើម្បីប្រយោជន៍ដល់ការលះបង់កិលេសមានរាគៈជាដើម ។ បទថា **និរោធាយ** (ដើម្បីការរលត់) បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើមិនឲ្យប្រព្រឹត្តទៅបាន ។ បទថា **វូបសមាយ** (ដើម្បីស្ងប់រម្ងាប់) បានដល់ ដើម្បីសេចក្តីរម្ងាប់កិលេស គឺ ដើម្បីមិនឲ្យកិលេស*

ប្រព្រឹត្តទៅបាន ។ បទថា **អភិញ្ញាយ** (ដើម្បីសេចក្ដីដឹងក្រៃលែង) បាន ដល់ ដើម្បីប្រយោជន៍ដល់ការលើកឡើងកាន់ត្រៃលក្ខណ៍ ហើយដឹងក្រៃ-លែង ។ បទថា **សម្ពោធាយ** (ដើម្បីត្រាស់ដឹង) បានដល់ ដើម្បីប្រយោជន៍ ដល់ការត្រាស់ដឹងធម៌ ពោលគឺ មគ្គ ។ បទថា **និព្វានាយ** (ដើម្បីនិព្វាន) បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ចប់អដ្ឋកថា សត្ថុសាសនសូត្រទី ៩

# អដ្ឋកថា អធិករណសមថសូត្រទី ១០

## វិធីរម្ងាប់អធិករណ៍

គប្បីជ្រាបវិនិច្ឆ័យក្នុង អធិករណសមថសូត្រទី ១០ ដូចតទៅនេះ ៖

[៨១] បទថា ធម៌ដែលឈ្មោះថា **អធិករណសមថា (សម្រាប់រម្ងាប់អធិករណ៍)** ព្រោះអត្ថថា រម្ងាប់ គឺ ញុំាំងអធិករណ៍ឲ្យចូលទៅដល់ការស្ងប់រម្ងាប់ ។ បទថា **ឧប្បន្នុប្បន្នានំ (ដែលកើតហើយ)** បានដល់ កើតឡើងហើយកើតឡើងទៀត ។ បទថា **អធិករណានំ (អធិករណ៍)** បានដល់ អធិករណ៍ ៤ នេះ គឺ វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ កិច្ចាធិករណ៍ ១ អាបត្តាធិករណ៍ ១ ។ បទថា **សមថាយ វូបសមាយ (ដើម្បីស្ងប់រម្ងាប់)** បានដល់ ដើម្បីស្ងប់ និងដើម្បីចូលទៅរម្ងាប់ ។ គប្បីប្រើសមថៈ ៧ ទាំងនេះ គឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកវិន័យ ១ ។ ន័យក្នុងការវិនិច្ឆ័យសមថៈទាំងនោះ គប្បីកាន់យកអំពីអដ្ឋកថាព្រះវិន័យចុះ ។ មួយ៉ាងទៀត ក្នុងអដ្ឋកថានៃសង្គីតិសូត្រ ក្នុង

ទីឃនិកាយ ក៏បានពោលទុកពិស្តារហើយនោះឯង ក្នុងអដ្ឋកថាសាមគាម សូត្រក្នុងមជ្ឈិមនិកាយ ក៏បានពោលទុកដោយពិស្តារហើយដូចគ្នា ។

ចប់អដ្ឋកថា អធិករណសមថៈសូត្រទី ១០

## ចប់អដ្ឋកថា វិនយធរវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៥ សូត្រ

# ចប់វគ្គដែលមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

# អដ្ឋកថាព្រះសូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ

[៨២-៩០] *តអំពីនេះទៀត ព្រះសូត្រ ៧ សូត្រ មានសេចក្ដីងាយហើយ ។ ព្រោះក្នុងព្រះសូត្រទាំងនេះ សូត្រណាៗ ឈ្មោះថា មានន័យដែលមិនធ្លាប់ពោលទុកហើយ មិនមានឡើយ ដូច្នេះឯង ។*

ចប់ព្រះសូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ

# ចប់អដ្ឋកថា

# អង្គុត្តរនិកាយ សត្តកនិបាត

# ឈ្មោះ

# មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ | |
| សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង | |
| ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |